# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាង
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង
# រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

# បុព្វកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ("កូរ៉េ") (តទៅនេះហៅជារួមថា "គូភាគី" និងដោយឡែកថា "ភាគីម្ខាង")

**ដោយទទួលស្គាល់** នូវភាពជាដៃគូដ៏យូរអង្វែងនិងរឹងមាំ និងតម្រូវការក្នុងការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មដ៏ជិតស្និទ្ធរបស់ខ្លួន

**ដោយជឿជាក់ថា** កិច្ចព្រមព្រៀងនេះនឹងបង្កើតបាននូវទីផ្សារដែលត្រូវបានពង្រីកនិងធានាសម្រាប់ទំនិញ និងសេវាកម្ម និងបង្កើតបាននូវបរិយាកាសដែលអាចព្យាករណ៍បាននិងមានស្ថេរភាពសម្រាប់ការវិនិយោគ ដែលតាមរយៈនេះ នឹងលើកកម្ពស់ភាពប្រកួតប្រជែងនៃក្រុមហ៊ុនធុរកិច្ចនានារបស់ខ្លួនក្នុងទីផ្សារសកល

**ដោយស្វះស្វែង** បង្កើតវិធានច្បាស់លាស់និងផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមក ក្នុងការគ្រប់គ្រងពាណិជ្ជកម្ម និងវិនិយោគរបស់ខ្លួន ខណៈពេលដែលទទួលស្គាល់ផងដែរនូវសិទ្ធិរបស់គូភាគីក្នុងការចាត់វិធានការចាំបាច់ដើម្បីសម្រេចបានគោលបំណងគោលនយោបាយសាធារណៈដែលទទួលស្គាល់ដោយច្បាប់

**ដោយមានការប្តេជ្ញាចិត្ត** ចូលរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយសុខដុមរមនានិងការពង្រីកពាណិជ្ជកម្មសកលលោកដោយដកចេញនូវឧបសគ្គពាណិជ្ជកម្មតាមរយៈការបង្កើតតំបន់ពាណិជ្ជកម្មសេរី

**ដោយអះអាង** អំពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការជំរុញការបង្កើតទីផ្សារសេដ្ឋកិច្ចបើកចំហរក្នុងតំបន់អាស៊ី និងក្នុងការលើកទឹកចិត្តឱ្យធ្វើសមាហរណកម្មសេដ្ឋកិច្ចនៃសេដ្ឋកិច្ចអាស៊ីសំដៅជំរុញការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងវិនិយោគបន្ថែមទៀតក្នុងតំបន់

**ដោយទទួលស្គាល់** អំពីភាពខុសគ្នានៃកម្រិតការអភិវឌ្ឍសេដ្ឋកិច្ចរវាងគូភាគី

**ដោយមានបំណង** ជំរុញកំណើនសេដ្ឋកិច្ច បង្កើតឱកាសការងារថ្មីៗ លើកកម្ពស់កម្រិតជីវភាពរស់នៅ និងធ្វើឱ្យប្រសើរឡើងសុខុមាភាពសាធារណៈ

**ដោយតាំងចិត្ត** លើកកម្ពស់តម្លាភាព និងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយពាក់ព័ន្ធរាល់ភាគីមានប្រយោជន៍រួមបញ្ចូលទាំងវិស័យឯកជន

**ដោយកសាងលើ** សិទ្ធិនិងកាតព្វកិច្ចរៀងខ្លួនក្រោម *កិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក* និងកិច្ចព្រមព្រៀងពហុភាគី តំបន់ និងទ្វេភាគី ដែលភាគីទាំងពីរជាភាគី និង

**ដោយអះអាងជាថ្មី** នូវបំណងកសាងលើការប្តេជ្ញាចិត្តក្រោម *កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ និងរដ្ឋាភិបាលនៃប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍* ព្រមទាំងកិច្ចព្រមព្រៀងពាក់ព័ន្ធដទៃទៀតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ

**បានព្រមព្រៀងគ្នា** ដូចតទៅ៖

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១.១៖ និយមន័យទូទៅ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែត្រូវបានបញ្ជាក់ផ្សេងពីនេះ

**កិច្ចព្រមព្រៀង ស្តីពីកសិកម្ម** សំដៅដល់ ***កិច្ចព្រមព្រៀង ស្តីពីកសិកម្ម*** នៅក្នុងឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (WTO)

**កិច្ចព្រមព្រៀង ស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ** សំដៅដល់ ***កិច្ចព្រមព្រៀង ស្តីពីការអនុវត្តមាត្រា VI នៃកិច្ចព្រមព្រៀងទូទៅ ស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ឆ្នាំ១៩៩៤*** នៅក្នុងឧបសម្ព័ន្ធ ១ ក នៃកិច្ចព្រមព្រៀង WTO

**រដ្ឋបាលគយ** សំដៅដល់អង្គាធរមានសមត្ថកិច្ចក្រោមច្បាប់របស់ភាគីនីមួយៗ ទទួលខុសត្រូវលើការគ្រប់គ្រង និងអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីគយរបស់ខ្លួន៖

(ក) សម្រាប់កម្ពុជា៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង

(ខ) សម្រាប់កូរ៉េ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬស្ថាប័នសេវាកម្មគយកូរ៉េ ឬអ្នកទទួលសិទ្ធិបន្តរបស់ខ្លួន

**ពន្ធគយ** សំដៅដល់ពន្ធគយ ឬពន្ធនាំចូល និងបន្ទុកគ្រប់ប្រភេទដែល បានអនុវត្តភ្ជាប់ជាមួយការនាំចូលទំនិញ លើកលែងតែ ៖

(ក) បន្ទុកសមមូលនឹងពន្ធក្នុងស្រុកដែលបានអនុវត្តដោយមានសង្គតិភាពជាមួយមាត្រា III: ២ នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ចំពោះលក្ខណៈដូចគ្នា លក្ខណៈប្រកួតប្រជែងផ្ទាល់ ឬទំនិញដែលអាចជំនួសបានរបស់ភាគីម្ខាង ឬចំពោះទំនិញ ដែលក្នុងនោះ ទំនិញនាំចូលត្រូវបានផលិត ឬបង្កើតទាំងស្រុង ឬដោយផ្នែក ពីទំនិញនោះ

(ខ) ពន្ធដែលបានដាក់ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ភាគីម្ខាងដោយមានសង្គតិភាពជាមួយជំពូកទី ៥ (ឧបាស្រ័យពាណិជ្ជកម្ម)

(គ) កម្រៃឬបន្ទុកផ្សេងៗទៀតពាក់ព័ន្ធនឹងការនាំចូលដែលមានតម្លៃសមមាត្រនឹងថ្លៃសេវាកម្មដែលបានប្រើប្រាស់

(ឃ) ពន្ធដែលបានដាក់ ស្របតាមមាត្រា៥ នៃកិច្ចព្រមព្រៀង ស្តីពីកសិកម្ម ក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀង WTO ឬ

(ង) បុព្វលាភដែលបានផ្តល់ឱ្យ ឬបានប្រមូលពីទំនិញនាំចូល តាមរយៈប្រតិបត្តិការប្រព័ន្ធផ្គត់ផ្គង់សេវាកម្មគយ ពាក់ព័ន្ធនឹងការគ្រប់គ្រងលើការរិតត្បឹតបរិមាណនាំចូល ឬកូតាអត្រាពន្ធគយ

**ច្បាប់ និងបទប្បញ្ញត្តិគយ** សំដៅដល់បទប្បញ្ញត្តិនិយ័តកម្មនិងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ ការផ្លាស់ទី ឬសន្និធិទំនិញ ការគ្រប់គ្រងនិងការអនុវត្តបទប្បញ្ញត្តិដែលត្រូវបានដាក់បន្ទុកយ៉ាងជាក់

លាក់ឱ្យទៅអាជ្ញាធរគយទទួលខុសត្រូវ និងរាល់បទប្បញ្ញតិដែលធ្វើឡើងដោយអាជ្ញាធរគយនេះក្រោមសិទ្ធិអំណាចកំណត់ដោយច្បាប់ របស់ខ្លួន

**កិច្ចព្រមព្រៀង ស្តីពីការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ** សំដៅដល់ ***កិច្ចព្រមព្រៀង ស្តីពីការអនុវត្តមាត្រា VII នៃកិច្ចព្រមព្រៀងទូទៅ ស្តីពីពន្ធគយនិងពាណិជ្ជកម្ម ឆ្នាំ១៩៩៤***នៅក្នុងឧបសម្ព័ន្ធ ១ ក នៃកិច្ចព្រមព្រៀង WTO

**ថ្ងៃ** សំដៅដល់ថ្ងៃប្រតិទិន រាប់បញ្ចូលទាំងថ្ងៃចុងសប្តាហ៍និងថ្ងៃឈប់សម្រាកសាធារណៈ

**ដែលមានស្រាប់** សំដៅដល់ការនៅជាធរមានក្នុងកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ

**កិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្មសេវាកម្ម** (GATS) សំដៅដល់ ***កិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្មសេវាកម្ម*** នៅក្នុងឧបសម្ព័ន្ធ ១ ខ នៃកិច្ចព្រមព្រៀង WTO

**កិច្ចព្រមព្រៀងទូទៅ ស្តីពីពន្ធគយនិងពាណិជ្ជកម្ម (GATT) ឆ្នាំ១៩៩៤** សំដៅដល់ ***កិច្ចព្រមព្រៀងទូទៅ ស្តីពីពន្ធគយនិងពាណិជ្ជកម្ម ឆ្នាំ១៩៩៤*** រួមបញ្ចូលទាំងកំណត់សម្គាល់របស់វា និងបទប្បញ្ញត្តិបន្ថែមដែលជាផ្នែកមួយ នៃកិច្ចព្រមព្រៀង WTO

**ទំនិញ** សំដៅដល់រាល់ទំនិញ ផលិតផល របស់របរ ឬវត្ថុធាតុនានា

**ប្រព័ន្ធសុខដុម** ឬ HS សំដៅដល់នាមវលីនៃប្រព័ន្ធបរិយាយមុខទំនិញ និងកំណត់លេខកូដសុខដុម ដូចបានកំណត់ក្នុង ***អនុសញ្ញាអន្តរជាតិ ស្តីពីនាមវលីនៃប្រព័ន្ធបរិយាយមុខទំនិញ និងកំណត់លេខកូដសុខដុម*** រួមបញ្ចូលទាំងអស់នូវកំណត់សម្គាល់គតិយុត្តិផ្សេងៗភ្ជាប់ជាមួយ ដែលត្រូវបានចូលជាធរមាន និងធ្វើវិសោធនកម្មជាបន្តបន្ទាប់

**គណៈកម្មាធិការចម្រុះ** សំដៅដល់គណៈកម្មាធិការចម្រុះ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ ដែលបានបង្កើតឡើងក្រោមមាត្រា១០.១ (គណៈកម្មាធិការចម្រុះ)

**នីតិបុគ្គល** សំដៅដល់នីតិបុគ្គលណាក៏ដោយដែលត្រូវបានបង្កើតត្រឹមត្រូវ ឬរៀបចំឡើងក្រោមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ទោះបីជាដើម្បីប្រាក់ចំណេញ ឬមិនដើម្បីប្រាក់ចំណេញ និងទោះបីជាកម្មសិទ្ធរបស់ឯកជន ឬរបស់រដ្ឋាភិបាល រាប់បញ្ចូលទាំងក្រុមហ៊ុនសាជីវកម្ម បរធនបាលកិច្ច ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនចម្រុះ ក្រុមហ៊ុនឯកបុគ្គល ឬសមាគម

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (**ASEAN-Korea FTA**) សំដៅដល់ *កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ* និងកិច្ចព្រមព្រៀងពាក់ព័ន្ធដទៃទៀតដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រា ១.៤ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ

**វិធានការ** សំដៅដល់វិធានការណាក៏ដោយដែលដាក់ចេញដោយភាគីណាមួយ ទោះបីជាក្នុងទម្រង់ច្បាប់លិខិតបទដ្ឋានគតិយុត្ត វិធាន នីតិវិធី សេចក្តីសម្រេច ចំណាត់ការរដ្ឋបាល ឬទម្រង់ផ្សេងៗទៀត

**វិធានការអនុម័ត ឬរក្សាទុកដោយភាគីណាមួយ** សំដៅដល់វិធានការដែលត្រូវបានអនុម័ត ឬរក្សាទុកដោយ៖

(ក) រដ្ឋាភិបាល ឬអាជ្ញាធរថ្នាក់កណ្តាល ឬថ្នាក់ក្រោមជាតិ និង

(ខ) អង្គភាពមិនមែនរដ្ឋាភិបាលដែលទទួលបានប្រតិភូកម្មអំណាចពីរដ្ឋាភិបាល ឬអាជ្ញាធរថ្នាក់កណ្តាល ឬថ្នាក់ក្រោមជាតិ

**ជនជាតិ** សំដៅដល់

(ក) សម្រាប់កម្ពុជា៖ រាល់បុគ្គលដែលជាពលរដ្ឋខ្មែរដែលមានកំណត់ក្នុងខ្លឹមសារនៃ *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* និង *ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលបានប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ* ឬអាចត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ និង

(ខ) សម្រាប់កូរ៉េ៖ ជនជាតិកូរ៉េក្នុងខ្លឹមសារនៃ *ច្បាប់សញ្ជាតិ* ដូចបានធ្វើវិសោធនកម្មជាបន្តបន្ទាប់

**ទំនិញមានដើមកំណើត** សំដៅដល់ទំនិញ ឬវត្ថុធាតុដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានដើមកំណើតក្រោមជំពូកទី៣ (វិធានដើមកំណើត)

**បុគ្គល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល

**កិច្ចព្រមព្រៀង ស្តីពីវិធានការការពារ** សំដៅដល់ ***កិច្ចព្រមព្រៀង ស្តីពីវិធានការការពារ*** ក្នុងឧបសម្ព័ន្ធ ១ ក នៃកិច្ចព្រមព្រៀង WTO

**កិច្ចព្រមពៀង SCM** សំដៅដល់ ***កិច្ចព្រមពៀង ស្តីពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ*** ក្នុងឧបសម្ព័ន្ធ ១ ក នៃកិច្ចព្រមព្រៀង WTO

**បទប្បញ្ញត្តិបច្ចេកទេស បទដ្ឋាន និងនីតិវិធីវាយតម្លៃភាពអនុលោម** ត្រូវបានកំណត់អត្ថន័យដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃកិច្ចព្រមព្រៀង ស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្ម ដូចមានក្នុងឧបសម្ព័ន្ធ១ នៃកិច្ចព្រមព្រៀង WTO (តទៅនេះហៅថា "កិច្ចព្រមព្រៀង TBT")

**ទឹកដី** សំដៅដល់៖

១. សម្រាប់កម្ពុជា៖ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់សមុទ្រ ដែលរួមមានខ្ពង់រាបបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងផ្នែកខាងក្រៅនៃដែនសមុទ្រ និងដែនអាកាសដែលព្រះរាជាណាចក្រកម្ពុជាអនុវត្តសិទ្ធិអធិបតេយ្យ ឬយុត្តាធិការ ដោយអនុលោមតាមច្បាប់អន្តរជាតិ និង

២. សម្រាប់កូរ៉េ៖ ដែនដីគោក ដែនសមុទ្រ និងដែនអាកាសក្រោមអធិបតេយ្យភាពរបស់ខ្លួន និងតំបន់សមុទ្រ ដែលរួមមានខ្ពង់រាបបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រដែលជាប់ និងហួសដែនសមុទ្រខាងក្រៅដែលកូរ៉េអនុវត្តសិទ្ធិអធិបតេយ្យ ឬយុត្តាធិការ ដោយអនុលោមតាមច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុករបស់ខ្លួន

**អង្គការ** WTO សំដៅដល់ អង្គការពាណិជ្ជកម្មពិភពលោក និង

**កិច្ចព្រមព្រៀង** WTO សំដៅដល់ ***កិច្ចព្រមព្រៀងទីក្រុងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក*** ដែលបានចុះហត្ថលេខានៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤។

## មាត្រា១.២៖ ការបង្កើតតំបន់ពាណិជ្ជកម្មសេរី

ដោយមានសង្គតិភាពជាមួយមាត្រា XXIV នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងមាត្រា V នៃកិច្ចព្រមព្រៀង GATS គូភាគីសម្រេចបង្កើតតំបន់ពាណិជ្ជកម្មសេរី ដោយអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១.៣៖ គោលបំណង

គោលបំណង នៃកិច្ចព្រមព្រៀងនេះ គឺដើម្បី៖

(ក) សម្រេចបាននូវការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញជាជុំកំភួនរវាងគូភាគីដោយអនុលោមតាមមាត្រា XXIV នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤

(ខ) សម្រេចបាននូវសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មជាជុំកំភួនរវាងគូភាគីដោយអនុលោមតាមមាត្រា V នៃកិច្ចព្រមព្រៀង GATS

(គ) ជំរុញការប្រកួតប្រជែងក្នុងសេដ្ឋកិច្ចរបស់គូភាគី ជាពិសេសការប្រកួតប្រជែងដែលពាក់ព័ន្ធនឹងទំនាក់ទំនងសេដ្ឋកិច្ចរវាងគូភាគី

(ឃ) លើកកម្ពស់តម្លាភាពនៃវិធានការពាណិជ្ជកម្មនិងវិនិយោគរបស់គូភាគី តាមរយៈការចែករំលែកនូវឧត្តមានុវត្តន៍និយ័តកម្ម និងការជំរុញនវានុវត្តន៍ក្នុងវិស័យដែលមានផលប្រយោជន៍ទៅវិញទៅមក និង

(ង) បង្កើតក្របខ័ណ្ឌសម្រាប់ជំរុញបន្ថែមនូវកិច្ចសហប្រតិបត្តិការ សំដៅពង្រីក និងលើកកម្ពស់សារៈប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១.៤៖ ទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងដទៃទៀត

១. គូភាគីអះអាងជាថ្មីអំពីសិទ្ធិ និងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីដែលគូភាគីជាភាគី រួមបញ្ចូលទាំងកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ។

២. ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ កិច្ចព្រមព្រៀងនេះ មិនត្រូវបកស្រាយដើម្បីគេចវេសពីកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិរវាងគូភាគី ដែលផ្តល់ឱ្យនូវប្រព្រឹត្តកម្មដែលមានភាពអនុគ្រោះចំពោះទំនិញ សេវាកម្ម ការវិនិយោគ ឬបុគ្គលនានា ជាងប្រព្រឹត្តកម្មដែលបានផ្តល់ឱ្យក្រោមកិច្ចព្រមព្រៀងនេះនោះទេ។

៣. លើកលែងតែមានចែងផ្សេងពីនេះក្នុងកិច្ចព្រមព្រៀងនេះ ក្នុងករណីមានអសង្គតិភាពរវាង កិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងណាមួយដែលគូភាគីជាភាគី គូភាគីត្រូវពិគ្រោះយោបល់គ្នាដើម្បីស្វែងរកដំណោះស្រាយដែលមានការពេញចិត្តទាំងសងខាង ដោយពិចារណាលើគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ។

**មាត្រា១.៥៖ វិសាលភាព នៃភាតព្វកិច្ច**

ផ្អែកលើបទប្បញ្ញត្តិទាំងឡាយ នៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗ ត្រូវធានានូវការគោរពរាល់កាតព្វកិច្ច និងការសន្យាក្រោមកិច្ចព្រមព្រៀងនេះរបស់រដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិ និងរបស់អង្គភាពមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្តសិទ្ធិអំណាចធ្វើអភិបាលកិច្ច ដែលរដ្ឋាភិបាលថ្នាក់កណ្តាល និងរដ្ឋាភិបាល ឬអាជ្ញាធរថ្នាក់ក្រោមជាតិ បានធ្វើប្រតិភូកម្មជូនពួកគេ។

# ជំពូកទី ២
# ពាណិជ្ជកម្មទំនិញ

## ផ្នែក ក៖ បទប្បញ្ញត្តិទូទៅ

### មាត្រា២.១៖ និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ៖

**គំរូពាណិជ្ជកម្មដែលមានតម្លៃតិចតួច** សំដៅដល់គំរូពាណិជ្ជកម្ម ទោះជាត្រូវបានដឹកជញ្ជូនដាច់ពីគ្នា ឬសរុបរួមគ្នាក៏ដោយ ដែលមានតម្លៃមិនលើសពីតម្លៃដែលមានកំណត់ក្នុងច្បាប់ បទប្បញ្ញត្តិ ឬនីតិវិធីគ្រប់គ្រងការនាំចូលតាមរបបប្រវេសន៍កាលិករបស់ភាគីម្ខាង ឬដូចមានសម្គាល់ថា រហែក ធ្លុះ ឬក្រៅពីនេះ ត្រូវបានចាត់ទុកថាមិនសមស្របសម្រាប់ការដាក់លក់ ឬការប្រើប្រាស់ លើកលែងតែសម្រាប់ធ្វើជាគំរូពាណិជ្ជកម្ម។

**ប្រតិបត្តិការតាមរយៈកុងស៊ុល** សំដៅដល់លក្ខខណ្ឌតម្រូវដែលតម្រូវឱ្យទំនិញរបស់ភាគីម្ខាង សម្រាប់នាំចេញទៅដែនដីនៃភាគីម្ខាងទៀត ត្រូវដាក់ជូនស្ថានកុងស៊ុលតំណាងនៃភាគីនាំចូល នៅក្នុងដែនដីនៃភាគីនាំចេញ ដើម្បីធ្វើការត្រួតពិនិត្យជាមុន ក្នុងគោលបំណងទទួលបាន វិក្កយបត្រកុងស៊ុល ឬទិដ្ឋាការកុងស៊ុល សម្រាប់វិក្កយបត្រពាណិជ្ជកម្ម វិញ្ញាបនបត្រដើមកំណើត និវេទនប័ណ្ណ ប្រតិវេទន៍នាំចេញរបស់អ្នកបញ្ជូនទំនិញ ឬឯកសារគយផ្សេងទៀត ដែលតម្រូវឱ្យមានក្នុងការនាំចូល ឬទាក់ទងនឹងការនាំចូល។

**ការរួចពន្ធ** សំដៅដល់ មិនមានកាតព្វកិច្ចត្រូវបង់ពន្ធគយ។

**ការផ្តល់អាជ្ញាប័ណ្ណនាំចូល** សំដៅដល់នីតិវិធីរដ្ឋបាលដែលតម្រូវឱ្យមានការដាក់ពាក្យស្នើសុំ ឬឯកសារផ្សេងៗ (ក្រៅពីតម្រូវការជាទូទៅសម្រាប់គោលបំណងបញ្ចេញទំនិញពីគយ) ទៅអង្គភាពរដ្ឋបាលដែលពាក់ព័ន្ធជាលក្ខខណ្ឌមុនធ្វើការនាំចូលទៅក្នុងដែនដីនៃភាគីនាំចូល។ និង

**វិធានការមិនមែនពន្ធគយ** សំដៅដល់វិធានការគោលនយោបាយ ក្រៅពីពន្ធគយធម្មតាដែលអាចមានផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច លើពាណិជ្ជកម្មទំនិញអន្តរជាតិ រួមមានការប្រែប្រួលបរិមាណដែលបានធ្វើពាណិជ្ជកម្ម ឬតម្លៃ ឬក៏ទាំងបរិមាណនិងទាំងតម្លៃ។

### មាត្រា២.២៖ វិសាលភាព និងដែនអនុវត្ត

លើកលែងតែមានការចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ជំពូកនេះត្រូវអនុវត្តចំពោះពាណិជ្ជកម្មទំនិញរវាងគូភាគី។

## ផ្នែក ខ៖ ប្រព្រឹត្តិកម្មជាតិ

### មាត្រា២.៣៖ ប្រព្រឹត្តិកម្មជាតិ

ភាគីនីមួយៗ ត្រូវផ្តល់ប្រព្រឹត្តិកម្មជាតិចំពោះទំនិញរបស់ភាគីម្ខាងទៀត អនុលោមតាមមាត្រា III នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ រាប់បញ្ចូលទាំងកំណត់សម្គាល់បកស្រាយ។ ក្នុងគោលបំណងនេះ មាត្រា

III នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងកំណត់សម្គាល់បកស្រាយ ត្រូវបានដាក់បញ្ចូលនិងក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ *ដែលត្រូវយកមកអនុវត្តដូចគ្នា។*

## ផ្នែក គៈ ការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយ

### មាត្រា២.៤៖ ការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយ

១. លើកលែងតែមានចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ មិនមានភាគីណាមួយអាចដំឡើងពន្ធគយដែលមានស្រាប់ ដូចបានកំណត់នៅក្នុងតារាងសន្យានៅក្នុងឧបសម្ព័ន្ធ២-ក ឬអនុវត្តពន្ធគយថ្មីចំពោះទំនិញដែលមានដើមកំណើតឡើយ។

២. លើកលែងតែមានចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវបន្តកាត់បន្ថយ ឬលុបបំបាត់ពន្ធគយជាបន្តបន្ទាប់លើទំនិញដែលមានដើមកំណើត អនុលោមតាមតារាងសន្យាក្នុងឧបសម្ព័ន្ធ ២-ក។

៣. តាមសំណើរបស់ភាគីណាមួយ គូភាគីត្រូវពិគ្រោះយោបល់ដើម្បីពិចារណាលើការពន្លឿន ការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយ ដូចបានកំណត់ក្នុងតារាងសន្យារបស់ខ្លួនក្នុងឧបសម្ព័ន្ធ ២-ក។ ការព្រមព្រៀងណាមួយដោយគូភាគី ក្នុងការពន្លឿនការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយលើទំនិញ ត្រូវយកមកជំនួសអត្រាពន្ធគយ ឬប្រភេទដំណាក់កាល ដែលបានកំណត់ក្នុងតារាងសន្យារបស់ខ្លួនក្នុងឧបសម្ព័ន្ធ ២-ក សម្រាប់ទំនិញទាំងនោះ ហើយត្រូវចូលជាធរមានបន្ទាប់ពីទទួលបានការអនុម័តដោយភាគីនីមួយៗ ដោយអនុលោមតាមនីតិវិធីច្បាប់ជាធរមានរបស់ភាគីនីមួយៗ។

៤. ភាគីម្ខាងអាចពន្លឿនការកាត់បន្ថយ ឬលុបបំបាត់ពន្ធគយជាឯកតោភាគី ដូចដែលបានកំណត់ក្នុងតារាងសន្យារបស់ខ្លួនក្នុងឧបសម្ព័ន្ធ ២-ក ក្នុងពេលណាមួយក៏បានប្រសិនបើភាគីម្ខាងនោះមានបំណងធ្វើដូច្នោះ។ ភាគីម្ខាងនោះត្រូវផ្តល់ព័ត៌មានដល់ភាគីម្ខាងមួយទៀតភ្លាមៗ តាមរយៈកំណត់ទូត បន្ទាប់ពីការបញ្ចប់នីតិវិធីផ្ទៃក្នុងសម្រាប់ការចូលជាធរមាននៃវិសោធនកម្មនោះ។

៥. ប្រសិនបើនៅពេលណាមួយ ភាគីម្ខាងបានកាត់បន្ថយនូវអត្រាអនុវត្តនៃពន្ធគយប្រជាជាតិអនុគ្រោះបំផុត (តទៅនេះ ហៅកាត់ថា "MFN") បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន អត្រាពន្ធគយដែលបានកាត់បន្ថយនោះ ត្រូវយកមកអនុវត្តចំពោះការធ្វើពាណិជ្ជកម្មក្រោមកិច្ចព្រមព្រៀងនេះ ក្នុងករណីដែលអត្រាពន្ធគយនោះទាបជាងអត្រាពន្ធគយដែលត្រូវបានគណនាស្របតាមតារាងសន្យារបស់ខ្លួនក្នុងឧបសម្ព័ន្ធ ២-ក។

៦. ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ ភាគីម្ខាងអាច៖

(ក) ដំឡើងពន្ធគយទៅដល់កម្រិតដែលបានដាក់ចេញក្នុងតារាងសន្យារបស់ខ្លួនក្នុងឧបសម្ព័ន្ធ២-ក បន្ទាប់ពីការកាត់បន្ថយ ឬលុបបំបាត់ ជាឯកតោភាគី ឬ

(ខ) រក្សា ឬដំឡើងពន្ធគយ ដូចដែលបានអនុញ្ញាតដោយអង្គភាពដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក។

### មាត្រា២.៥៖ ការកំណត់តម្លៃគិតពន្ធគយ

សម្រាប់គោលបំណងនៃការកំណត់តម្លៃគិតពន្ធគយចំពោះទំនិញដែលបានធ្វើពាណិជ្ជកម្មរវាងគូភាគី បទប្បញ្ញត្តិនៃមាត្រា VII នៃ កិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងបទប្បញ្ញត្តិនៃផ្នែកទី១ និងកំណត់សម្គាល់បកស្រាយក្នុងឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយ *ដែលត្រូវយកមកអនុវត្តដូចគ្នា* ។

### មាត្រា២.៦៖ ការផ្ទេរតារាងសន្យាពន្ធគយ

ភាគីនីមួយៗ ត្រូវធានាថាការផ្ទេរតារាងសន្យាពន្ធគយរបស់ខ្លួនដែលត្រូវបានធ្វើឡើងដើម្បីអនុវត្តឧបសម្ព័ន្ធ ២-ក ក្នុងនាមវលីនៃលេខកូដប្រព័ន្ធសុខដុមនីយកម្មដែលបានកែសម្រួល បន្ទាប់ពីការធ្វើវិសោធនកម្មលើលេខកូដប្រព័ន្ធសុខដុមនីយកម្មតាមកាលកំណត់ នឹងប្រព្រឹត្តទៅដោយមិនប៉ះពាល់ការសន្យាពន្ធគយ ដូចដែលបានកំណត់ក្នុងឧបសម្ព័ន្ធ ២-ក ដោយអនុលោមតាមគោលការណ៍នៃការផ្ទេរដែលបានឯកភាព ដែលនឹងត្រូវអនុម័តដោយគណៈកម្មការ ស្តីពីពាណិជ្ជកម្មទំនិញ។

## ផ្នែក ឃ៖ របបពិសេស

### មាត្រា២.៧៖ ការនាំចូលទំនិញតាមរបបប្រវេសន៍កាលិក

១. ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន ភាគីនីមួយៗ ត្រូវអនុញ្ញាតឱ្យនាំចូលទំនិញក្នុងដែនគយរបស់ខ្លួន ក្រោមលក្ខខណ្ឌរួចផុតពីការបង់ពន្ធនិងអាករទាំងស្រុង ឬភាគខ្លះ ប្រសិនបើទំនិញទាំងនោះត្រូវបាននាំចូលក្នុងគោលបំណងច្បាស់លាស់ ហើយនឹងត្រូវនាំចេញទៅវិញក្នុងកម្រិតពេលវេលាជាក់លាក់មួយ និងមិនត្រូវបានធ្វើការកែច្នៃ ឬផ្លាស់ប្តូរ លើកលែងតែការរំលស់ជាធម្មតា និងការខាតបង់ដោយសារការខ្ជះខ្ជាយ តាមការប្រើប្រាស់។

២. ភាគីនីមួយៗត្រូវពន្យារពេលនៃរយៈពេលកំណត់ដំបូង សម្រាប់ការនាំចូលតាមរបបប្រវេសន៍កាលិកដោយរួចពន្ធ ដូចមានចែងក្នុងកថាខណ្ឌ ១ តាមការស្នើសុំរបស់បុគ្គលដែលពាក់ព័ន្ធ និងជាមួយហេតុផលដែលរដ្ឋបាលគយរបស់ខ្លួនចាត់ទុកថាសមស្រប។

៣. មិនមានភាគីណាមួយត្រូវដាក់លក្ខខណ្ឌក្នុងការនាំចូលទំនិញតាមរបបប្រវេសន៍កាលិកដែលមានចែងក្នុងកថាខណ្ឌ ១ ក្រៅពីតម្រូវឱ្យទំនិញនោះ៖

(ក) ត្រូវបានប្រើតែឯង ឬក្រោមការត្រួតពិនិត្យផ្ទាល់ខ្លួនរបស់ជនជាតិ ឬនិវេសនជន របស់ភាគីម្ខាងទៀត សម្រាប់ធ្វើសកម្មភាពអាជីវកម្ម ពាណិជ្ជកម្ម វិជ្ជាជីវៈ ឬកីឡារបស់បុគ្គលនោះ

(ខ) មិនត្រូវបានលក់ ឬជួលឱ្យគេនៅលើទឹកដីរបស់ខ្លួន

(គ) ត្រូវតម្កល់និមុត្តិធានា ក្នុងចំនួនមួយដែលមិនលើសពីពន្ធគយ អាករ កម្រៃនិងបន្ទុកផ្សេងៗដែលនឹងត្រូវដាក់តម្កល់នៅពេលនាំចូល ឬការនាំចូលចុងក្រោយ ដែលអាចនឹងបង្វែរសងវិញ បាននៅពេលធ្វើការនាំចេញទំនិញទៅវិញ

(ឃ) អាចកំណត់អត្តសញ្ញាណបាន នៅពេលនាំចូល និងនាំចេញ

(ង) ត្រូវនាំចេញទៅវិញតាមការត្រឡប់ទៅវិញ របស់បុគ្គលដូចមានមានចែងក្នុងវាក្យខណ្ឌ (ក) ឬក្នុងរយៈពេលផ្សេងទៀតទៅតាមគោលបំណងនៃការនាំចូល តាមរបបប្រវេសន៍កាលិក ដែលភាគីម្ខាងនោះបានកំណត់ លើកលែងតែមានការពន្យារពេល

(ច) ត្រូវបានអនុញ្ញាតក្នុងបរិមាណមិនលើសពីបរិមាណសមស្របសម្រាប់ការប្រើប្រាស់ណាមួយ និង

(ឆ) បើមិនដូច្នេះទេ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងដែនដីរបស់ភាគីម្ខាង តាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

៤. ប្រសិនបើមានលក្ខខណ្ឌណាមួយដែលភាគីម្ខាង ដាក់ចេញក្រោមកថាខណ្ឌ ៣ មិនត្រូវបានបំពេញ ភាគីម្ខាងនោះអាចអនុវត្តពន្ធគយ និងបន្ទុកផ្សេងៗ ដែលជាធម្មតាត្រូវបានដាក់បន្ថែមពីលើបន្ទុកផ្សេងៗទៀតចំពោះទំនិញនោះ ឬការផាកពិន័យណាមួយដែលមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

៥. ភាគីនីមួយៗ ត្រូវអនុញ្ញាតឱ្យទំនិញដែលត្រូវបាននាំចូលតាមរបបប្រវេសន៍កាលិក ដូចមានចែងក្នុងមាត្រានេះ នាំចេញទៅវិញ តាមកំពង់ផែគយណាមួយ ក្រៅពីកំពង់ផែដែលទំនិញត្រូវបានអនុញ្ញាតឱ្យនាំចូល។

## មាត្រា២.៨៖ ការនាំចូលដោយមិនបង់ពន្ធលើគំរូពាណិជ្ជកម្មដែលមានតម្លៃតិចតួច

ភាគីនីមួយៗ ត្រូវអនុញ្ញាតឱ្យនាំចូលដោយរួចពន្ធចំពោះគំរូពាណិជ្ជកម្មដែលមានតម្លៃតិចតួច ដែលត្រូវបាននាំចូលពីដែនដីនៃភាគីម្ខាងទៀត ដោយមិនគិតពីដើមកំណើត ប៉ុន្តែអាចតម្រូវឱ្យគំរូនោះត្រូវបាននាំចូលសម្រាប់តែជាព័ត៌មានក្នុងការបញ្ជាទិញទំនិញ ឬសេវាកម្ម ដែលបានផ្តល់ឱ្យពីដែនដីនៃភាគីម្ខាងទៀត ឬប្រទេសមិនមែនភាគីម្ខាងនោះ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

# ផ្នែក ខ៖ វិធានការមិនមែនពន្ធគយ

## មាត្រា២.៩៖ ការអនុវត្តវិធានការមិនមែនពន្ធគយ

១. ភាគីម្ខាងមិនត្រូវអនុវត្ត ឬបន្តរក្សាវិធានការមិនមែនពន្ធគយ លើការនាំចូលទំនិញណាមួយរបស់ភាគីម្ខាងទៀត ឬលើការនាំចេញទំនិញទៅកាន់ ដែនដីនៃភាគីម្ខាងទៀតឡើយ លើកលែងតែអនុលោមតាមសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ឬក្រោមកិច្ចព្រមព្រៀងនេះ។

២. ភាគីនីមួយៗ ត្រូវធានាឱ្យមានតម្លាភាពនៃវិធានការមិនមែនពន្ធគយរបស់ខ្លួន ដែលត្រូវបានអនុញ្ញាតនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ហើយត្រូវធានាថា វិធានការទាំងនោះមិនត្រូវបានរៀបចំ អនុម័ត ឬអនុវត្ត ដោយមានបំណង ឬផលប៉ះពាល់ ក្នុងការបង្កើតឧបសគ្គមិនចាំបាច់ចំពោះពាណិជ្ជកម្មរវាងគូភាគី។

## មាត្រា២.១០៖ ការរឹតត្បិតការនាំចេញ និងការនាំចូល

១. លើកលែងតែមានចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ មិនមានភាគីណាមួយត្រូវអនុវត្ត ឬបន្តរក្សាការហាមឃាត់ ឬការរឹតត្បិតលើការនាំចូលទំនិញណាមួយរបស់ភាគីម្ខាងទៀត ឬលើការនាំចេញ

ឬការលក់សម្រាប់ការនាំចេញទំនិញណាមួយ ទៅកាន់ដែនដីរបស់ភាគីម្ខាងទៀតឡើយ លើកលែងតែអនុលោមតាមមាត្រា XI នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងកំណត់សម្គាល់បកស្រាយ ហើយក្នុងគោលបំណងនេះ មាត្រា XI នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងកំណត់សម្គាល់បកស្រាយ ត្រូវបានបញ្ចូលជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ *ដែលត្រូវយកមកអនុវត្តដូចគ្នា*។

២. នៅពេលដែលភាគីម្ខាងស្នើសុំដាក់ចេញនូវការហាមឃាត់ឬការដាក់កម្រិតលើការនាំចូល ឬការនាំចេញ គ្រឿងឧបភោគបរិភោគ ឬផលិតផលផ្សេងទៀត អនុលោមតាមកថាខណ្ឌ២ នៃមាត្រា XI នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ភាគីម្ខាងនោះត្រូវ៖

(ក) ជូនដំណឹងជាលាយលក្ខណ៍អក្សរតាមលទ្ធភាពដែលអាចធ្វើទៅបាន មុនពេលការហាមឃាត់ ឬការដាក់កម្រិតដែលបានស្នើចូលជាធរមាន និង

(ខ) ផ្តល់ជូនភាគីម្ខាងទៀតនូវឱកាសគ្រប់គ្រាន់ សម្រាប់ការពិគ្រោះយោបល់ទាក់ទងនឹងបញ្ហាដែលទាក់ទងនឹងការហាមឃាត់ឬការដាក់កម្រិតដែលបានស្នើតាមរយៈយន្តការសមស្រប ដែលអាចរួមបញ្ចូលទាំងអនុគណៈកម្មការ ឬក្រុមការងារដែលត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការចម្រុះ។

## មាត្រា២.១១៖ ការពិគ្រោះយោបល់បច្ចេកទេស ស្តីពីវិធានការមិនមែនពន្ធគយ

១. ភាគីម្ខាងអាចស្នើសុំការពិគ្រោះយោបល់បច្ចេកទេសជាមួយភាគីម្ខាងទៀត (តទៅនេះ ហៅកាត់ថា "ភាគីដែលត្រូវបានស្នើសុំ") ចំពោះវិធានការដែលភាគីម្ខាងចាត់ទុកថាធ្វើឱ្យមានការប៉ះពាល់ដល់ពាណិជ្ជកម្មរបស់ខ្លួន។ សំណើនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវកំណត់ពីវិធានការ និងបញ្ហាឱ្យច្បាស់ ក៏ដូចជាអំពីរបៀបដែលវិធានការនេះជះឥទ្ធិពលយ៉ាង ធ្ងន់ធ្ងរដល់ពាណិជ្ជកម្មរវាងភាគីស្នើសុំការពិគ្រោះយោបល់បច្ចេកទេស (តទៅនេះ ហៅកាត់ថា "ភាគីស្នើសុំ") និងភាគីដែលត្រូវបានស្នើសុំ។

២. នៅពេលដែលវិធានការត្រូវបានចែងក្រោមជំពូកមួយផ្សេងទៀត យន្តការពិគ្រោះយោបល់តាមជំពូកដាក់លាក់នោះ នឹងត្រូវបានប្រើប្រាស់ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះរវាងគូភាគី។

៣. លើកលែងតែមានចែងក្នុងកថាខណ្ឌ ២ ភាគីដែលត្រូវបានស្នើសុំត្រូវឆ្លើយតប និងចូលរួមការពិគ្រោះយោបល់បច្ចេកទេសក្នុងរយៈពេល ៦០ថ្ងៃ ចាប់ពីពេលទទួលបានសំណើជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងកថាខណ្ឌ ១ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយគូភាគី ក្នុងគោលបំណងដើម្បីឈានរកដំណោះស្រាយដែលទទួលបានការពេញចិត្តទៅវិញទៅមក ក្នុងរយៈពេល ១៨០ថ្ងៃ គិតចាប់ពីពេលស្នើសុំ។ ការពិគ្រោះយោបល់បច្ចេកទេសអាចត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយណាមួយដែលបានព្រមព្រៀងគ្នាដោយគូភាគី។

៤. ប្រសិនបើភាគីស្នើសុំយល់ឃើញថាបញ្ហានេះជារឿងបន្ទាន់ ឬពាក់ព័ន្ធនឹងទំនិញងាយខូចគុណភាព ការពិគ្រោះយោបល់បច្ចេកទេសអាចធ្វើឡើងក្នុងរយៈពេលខ្លីជាងអ្វីដែលបានចែងក្នុងកថាខណ្ឌ៣។

៥. ការពិគ្រោះយោបល់បច្ចេកទេសក្រោមមាត្រានេះនឹងមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងនីតិវិធីដោះស្រាយវិវាទដូចមានចែងក្នុងជំពូកទី ៨ (ការដោះស្រាយវិវាទ) និងកិច្ចព្រមព្រៀងនានារបស់អង្គការពាណិជ្ជកម្មពិភពលោកឡើយ។

## មាត្រា២.១២៖ ការផ្តល់អាជ្ញាប័ណ្ណនាំចូល

១. ភាគីនីមួយៗត្រូវធានាថា រាល់នីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណនាំចូលដោយស្វ័យប្រវត្តិ និងមិនស្វ័យប្រវត្តិ ត្រូវបានអនុវត្តប្រកបដោយតម្លាភាព និងភាពអាចព្យាករណ៍បាន ហើយអនុលោមតាមកិច្ចព្រមព្រៀង ស្តីពីនីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូល ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ១-ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (តទៅនេះ ហៅកាត់ថា "កិច្ចព្រមព្រៀង ស្តីពីអាជ្ញាប័ណ្ណនាំចូល")។ មិនមានភាគីណាមួយត្រូវអនុវត្ត ឬរក្សាវិធានការណាមួយដែលមិនមានសង្គតិភាពទៅនឹងកិច្ចព្រមព្រៀង ស្តីពីអាជ្ញាប័ណ្ណនាំចូលឡើយ។

២. ភ្លាមៗបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ភាគីនីមួយៗត្រូវជូនដំណឹងទៅភាគីម្ខាងទៀតអំពីនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណនាំចូលដែលមានស្រាប់របស់ខ្លួន ប្រសិនបើមាន។ ការជូនដំណឹងត្រូវ៖

(ក) រួមបញ្ចូលព័ត៌មានដែលបានបញ្ជាក់នៅក្នុងមាត្រា ៥ នៃកិច្ចព្រមព្រៀង ស្តីពីអាជ្ញាប័ណ្ណនាំចូល និង

(ខ) មិនត្រូវរើសអើងថា នីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណនាំចូល មាន ឬមិនមានសង្គតិភាពនឹងកិច្ចព្រមព្រៀងនេះ។

៣. មុនពេលអនុវត្តនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណនាំចូលថ្មី ឬដែលត្រូវបានកែប្រែ ភាគីត្រូវផ្សព្វផ្សាយនីតិវិធី ឬការកែប្រែថ្មី នៅលើគេហទំព័រអ៊ិនធើណិតផ្លូវការរបស់រដ្ឋាភិបាល។ ភាគីនោះត្រូវផ្សព្វផ្សាយតាមលទ្ធភាពដែលអាចធ្វើទៅបាន យ៉ាងតិច ២១ថ្ងៃ មុនពេលនីតិវិធីថ្មី ឬការផ្លាស់ប្តូរនៃនីតិវិធីចូលជាធរមាន។

៤. មិនមានភាគីណាមួយត្រូវអនុវត្តនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណនាំចូលចំពោះទំនិញរបស់ភាគីម្ខាងទៀតឡើយ ប្រសិនបើភាគីនោះបានអនុវត្ត តាមតម្រូវការនៃកថាខណ្ឌ២ និង ៣ ទាក់ទងនឹងនីតិវិធីនោះ។

## មាត្រា២.១៣៖ កម្រៃ និងបែបបទទាក់ទងនឹងការនាំចូលនិងការនាំចេញ

១. ភាគីនីមួយៗត្រូវធានាថា ដោយអនុលោមតាមមាត្រា VIII:1 នៃ កិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ កម្រៃ និងបន្ទុកទាំងអស់ (ក្រៅពីពន្ធនាំចូល ឬអាករនាំចេញ ថ្លៃសមមូលនឹងពន្ធក្នុងស្រុក ឬថ្លៃសេវាក្នុងស្រុកផ្សេងទៀតដែលអនុវត្តអនុលោមតាមមាត្រា III:2 នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ព្រមទាំងពន្ធប្រឆាំងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ) ដែលត្រូវដាក់លើ ឬទាក់ទងនឹងការនាំចូល ឬការនាំចេញ ត្រូវកំណត់ក្នុងចំនួនទឹកប្រាក់ប្រហាក់ប្រហែលនឹងតម្លៃសេវាកម្មដែលបានផ្តល់ ហើយមិនបង្ហាញពីការការពារដោយប្រយោលចំពោះទំនិញក្នុងស្រុក ឬការយកពន្ធលើការនាំចូល ឬការនាំចេញសម្រាប់គោលបំណងសារពើពន្ធ។

២. ភាគីនីមួយៗត្រូវផ្សព្វផ្សាយព័ត៌មានលម្អិតអំពីកម្រៃ និងបន្ទុកនានាដែលពាក់ព័ន្ធនឹងការនាំចូល ឬការនាំចេញឱ្យបានឆាប់រហ័ស ហើយត្រូវផ្សព្វផ្សាយព័ត៌មានទាំងនោះតាមប្រព័ន្ធអ៊ីនធឺណែត។

៣. មិនមានភាគីណាមួយទាមទារឱ្យមានប្រតិបត្តិការតាមរយៈកុងស៊ុល រួមទាំងកម្រៃ និងបន្ទុកផ្សេងទៀតដែលទាក់ទងនឹងការនាំចូលទំនិញរបស់ភាគីម្ខាងទៀតទេ។ មិនមានភាគីណាមួយទាមទារថា ឯកសារសម្រាប់ការធ្វើបែបបទគយនានា ដែលត្រូវបានផ្តល់ទាក់ទងនឹងការនាំចូលទំនិញរបស់ភាគីម្ខាងទៀត ត្រូវមានការយល់ព្រម បញ្ជាក់ ពិនិត្យ ឬអនុម័តដោយតំណាងនៅក្រៅប្រទេសរបស់ភាគីជាប្រទេសនាំចូល ឬបុគ្គល ឬអង្គភាពមានសមត្ថកិច្ច ក្នុងការធ្វើសកម្មភាពក្នុងនាមភាគីជាប្រទេសនាំចូលឡើយ ឬមិនត្រូវដាក់បន្ទុកកម្រៃ ឬបន្ទុកណាមួយឡើយ។

## មាត្រា២.១៤៖ សហគ្រាសពាណិជ្ជកម្មរបស់រដ្ឋ

សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីទាក់ទងនឹងសហគ្រាសពាណិជ្ជកម្មរបស់រដ្ឋ ត្រូវអនុលោមតាមមាត្រា XVII នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ កំណត់សម្គាល់បកស្រាយ និងការពន្យល់ ស្តីពីការបកស្រាយមាត្រា XVII នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ដែលត្រូវបានបញ្ចូលជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ *ត្រូវយកមកអនុវត្តដូចគ្នា* ។

## មាត្រា២.១៥៖ វិធានការអនាម័យនិងភូតគាមអនាម័យ

១. មាត្រានេះមានគោលបំណង ដើម្បីការពារជីវិតមនុស្ស សត្វ ឬរុក្ខជាតិ ឬសុខភាពនៅក្នុងដែនដីរបស់ភាគី ទន្ទឹមនឹងការសម្រួលពាណិជ្ជកម្ម តាមរយៈការកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អវិជ្ជមានលើពាណិជ្ជកម្មរវាងគូភាគី។

២. មាត្រានេះត្រូវអនុវត្តចំពោះរាល់វិធានការអនាម័យនិងភូតគាមអនាម័យ (តទៅនេះ ហៅកាត់ថា "SPS") របស់គូភាគី ដែលអាចប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ពាណិជ្ជកម្មរវាងគូភាគី ដោយពិចារណាលើនិយមន័យដូចមានចែងក្នុងឧបសម្ព័ន្ធ ក នៃកិច្ចព្រមព្រៀង ស្តីពីការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យ ដូចមានចែងក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (តទៅនេះ ហៅកាត់ថា "កិច្ចព្រមព្រៀង SPS") ។

៣. គូភាគីបញ្ជាក់សារជាថ្មីពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ចំពោះគ្នាទៅវិញទៅមកក្រោមកិច្ចព្រមព្រៀង SPS ដោយពិចារណាលើសេចក្តីសម្រេចរបស់គណៈកម្មាធិការ SPS របស់អង្គការពាណិជ្ជកម្មពិភពលោក និងស្តង់ដារអន្តរជាតិ គោលការណ៍ណែនាំ និងអនុសាសន៍នានា។

៤. ភាគីនាំចេញត្រូវផ្តល់ព័ត៌មានសមស្របឱ្យបានទាន់ពេលវេលាដល់ភាគី នាំចូល នៅពេលមានការផ្លាស់ប្តូរសំខាន់ទាក់ទងនឹងស្ថានភាពសុខភាពសត្វ ឬរុក្ខជាតិ ឬបញ្ហាសុវត្ថិភាពចំណីអាហារនៅក្នុងភាគីនាំចេញ ដែលអាចប៉ះពាល់ដល់ពាណិជ្ជកម្ម។

៥. គូភាគីត្រូវផ្លាស់ប្តូរព័ត៌មានលើបញ្ហា SPS ដែលជាផលប្រយោជន៍រួម ក្រោមមាត្រានេះ និងពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេស ការកសាងសមត្ថភាព និងការពិគ្រោះយោបល់ បើសិនមានការស្នើសុំ។

៦. ក្នុងគោលបំណងសម្រួលដល់ការអនុវត្ត និងការប្រាស្រ័យទាក់ទងលើបញ្ហា SPS នៃមាត្រានេះ គូភាគីត្រូវកំណត់ចំណុចទំនាក់ទំនងដូចខាងក្រោម៖

(ក) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ភាគីកម្ពុជា និង

(ខ) ក្រសួងកសិកម្ម ចំណីអាហារ និងកិច្ចការជនបទ សម្រាប់ភាគីកូរ៉េ

ឬស្ថាប័នបន្តវេនរៀងៗខ្លួន។

៧. មិនមានភាគីណាមួយត្រូវប្រើប្រាស់ជំពូកទី ៨ (ការដោះស្រាយវិវាទ) សម្រាប់បញ្ហាទាំងឡាយណាដែលកើតឡើងក្រោមមាត្រានេះឡើយ។

**មាត្រា២.១៦៖ បទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារ និងនីតិវិធីវាយតម្លៃភាពអនុលោម**

១. គូភាគីបញ្ជាក់ជាថ្មីអំពីសិទ្ធិ និងកាតព្វកិច្ចដែលមានស្រាប់របស់ភាគីនីមួយៗ ក្រោមកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (TBT) ដែលមាននៅក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (តទៅនេះ ហៅកាត់ថាកិច្ចព្រមព្រៀង TBT)។

២. គូភាគីទទួលស្គាល់ពីសារៈសំខាន់នៃមាត្រាពាក់ព័ន្ធនឹងតម្លាភាពក្នុងកិច្ចព្រមព្រៀង TBT ។ នៅក្នុងន័យនេះ គូភាគីត្រូវពិចារណាលើសេចក្តីសម្រេច និងអនុសាសន៍នានាពាក់ព័ន្ធ ដែលបានអនុម័តដោយគណៈកម្មាការ ស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម របស់អង្គការពាណិជ្ជកម្មពិភពលោកចាប់តាំងថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៥ (G/TBT/1/Rev.14) ដែលបានកែសម្រួល និងដាក់ចេញដោយគណៈកម្មាការស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក។

៣. គូភាគីយល់ព្រមប្រើប្រាស់ស្តង់ដារអន្តរជាតិពាក់ព័ន្ធធ្វើជាមូលដ្ឋានសម្រាប់បទប្បញ្ញត្តិបច្ចេកទេស និងដើម្បីធានាថា ស្ថាប័នរដ្ឋាភិបាលកណ្តាលប្រើប្រាស់ស្តង់ដារអន្តរជាតិពាក់ព័ន្ធ ឬផ្នែកពាក់ព័ន្ធរបស់ស្តង់ដារទាំងនោះធ្វើជាមូលដ្ឋាន សម្រាប់ជានីតិវិធីវាយតម្លៃភាពអនុលោមរបស់ខ្លួន លើកលែងតែត្រូវបានពន្យល់លម្អិតតាមសំណើថា ស្តង់ដារអន្តរជាតិ ឬផ្នែកពាក់ព័ន្ធ មិនមានប្រសិទ្ធភាព ឬ មិនសមស្របសម្រាប់បំពេញគោលបំណងស្របច្បាប់ដូចមានចែងក្នុងមាត្រា ២.៤ និង ៥.៤ នីមួយៗរៀងខ្លួននៃកិច្ចព្រមព្រៀង TBT។

៤. ក្នុងការកំណត់ថាតើស្តង់ដារអន្តរជាតិ គោលការណ៍ណែនាំ ឬអនុសាសន៍ ស្ថិតក្នុងវិសាលភាពអត្ថន័យនៃមាត្រា ២ និង ៥ និងឧបសម្ព័ន្ធ ៣ នៃកិច្ចព្រមព្រៀង TBT ដែលមានស្រាប់ដែរឬទេ ភាគីនីមួយៗ ត្រូវអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាការ ស្តីពីគោលការណ៍សម្រាប់ការអភិវឌ្ឍស្តង់ដារអន្តរជាតិ គោលការណ៍ណែនាំ និងអនុសាសន៍នានា ពាក់ព័ន្ធនឹងមាត្រា ២ និង ៥ និងឧបសម្ព័ន្ធ ៣ នៃកិច្ចព្រមព្រៀងដែលបានអនុម័តនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដោយគណៈកម្មាការ ស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម របស់អង្គការពាណិជ្ជកម្មពិភពលោក (ឧបសម្ព័ន្ធ ២ ផ្នែក ១ នៃ G/TBT/1/Rev.14) និងការអភិវឌ្ឍបន្តបន្ទាប់ទៅមុខទៀត។ ស្តង់ដារអន្តរជាតិទាំងនោះ ត្រូវរួមបញ្ចូលនូវកម្មវត្ថុផ្សេងទៀតក្នុងចំណោម ប៉ុន្តែមិនត្រូវបានកំណត់ត្រឹមតែស្តង់ដារដែលត្រូវបានរៀបចំឡើង ដោយអង្គការអន្តរជាតិសម្រាប់ស្តង់ដារូបនីយកម្ម (ISO) គណៈកម្មការអេឡិចត្រូនិកអន្តរជាតិ (IEC) សហព័ន្ធទូរគមនាគមន៍អន្តរជាតិ (ITU) និង គណៈកម្មការកូដិច Codex Alimentarius (CAC) នោះឡើយ។

៥. នៅពេលដែលភាគីម្ខាងឃាត់ទុកទំនិញនៅច្រកនាំចូល ដោយរួមទាំងគំរូសំណាកសម្រាប់ ធ្វើតេស្តវាយតម្លៃភាពអនុលោមដែលបាននាំចេញពីភាគីម្ខាងទៀតដោយសារបានដឹងជាមុនថាទំនិញនោះមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសឬនីតិវិធីវាយតម្លៃភាពអនុលោម ត្រូវតែជូនដំណឹងភ្លាមៗដល់អ្នកនាំចូលឬតំណាងរបស់ពួកគេពីហេតុផលនៃការឃាត់ទុកទាំងនោះ។

៦. ភាគីនីមួយៗត្រូវកំណត់ចំណុចទាក់ទងដែលត្រូវធ្វើការរួមគ្នាក្នុងការសម្របសម្រួលការអនុវត្តនៃមាត្រានេះ និងការប្រាស្រ័យទាក់ទងលើបញ្ហានៃរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ដែលបានកើតចេញពីការអនុវត្តកិច្ចព្រមព្រៀងនេះ។ ចំណុចទំនាក់ទំនងទាំងនេះគឺ៖

(ក) វិទ្យាស្ថានស្តង់ដារកម្ពុជា សម្រាប់ភាគីកម្ពុជា និង

(ខ) ភ្នាក់ងារកូរ៉េសម្រាប់បច្ចេកវិទ្យានិងស្តង់ដារ សម្រាប់ភាគីកូរ៉េ

ឬស្ថាប័នបន្តវេនរៀងៗខ្លួន។

## ផ្នែក ចៈ បទប្បញ្ញត្តិនៃការរៀបចំស្ថាប័ន

### មាត្រា២.១៧៖ គណៈកម្មការ ស្តីពីពាណិជ្ជកម្មទំនិញ

១. សម្រាប់គោលបំណងនៃការអនុវត្ត និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្រោមជំពូកនេះ និងជំពូកទី៥ (ឧបាស្រ័យពាណិជ្ជកម្ម) គូភាគីសម្រេចបង្កើតគណៈកម្មការ ស្តីពីពាណិជ្ជកម្មទំនិញដែលមានតំណាងចូលរួមរបស់គូភាគី។

២. គណៈកម្មការ ស្តីពីពាណិជ្ជកម្មទំនិញ ត្រូវជួបប្រជុំតាមការស្នើសុំរបស់ភាគីម្ខាង ឬគណៈកម្មាធិការចម្រុះ តាមការឯកភាពគ្នាលើពេលវេលា ទីកន្លែង និងមធ្យោបាយ ដើម្បីពិចារណាលើបញ្ហាដែលបានលេចឡើងក្រោមជំពូកនេះ និងជំពូកទី ៥ (ឧបាស្រ័យពាណិជ្ជកម្ម)។

៣. មុខងារនៃគណៈកម្មការ ស្តីពីពាណិជ្ជកម្មទំនិញ ត្រូវរួមបញ្ចូល៖

(ក) ពិនិត្យឡើងវិញ និងតាមដានការត្រួតពិនិត្យលើការអនុវត្តនិងប្រតិបត្តិនៃជំពូកនេះ និងជំពូកទី៥ (ឧបាស្រ័យពាណិជ្ជកម្ម) និងរៀបចំរបាយការណ៍ និងអនុសាសន៍ ក្នុងករណីសមស្រប។

(ខ) លើកកម្ពស់ការធ្វើពាណិជ្ជកម្មទំនិញរវាងគូភាគី រួមបញ្ចូលទាំងកិច្ចពិភាក្សា ស្តីពីការពន្លឿនការកាត់បន្ថយឬលុបបំបាត់ពន្ធគយក្រោមកិច្ចព្រមព្រៀងនេះ និងបញ្ហាដទៃទៀតតាមភាពសមស្រប។

(គ) ដោះស្រាយរបាំងចំពោះការធ្វើពាណិជ្ជកម្មទំនិញរវាងគូភាគី ជាពិសេសបញ្ហាដែលពាក់ព័ន្ធនឹងការអនុវត្តវិធានការមិនមែនពន្ធគយ និងក្នុងករណីសមស្រប បញ្ជូនបញ្ហាទាំងនោះទៅគណៈកម្មាធិការចម្រុះ ដើម្បីពិចារណា។

(ឃ) ដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងវិធានការ ក្នុងការធ្វើបច្ចុប្បន្នភាពតារាងសន្យាពន្ធគយរបស់ភាគីនីមួយៗ ដើម្បីរំលេចនូវវិសោធនកម្មនៃប្រព័ន្ធសុខុមនីយកម្ម ដែលរួមបញ្ចូលការអនុម័តនិងពិនិត្យឡើងវិញនូវគោលការណ៍ណែនាំការផ្ទេរតារាងសន្យាពន្ធគយ ការផ្ទេរតារាងសន្យាពន្ធគយរបស់ភាគីនីមួយៗ និងការផ្លាស់ប្តូរតារាងសន្យាពន្ធគយដែលបាន

ផ្ទេរតោរាងសន្យាពន្ធគយរួចហើយ និងតារាងទំនាក់ទំនងនៃការផ្ទេរតារាង សន្យាពន្ធគយឱ្យបានទាន់ពេលវេលា។

(ង) ពិភាក្សាលើបញ្ហាដែលលេចឡើងក្រោមជំពូកនេះ និងជំពូកទី ៥ (ឧបាស្រ័យពាណិជ្ជកម្ម) ដូចដែលបានឯកភាព។

(ច) កំណត់ចំណុចទំនាក់ទំនង តាមការស្នើសុំរបស់ភាគីណាមួយ ដែលសម្របសម្រួលទំនាក់ទំនងលើបញ្ហាជាក់លាក់ណាមួយដែលបានលេចឡើងពីជំពូកនេះ និងជំពូកទី៥ (ឧបាស្រ័យពាណិជ្ជកម្ម)។

# ជំពូកទី៣
# វិធានដើមកំណើត
# ផ្នែក ក៖ វិធានដើមកំណើត

**មាត្រា៣.១៖ និយមន័យ**

សម្រាប់គោលបំណងនៃជំពូកនេះ៖

**ថ្លៃទំនិញ រួមនឹងថ្លៃធានារ៉ាប់រង និងថ្លៃដឹកជញ្ជូន** (CIF) សំដៅដល់ថ្លៃនៃទំនិញនាំចូល រួមទាំងថ្លៃដឹកជញ្ជូន និងការធានារ៉ាប់រងដល់កំពង់ផែ ឬមាត់ច្រកចូលទៅកាន់ប្រទេសនាំចូល។

**អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់អាជ្ញាធររដ្ឋាភិបាល ឬអាជ្ញាធរដែលត្រូវបានចាត់តាំងដោយភាគីម្ខាង និងត្រូវបានជូនដំណឹងទៅភាគីម្ខាងទៀត។

**អ្នកនាំចេញ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្ថិតក្នុងដែនដីនៃភាគីម្ខាងដែលទំនិញត្រូវបាននាំចេញដោយរូបវន្តបុគ្គល ឬនីតិបុគ្គលនោះ។

**ថ្លៃទំនិញដឹកជញ្ជូនដល់លើនាវា** (FOB) សំដៅដល់តម្លៃនៃទំនិញដែលដឹកជញ្ជូនមកដល់លើនាវា រួមបញ្ចូលទាំងចំណាយនៃការដឹកជញ្ជូនទំនិញពីផលិតករទៅកាន់កំពង់ផែ ឬទីកន្លែងដឹកជញ្ជូនចុងក្រោយបំផុតនៅក្រៅប្រទេស។

**គោលការណ៍គណនេយ្យទទួលស្គាល់ទូទៅ** (GAAP) សំដៅដល់គោលការណ៍ទាំងឡាយដែលមានការទទួលស្គាល់ជាទូទៅ ឬទទួលស្គាល់ភាគច្រើនដោយភាគីណាមួយពាក់ព័ន្ធនឹងការកត់ត្រាចំណូល ចំណាយថ្លៃដើម ទ្រព្យសកម្ម និងបំណុល ការលាតត្រដាងព័ត៌មាន និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ គោលការណ៍ទាំងនេះអាចរាប់បញ្ចូលទាំងគោលការណ៍ណែនាំទូលំទូលាយនៃការអនុវត្តទូទៅ រួមទាំងស្តង់ដារ ការអនុវត្ត និងនីតិវិធីលម្អិតផ្សេងៗ។

**ទំនិញ** ត្រូវរាប់បញ្ចូលទាំងវត្ថុធាតុ ឬផលិតផល ដែលអាចប្រមូលផល ឬផលិតបានទាំងស្រុងបើទោះបីជា វត្ថុធាតុ ឬទំនិញទាំងនោះ ត្រូវបានបម្រុងទុកសម្រាប់ប្រើជាវត្ថុធាតុនៅក្នុងដំណើរការផលិតកម្មផ្សេងទៀតក៏ដោយ។ សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យ "ទំនិញ (goods)" និង "ផលិតផល (products)" អាចត្រូវបានប្រើប្រាស់ជំនួសគ្នាបាន ហើយពាក្យ "ទំនិញ (good)" និង "ផលិតផល (product)" ត្រូវបកស្រាយតាមន័យខាងលើ។

**ប្រព័ន្ធសុខដុមនីយកម្ម** ត្រូវមាននិយមន័យដូចមានចែងក្នុងមាត្រា១.១ (និយមន័យទូទៅ)។
**អ្នកនាំចូល** សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្ថិតក្នុងដែនដីនៃភាគីម្ខាងដែលទំនិញត្រូវបាននាំចូលដោយរូបវន្តបុគ្គល ឬនីតិបុគ្គលនោះ។

**ស្ថាប័នចេញវិញ្ញាបនបត្រ** សំដៅដល់អង្គភាពដែលត្រូវបានចាត់តាំង ឬទទួលបានការផ្តល់សិទ្ធិដោយភាគីម្ខាង ក្នុងការចេញវិញ្ញាបនបត្រដើមកំណើត និងត្រូវជូនដំណឹងទៅភាគីម្ខាងទៀតដោយអនុលោមតាមជំពូកនេះ។

**ទំនិញ ឬវត្ថុធាតុដែលអាចជំនួសគ្នា** សំដៅដល់ទំនិញ ឬវត្ថុធាតុ ដែលអាចផ្លាស់ប្តូរគ្នាបានសម្រាប់គោលបំណងពាណិជ្ជកម្ម ហើយមានលក្ខណៈសំខាន់ប្រហាក់ប្រហែលគ្នា។

**វត្ថុធាតុ** ត្រូវរាប់បញ្ចូលទាំងគ្រឿងផ្សំ វត្ថុធាតុដើម ផ្នែក សមាសភាគ បង្គុំ ដែលត្រូវបានប្រើប្រាស់ក្នុងផលិតកម្ម។

**ទំនិញមិនមានដើមកំណើត ឬវត្ថុធាតុមិនមានដើមកំណើត** សំដៅដល់ទំនិញ ឬវត្ថុធាតុដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ថាមានដើមកំណើត ដោយអនុលោមតាមជំពូកនេះ។

**ទំនិញមានដើមកំណើត** ត្រូវមាននិយមន័យដូចមានចែងក្នុងមាត្រា១.១ (និយមន័យទូទៅ)។

**វត្ថុធាតុវេចខ្ចប់ និងកុងតឺន័រសម្រាប់ដឹកជញ្ជូន** សំដៅដល់ទំនិញដែលត្រូវបានប្រើប្រាស់ដើម្បីការពារទំនិញក្នុងអំឡុងពេលដឹកជញ្ជូន ខុសពីវត្ថុធាតុឬកុងតឺន័រទាំងឡាយណាដែលត្រូវបានប្រើសម្រាប់ការលក់រាយ។

**ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ** សំដៅដល់សម្បទានពន្ធដែលត្រូវបានផ្តល់ឱ្យចំពោះទំនិញដែលមានដើមកំណើត ដូចបានកំណត់ដោយអត្រាពន្ធគយដែលអាចអនុវត្តទៅបាន នៅក្រោមកិច្ចព្រមព្រៀងនេះ។

**វិធានជាក់លាក់សម្រាប់ផលិតផល** សំដៅដល់វិធាននានាដែលបញ្ជាក់ថា វត្ថុធាតុបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ ឬកម្មន្តសាលជាក់លាក់ ឬប្រតិបត្តិការនៃដំណើរការ ឬការបំពេញលក្ខណៈគ្រប់គ្រាន់នៃសមាសធាតុតម្លៃតំបន់ ឬការរួមបញ្ចូលគ្នានៃលក្ខណៈវិនិច្ឆ័យណាមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងនេះ។

**ផលិតករ** សំដៅដល់បុគ្គលដែលបានចូលរួមក្នុងផលិតកម្មនៃទំនិញ។

**ផលិតកម្ម** សំដៅដល់វិធីសាស្ត្រក្នុងការទទួលបានទំនិញ រាប់បញ្ចូលទាំង ការដាំដុះ ការជីករ៉ែ ការប្រមូលផល ការចិញ្ចឹម ការបង្កាត់ពូជ ការចម្រាញ់ចេញ ការប្រមូលផ្តុំ ការប្រមូលយក ការចាប់យក ការនេសាទ ការដាក់អន្ទាក់ ការប្រមាញ់ កម្មន្តសាល ការផលិត ការកែច្នៃ ឬការតម្លើង/ផ្គុំទំនិញ និង

**ប្រទេសទីបី** សំដៅដល់ប្រទេសដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា៣.២៖ លក្ខណៈវិនិច្ឆ័យដើមកំណើត

១. សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ទំនិញមួយដែលត្រូវបាននាំចូលក្នុងដែនដីនៃភាគីម្ខាង ត្រូវបានចាត់ទុកថាជាទំនិញមានដើមកំណើត និងអាចទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ប្រសិនបើទំនិញនោះអនុលោមតាមលក្ខខណ្ឌតម្រូវដើមកំណើតណាមួយដូចខាងក្រោម៖

(ក) ទំនិញដែលទទួលបាន ឬផលិតទាំងស្រុងនៅក្នុងដែនដីនៃភាគីនាំចេញ ដូចមានចែង និងកំណត់ក្នុងមាត្រា៣.៣

(ខ) ទំនិញដែលត្រូវបានផលិតនៅក្នុងដែនដីនៃភាគីនាំចេញទាំងស្រុង ចេញពីវត្ថុធាតុមានដើមកំណើត ឬ

(គ) ទំនិញដែលត្រូវបានផលិតនៅក្នុងដែនដីនៃភាគីនាំចេញ ដោយប្រើវត្ថុធាតុមិនមានដើមកំណើត លុះត្រាតែទំនិញនោះបំពេញតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងឧបសម្ព័ន្ធ ៣(ក)។

២. លើកលែងតែមានចែងក្នុងមាត្រា៣.៦ លក្ខខណ្ឌសម្រាប់ការទទួលបានការបញ្ជាក់ដើមកំណើតដែលមានចែងក្នុងជំពូកនេះ ត្រូវតែបំពេញដោយមិនមានការរាំងនៅក្នុងដែនដីនៃភាគីនាំចេញ។

**មាត្រា៣.៣៖ ទំនិញ ដែលទទួលបានទាំងស្រុង ឬផលិតទាំងស្រុង**

នៅក្នុងអត្ថន័យនៃមាត្រា៣.២.១ (ក) ទំនិញដែលត្រូវបានចាត់ទុកថាជាទំនិញដែលទទួលបានទាំងស្រុង ឬផលិតទាំងស្រុង នៅក្នុងដែនដីនៃភាគីម្ខាង មានដូចខាងក្រោម៖

(ក) រុក្ខជាតិ និងផលិតផលពីរុក្ខជាតិ ដែលត្រូវបានប្រមូលផល បេះ ឬប្រមូលយក បន្ទាប់ពីដាំដុះនៅទីនោះ

(ខ) សត្វរស់ ដែលបានកើត និងចិញ្ចឹមនៅទីនោះ

(គ) ទំនិញដែលទទួលបានពីសត្វរស់ ដូចមានចែងក្នុងវាក្យខណ្ឌ (ខ)

(ឃ) ទំនិញដែលទទួលបានមកពី ការប្រមាញ់ ការដាក់អន្ទាក់ ការនេសាទ វារីវប្បកម្ម ការប្រមូលយក និងការចាប់នៅទីនោះ

(ង) រ៉ែ និងសារធាតុកើតឡើងដោយធម្មជាតិដទៃទៀត ដែលមិនបានរាប់បញ្ចូលក្នុងវាក្យខណ្ឌ (ក) ដល់ (ឃ) ដែលបានមកពីការទាញ ឬយកចេញពីក្នុង ដី ទឹក បាតសមុទ្រ ឬនៅក្រោមបាតសមុទ្រ

(ច) ត្រី សំបកខ្យង និងបណ្ដាសត្វ ឬរុក្ខជាតិសមុទ្រដែលមានជីវិតដទៃទៀត ដែលត្រូវបានយកដោយនាវាដែលបានចុះបញ្ជីជាមួយភាគីម្ខាងនោះ ហើយមានសិទ្ធិដាក់ទង់ជាតិរបស់ភាគីម្ខាងនោះ និងផលិតផលផ្សេងទៀតដែលយកដោយភាគីម្ខាង ឬប្រជាជននៃភាគីម្ខាងនោះ ពីក្នុងសមុទ្រ បាតសមុទ្រ ឬក្រោមបាតសមុទ្រនៅខាងក្រៅដែនសមុទ្រ នៃភាគីម្ខាងនោះ ដោយហេតុថាថាភាគីម្ខាងនោះមានសិទ្ធិទាញយកផលប្រយោជន៍ [1] ពីធនធានធម្មជាតិដែលស្ថិតលើដែនសមុទ្រ ក្នុងបាតសមុទ្រ និងក្រោមបាតសមុទ្រ ដោយអនុលោមតាមច្បាប់អន្តរជាតិ

(ឆ) ត្រីសមុទ្រ សំបកខ្យង និងសត្វ ឬរុក្ខជាតិសមុទ្រដែលមានជីវិតដទៃទៀត ដែលត្រូវបានយកចេញពីសមុទ្រអន្តរជាតិដោយនាវាដែលបានចុះបញ្ជីជាមួយភាគីម្ខាងនោះ និងមានសិទ្ធិដាក់ទង់ជាតិរបស់ភាគីម្ខាងនោះ

(ជ) ទំនិញដែលត្រូវបានផលិត ឬបង្កើតផ្ដាច់មុខមកពីផលិតផលដូចមានចែងនៅក្នុងវាក្យខណ្ឌ (ច) ឬ (ឆ) នៅលើរោងចក្រកប៉ាល់ដែលបានចុះបញ្ជីជាមួយភាគីម្ខាងនោះ និងមានសិទ្ធិដាក់ទង់ជាតិរបស់ភាគីម្ខាងនោះ

---

[1] ក្នុងគោលបំណងកំណត់ដើមកំណើតនៃត្រីសមុទ្រ សំបកខ្យង និងសត្វឬរុក្ខជាតិសមុទ្រដែលមានជីវិតដទៃទៀត "សិទ្ធិក្នុងការទាញយកផលប្រយោជន៍" នៅក្នុងមាត្រា៣.៣ (ច) រួមបញ្ចូលសិទ្ធិទាំងឡាយក្នុងការទាញយកធនធានជលផលរបស់រដ្ឋនៃឆ្នេរសមុទ្រ ដូចដែលបានបន្ថែមក្នុងកិច្ចព្រមព្រៀងណាមួយរវាងភាគីម្ខាងជាមួយនឹងរដ្ឋនៃឆ្នេរសមុទ្រ ក្នុងកម្រិតរដ្ឋាភិបាល ឬអង្គភាពឯកជនដែលមានការអនុញ្ញាតត្រឹមត្រូវ។

(ឈ) ទំនិញដែលយកចេញពីលំហខាងក្រៅ ដោយហេតុថាទំនិញទាំងនោះបានប្រមូលដោយភាគីម្ខាងនោះ ឬប្រជាជននៃភាគីម្ខាងនោះ

(ញ) ទំនិញទាំងឡាយណាដែលជា៖

(i) កម្ទេចកម្ទី និងកាកសំណល់ដែលបានពីផលិតកម្ម ឬការប្រើប្រាស់នៅទីនោះ ប្រសិនបើទំនិញបែបនេះសមស្របសម្រាប់តែគោលបំណងក្នុងការបោះចោល ការទាញយកវត្ថុធាតុដើម ឬ ការកែច្នៃយកមកប្រើឡើងវិញ ឬ

(ii) ទំនិញប្រើប្រាស់រួចដែលត្រូវបានប្រមូលនៅទីនោះ ប្រសិនបើទំនិញបែបនេះសមស្របសម្រាប់តែការបោះចោល ការទាញយកវត្ថុធាតុដើម ឬការកែច្នៃយកមកប្រើឡើងវិញ និង

(ដ) ទំនិញ ដែលទទួលបាន ឬត្រូវបានផលិតទាំងស្រុងក្នុងដែនដីនៃភាគីម្ខាងនោះចេញមកពីផលិតផលដូចមានចែងក្នុង វាក្យខណ្ឌ(ក) ដល់ (ញ) តែប៉ុណ្ណោះ។

## មាត្រា៣.៤៖ ការគណនាសមាសធាតុតម្លៃតំបន់

សមាសធាតុតម្លៃតំបន់នៃទំនិញមួយ (តទៅនេះហៅកាត់ថា "RVC") ដូចមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ៣-ក ត្រូវគណនាដោយប្រើរូបមន្តណាមួយ ដូចខាងក្រោម៖

(ក) វិធីផ្ទាល់/វិធីបង្កើនតម្លៃ (Build-Up)

$$RVC = \frac{\text{VOM+ថ្លៃពលកម្មផ្ទាល់+ថ្លៃចំណាយសរុប+ប្រាក់ចំណេញ+ថ្លៃផ្សេងៗ}}{\text{តម្លៃ FOB}} \times 100\%$$

ដែល៖

(i) **VOM** គឺជាតម្លៃនៃវត្ថុធាតុ បំណែក ឬផលិតផលមានដើមកំណើត ដែលយកដោយផលិតករ ឬផលិតដោយខ្លួនឯង នៅក្នុងផលិតកម្មនៃទំនិញនោះ

(ii) **ថ្លៃពលកម្មផ្ទាល់** រួមមាន ប្រាក់ឈ្នួល លាភការ និងអត្ថប្រយោជន៍ផ្សេងទៀតរបស់និយោជិក

(iii) **ថ្លៃចំណាយសរុប** គឺជាការចំណាយសរុប និង

(iv) **ការចំណាយផ្សេងទៀត** គឺជាថ្លៃដើមដែលត្រូវចំណាយក្នុងការដាក់ទំនិញនៅក្នុងកប៉ាល់ ឬមធ្យោបាយដឹកជញ្ជូនផ្សេងទៀត សម្រាប់ការនាំចេញ រួមមាន (ប៉ុន្តែមិនមានកំណត់ត្រឹមតែ) ថ្លៃដើមដឹកជញ្ជូនក្នុងស្រុក ស្តុកនិងឃ្លាំង ការលើកដាក់នៅកំពង់ផែ កម្រៃជើងសារ និងថ្លៃសេវាកម្ម

ឬ

**(ខ)** វិធីប្រយោល/វិធីបញ្ចុះតម្លៃ (Build-Down)

$$RVC = \frac{\text{តម្លៃ FOB - VNM}}{\text{តម្លៃ FOB}} \times 100\%$$

VNM គឺជាតម្លៃនៃវត្ថុធាតុមិនមានដើមកំណើត ដែលត្រូវជា៖

(ក) តម្លៃ CIF នៃវត្ថុធាតុ បំណែក ឬផលិតផល នៅពេលធ្វើការនាំចូល ឬ

(ខ) ថ្លៃដើមដំបូងបំផុត ដែលបានចំណាយសម្រាប់វត្ថុធាតុ បំណែក ឬទំនិញ ដែលមិនមានកំណត់ដើមកំណើតនៅក្នុងដែនដីនៃភាគីម្ខាង ដែលជាទីកន្លែងនៃដំណើរការផលិតកម្ម។

## មាត្រា៣.៥៖ ប្រព្រឹត្តិកម្មសម្រាប់ទំនិញជាក់លាក់

ទោះបីជាមានចែងក្នុងមាត្រា៣.២ ក៏ដោយ ទំនិញជាក់លាក់ ត្រូវបានសន្មត់ថាមានដើមកំណើត ចំពោះវត្ថុធាតុដែលនាំចេញពីភាគីម្ខាង ហើយបន្ទាប់មកបាននាំចូលទៅភាគីម្ខាងនោះវិញ ក្នុងករណីដែលលក្ខខណ្ឌនានាចែងនៅក្នុង ឧបសម្ព័ន្ធ៣-ខ ត្រូវបានបំពេញ បើទោះជាដំណើរការ ឬប្រតិបត្តិការផលិតកម្មត្រូវបានប្រព្រឹត្តឡើងនៅក្នុងតំបន់ឧស្សាហកម្មហ្គេហ្សុង (Gaeseong) ដែលមានទីតាំងនៅឧបទ្វីបកូរ៉េក៏ដោយ។

## មាត្រា៣.៦៖ វិធានបូកបន្ថែម

១. លើកលែងតែមានចែងផ្សេងនៅក្នុងជំពូកនេះ ទំនិញមានដើមកំណើតនៅក្នុងដែនដីនៃភាគីម្ខាង ដែលត្រូវបានប្រើប្រាស់នៅក្នុងដែនដីនៃភាគីម្ខាងទៀត សម្រាប់ធ្វើជាវត្ថុធាតុដើម្បីឱ្យផលិតផលសម្រេច អាចទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ត្រូវបានចាត់ទុកថាមានដើមកំណើតនៅក្នុងដែនដីនៃភាគីម្ខាងទៀតនោះ ដែលក្នុងនោះដំណើរការការងារ ឬដំណើរការផលិតកម្មលើផលិតផលសម្រេចនោះ ត្រូវបានប្រព្រឹត្តឡើង។

២. គូភាគីអាចឯកភាពដើម្បីធ្វើការពិនិត្យឡើងវិញលើមាត្រានេះ ដោយពិចារណាលើការពន្យារការអនុវត្តនៃវិធានបូកបន្ថែមដូចមានចែងក្នុងកថាខណ្ឌ១ ក្នុងគោលបំណងធ្វើឱ្យទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្លាយជាទំនិញមានដើមកំណើតក្រោមកិច្ចព្រមព្រៀងនេះ។

## មាត្រា៣.៧៖ ប្រតិបត្តិការដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

១. ទោះបីជាមានចែងក្នុងបញ្ញត្តិណាមួយនៅក្នុងជំពូកនេះក៏ដោយ ទំនិញមួយមិនត្រូវបានចាត់ទុកថាមានដើមកំណើតនៅក្នុងដែនដីនៃភាគីម្ខាងទេ ប្រសិនបើប្រតិបត្តិការដូចខាងក្រោម ត្រូវបានប្រព្រឹត្តឡើងផ្តាច់មុខដោយខ្លួនឯង ឬរួមគ្នា នៅក្នុងដែនដីនៃភាគីម្ខាងនោះ៖

(ក) ប្រតិបត្តិការរក្សាទុក ដើម្បីធានាថាទំនិញនៅតែស្ថិតក្នុងស្ថានភាពល្អ ក្នុងអំឡុងពេលដឹកជញ្ជូន និងស្តុកទុក។

(ខ) ការផ្លាស់ប្តូរការវេចខ្ចប់ ការបំបែក និងការប្រមូលផ្តុំជាកញ្ចប់

(គ) ការដុស ការលាង ការសម្អាតធូលី ការប្រើប្រាស់អុកស៊ីត ប្រេង ថ្នាំលាប ឬការបិតគម្របផ្សេងៗទៀតបែបសាមញ្ញ[2]

(ឃ) ការអ៊ុត ឬសង្កត់ផលិតផលវាយនភ័ណ្ឌ

---

[2] សម្រាប់គោលបំណងនៃមាត្រានេះ "សាមញ្ញ" ជាទូទៅពិពណ៌នាអំពីសកម្មភាពមួយដែលមិនត្រូវការជំនាញពិសេស ឬម៉ាស៊ីនបរិក្ខារ ឬឧបករណ៍ ដែលត្រូវបានផលិតឬតំឡើងជាពិសេស សម្រាប់ការអនុវត្តសកម្មភាពនេះ។

(ង) ការលាបពណ៌ និងការប៉ូលាសាមញ្ញ

(ច) ការយកសំបកចេញ ការធ្វើឱ្យសដោយផ្នែកឬទាំងស្រុង ការដុសខាត់ និងការធ្វើឱ្យរលោងនៃគ្រាប់ធញ្ញជាតិនិងអង្ករ

(ឆ) ការដាក់ពណ៌ស្ករ ឬការបង្កើតជាដុំស្ករ

(ជ) ការបកសំបក ឬការយកគ្រាប់ចេញបែបសាមញ្ញ

(ឈ) ការសម្រួច ការចិញ្ច្រាំ ឬការកាត់បែបសាមញ្ញ

(ញ) ការច្រោះ ការរែង ការតម្រៀប ការធ្វើចំណាត់ថ្នាក់ ការដាក់កម្រិត ការផ្គូរផ្គង

(ដ) ការដាក់ក្នុងដប កំប៉ុង ដបតូចៗ បាវ ប្រអប់ ឡាំង ការជួសជុលនៅនឹងកន្លែង និង ការវេចខ្ចប់ផ្សេងៗទៀត បែបសាមញ្ញ

(ឋ) ការផ្សារភ្ជាប់ ឬបោះពុម្ពម៉ាក ស្លាកសញ្ញា និមិត្តសញ្ញាផលិតផលឬសេវាកម្ម និងសញ្ញាសម្គាល់លើផលិតផល ឬវត្ថុធាតុវេចខ្ចប់ផលិតផលផ្សេងទៀត

(ឌ) ការលាយផលិតផលបែបសាមញ្ញ[3] ទោះបីជាប្រភេទដូចគ្នាឬខុសគ្នាក៏ដោយ

(ឍ) ការផ្គុំបំណែកក្រណាត់ធម្មតាដើម្បីរួមគ្នាជាក្រណាត់ទាំងមូល ឬការបំបែកផលិតផលឱ្យទៅជាផ្នែកៗ បែបសាមញ្ញ

(ឱ) ការសាកល្បង ឬការក្រិតខ្នាតបែបសាមញ្ញ ឬ

(ឍ) ការសម្លាប់សត្វ[4]។

២. ទំនិញដែលមានដើមកំណើតក្នុងដែនដីនៃភាគីម្ខាង ត្រូវរក្សាស្ថានភាពដើមកំណើតរបស់ខ្លួនដំបូង នៅពេលនាំចេញពីភាគីម្ខាងទៀត ដែលប្រតិបត្តិការប្រព្រឹត្តទៅនោះមិនទាន់ លើសពីប្រតិបត្តិការដែលបានចែងនៅក្នុងកថាខណ្ឌ១។

## មាត្រា៣.៨៖ វត្ថុធាតុប្រើក្នុងផលិតកម្ម

ប្រសិនបើវត្ថុធាតុដែលមិនមានដើមកំណើត ឆ្លងកាត់ផលិតកម្មបន្ថែមរហូតដល់បំពេញបានតាមតម្រូវការនៃជំពូកនេះ វត្ថុធាតុនោះត្រូវចាត់ទុកថាមានដើមកំណើត នៅពេលកំណត់ស្ថានភាពដើមកំណើតនៃទំនិញដែលផលិតបន្ទាប់ ដោយមិនគិតថា វត្ថុធាតុនោះផលិតដោយផលិតករនៃទំនិញនោះទេ។

## មាត្រា៣.៩៖ ការដឹកជញ្ជូនផ្ទាល់

១. ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ត្រូវផ្តល់ជូនសម្រាប់ទំនិញដែលបំពេញបានតាមលក្ខខណ្ឌតម្រូវនានាមានចែងក្នុងជំពូកនេះ និងដែលត្រូវបានដឹកជញ្ជូនត្រង់រវាងដែនដីរបស់ភាគីនាំចេញ និងភាគីនាំចូល។

---

[3] សម្រាប់គោលបំណងនៃមាត្រានេះ "ការលាយបែបសាមញ្ញ" ជាទូទៅពិពណ៌នាអំពីសកម្មភាពមួយ ដែលមិនត្រូវការជំនាញពិសេស ឬម៉ាស៊ីនបរិក្ខារ ឬឧបករណ៍ដែលត្រូវបានផលិតឬតំឡើងជាពិសេសសម្រាប់អនុវត្តសកម្មភាពនេះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការលាយបែបសាមញ្ញមិនរួមបញ្ចូលប្រតិកម្មគីមីទេ។ ប្រតិកម្មគីមី សំដៅដល់ដំណើរការមួយ (រាប់បញ្ចូលទាំងដំណើរការជីវគីមី) ដែលបណ្តាលឱ្យម៉ូលេគុលមានរចនាសម្ព័ន្ធថ្មី ដោយការបំបែកចំណង intramolecular និងដោយការបង្កើតចំណង intramolecular ថ្មី ឬដោយការផ្លាស់ប្តូរអាតូមក្នុងម៉ូលេគុលមួយ។

[4] "ការសម្លាប់" សំដៅដល់ ការសម្លាប់សត្វ និងដំណើរការជាបន្តបន្ទាប់ដូចជាការកាត់ ការធ្វើឱ្យត្រជាក់ ការបង្កក ការប្រឡាក់ជាមួយអំបិល ការសម្ងួត ឬការឆ្អើរ ក្នុងគោលបំណងរក្សាទុកដើម្បីស្តុកទុកនិងដឹកជញ្ជូន។

២. ទោះបីជាមានចែងក្នុងកថាខណ្ឌ១ ក៏ដោយ ទំនិញមួយដែលការដឹកជញ្ជូនមានឆ្លងកាត់ប្រទេសអន្តរការីមួយ ឬច្រើន ក្រៅពីដែនដីរបស់ភាគីនាំចេញ និងភាគីនាំចូល ត្រូវចាត់ទុកថាត្រូវបានដឹកជញ្ជូនត្រង់ ប្រសិនបើ៖

(ក) ទំនិញនោះស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋបាលគយនៃប្រទេសអន្តរការី និង

(ខ) ទំនិញនោះមិនបានឆ្លងកាត់ប្រតិបត្តិការណាមួយបន្ថែមក្រៅពីការលើកចុះ និងការលើកឡើង ការស្តុកទុក ឬប្រតិបត្តិការផ្សេងៗដែលចាំបាច់ក្នុងការរក្សាទំនិញឱ្យស្ថិតក្នុងលក្ខខណ្ឌល្អ។

**មាត្រា៣.១០៖ អប្បបរមា** (De Minimis)

១. ទំនិញមួយដែលមិនបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ត្រូវចាត់ទុកថាមានដើមកំណើត ប្រសិនបើ៖

(ក) សម្រាប់ទំនិញដែលមិនស្ថិតនៅក្នុងជំពូក ៥០ ដល់ ជំពូក ៦៣ នៃប្រព័ន្ធសុខដុមនីយកម្ម តម្លៃនៃវត្ថុធាតុដើមមិនមានដើមកំណើតទាំងអស់ប្រើក្នុងផលិតកម្មនៃទំនិញនោះ ដែលមិនបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ មិនលើសពី ១០ភាគរយ នៃតម្លៃ FOB របស់ទំនិញនោះ

(ខ) សម្រាប់ទំនិញដែលស្ថិតនៅក្នុងជំពូក ៥០ ដល់ ជំពូក ៦៣ នៃប្រព័ន្ធសុខដុមនីយកម្ម ទម្ងន់នៃវត្ថុធាតុដើមមិនមានដើមកំណើតទាំងអស់ប្រើក្នុងផលិតកម្មនៃទំនិញនោះ ដែលមិនបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ មិនលើសពី ១០ភាគរយ នៃទម្ងន់សរុបរបស់ទំនិញនោះ

និងទំនិញដែលបានកំណត់ក្នុងវាក្យខណ្ឌ(ក) និង (ខ) បំពេញគ្រប់លក្ខខណ្ឌដែលអាចអនុវត្តទៅបានដូចមានចែងក្នុងជំពូកនេះ សម្រាប់ការទទួលបានដើមកំណើត។

២. ទោះយ៉ាងណា តម្លៃនៃវត្ថុធាតុមិនមានដើមកំណើតដូចមានចែងក្នុងកថាខណ្ឌ១ ត្រូវបានរាប់បញ្ចូលនៅក្នុងតម្លៃនៃវត្ថុធាតុមិនមានដើមកំណើត សម្រាប់លក្ខខណ្ឌតម្រូវសមាសធាតុតម្លៃតំបន់ដែលអាចអនុវត្តទៅបាន។

**មាត្រា៣.១១៖ ប្រព្រឹត្តិកម្មវេចខ្ចប់ និងវត្ថុធាតុវេចខ្ចប់**

១. វត្ថុធាតុវេចខ្ចប់ និងកុងតឺន័រសម្រាប់ការដឹកជញ្ជូន និងការដឹកទំនិញ នឹងមិនត្រូវយកមកពិចារណាសម្រាប់ការកំណត់ដើមកំណើតទំនិញណាមួយឡើយ។

២. វត្ថុធាតុវេចខ្ចប់ និងកុងតឺន័រសម្រាប់វេចខ្ចប់ទំនិញដើម្បីលក់រាយ ដែលត្រូវបានធ្វើចំណាត់ថ្នាក់រួមជាមួយទំនិញនោះ នឹងមិនត្រូវយកមកពិចារណាសម្រាប់ការកំណត់ស្ថានភាពដើមកំណើតទំនិញនោះឡើយ ក្នុងករណីដែល៖

(ក) ទំនិញនោះទទួលបាន ឬត្រូវបានផលិត ទាំងស្រុង នៅក្នុងភាគីម្ខាង ដូចមានចែងក្នុងមាត្រា៣.២.១(ក)

(ខ) ទំនិញនោះត្រូវបានផលិតនៅក្នុងភាគីម្ខាង ចេញតែពីវត្ថុធាតុមានដើមកំណើត ដូចមានចែងក្នុងមាត្រា៣.២.១(ខ) ឬ

(គ) ទំនិញនោះគឺស្ថិតក្រោមលក្ខខណ្ឌតម្រូវ នៃការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ឬប្រតិបត្តិការផលិតឬកែច្នៃជាក់លាក់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ៣-ក។

៣. ប្រសិនបើទំនិញមួយស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃសមាសធាតុតម្លៃតំបន់ នោះតម្លៃនៃវត្ថុធាតុវេចខ្ចប់ និងកុងតឺន័រសម្រាប់ការវេចខ្ចប់ទំនិញដើម្បីលក់រាយនោះ ត្រូវយកមកពិចារណាថាជាវត្ថុធាតុដែលមានដើមកំណើតឬមិនមានដើមកំណើត ក្នុងការគណនាសមាសធាតុតម្លៃតំបន់នៃទំនិញនោះ តាមករណីនីមួយៗ។

## មាត្រា៣.១២៖ គ្រឿងបន្លាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍

១. សម្រាប់គោលបំណងនៃការកំណត់ស្ថានភាពដើមកំណើតនៃទំនិញមួយ គ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំ ឬឯកសារព័ត៌មានផ្សេងទៀត ដែលភ្ជាប់មកជាមួយទំនិញនោះ ត្រូវចាត់ទុកជាចំណែកនៃទំនិញនោះ និងមិនត្រូវបានរាប់បញ្ចូលក្នុងការកំណត់ថាតើរាល់វត្ថុធាតុមិនមានដើមកំណើតទាំងអស់ដែលត្រូវបានប្រើក្នុងផលិតកម្មនៃទំនិញនោះ បានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយដែលអាចអនុវត្តទៅបាន ឬប្រតិបត្តិការផលិត ឬកែច្នៃជាក់លាក់ ដូចមានចែងក្នុងឧបសម្ព័ន្ធ៣-ក នោះឡើយ ប្រសិនបើ៖

(ក) គ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំ ឬឯកសារព័ត៌មានផ្សេងទៀត ដែលភ្ជាប់មកជាមួយទំនិញនោះ មិនត្រូវបានដាក់ក្នុងវិក្កយបត្រដាច់ដោយឡែកពីទំនិញ ហើយ

(ខ) បរិមាណ និងតម្លៃនៃគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំ ឬឯកសារព័ត៌មានផ្សេងទៀត ដែលភ្ជាប់មកជាមួយទំនិញនោះ មានលក្ខណៈជាឈុតកំប្លេ។

២. ទោះបីជាមានចែងក្នុងកថាខណ្ឌ១ ប្រសិនបើទំនិញមួយស្ថិតក្រោមលក្ខខណ្ឌតម្រូវសមាសធាតុតម្លៃតំបន់ ដូចមានចែងក្នុងឧបសម្ព័ន្ធ ៣-ក តម្លៃនៃគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំ ឬឯកសារព័ត៌មានផ្សេងទៀតដែលភ្ជាប់មកជាមួយទំនិញនោះ ត្រូវយកមកពិចារណាថាជាវត្ថុធាតុដែលមានដើមកំណើត ឬមិនមានដើមកំណើត ក្នុងការគណនាសមាសធាតុតម្លៃតំបន់នៃទំនិញនោះ អាចតាមករណីនីមួយៗ ប្រសិនបើ៖

(ក) គ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំ ឬឯកសារព័ត៌មានផ្សេងទៀត ដែលភ្ជាប់មកជាមួយទំនិញនោះ មិនត្រូវបានដាក់ក្នុងវិក្កយបត្រដាច់ដោយឡែកពីទំនិញ ហើយ

(ខ) បរិមាណ និងតម្លៃនៃគ្រឿងបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងឯកសារណែនាំ ឬឯកសារ ព័ត៌មានផ្សេងទៀត ដែលភ្ជាប់មកជាមួយទំនិញនោះ មានលក្ខណៈជាឈុតកំប្លេ។

## មាត្រា៣.១៣៖ សមាសធាតុអព្យាក្រឹត

ដើម្បីកំណត់ថាទំនិញមួយមានដើមកំណើត គឺមិនត្រូវកំណត់ដើមកំណើតនៃវត្ថុធាតុដូចខាងក្រោម ដែលអាចនឹងត្រូវបានប្រើក្នុងផលិតកម្ម និងមិនបានបញ្ចូលទៅក្នុងទំនិញនោះ៖

(ក) ប្រេងឥន្ធនៈ និងថាមពល

(ខ) ឧបករណ៍ ពុម្ព និងឧបករណ៍ចាក់ពុម្ព

(គ) គ្រឿងបន្លាស់ និងវត្ថុធាតុដែលប្រើប្រាស់ក្នុងការថែទាំគ្រឿងបរិក្ខារ និងអគារ

(ឃ) ប្រេងរំអិល ខ្លាញ់គោ វត្ថុធាតុបន្សំ និងវត្ថុធាតុផ្សេងទៀតដែលប្រើប្រាស់ក្នុងផលិតកម្ម ឬប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការគ្រឿងបរិក្ខារ និងអគារ

(ង) ស្រោមដៃ វ៉ែនតា ស្បែកជើង សម្លៀកបំពាក់ គ្រឿងបរិក្ខារ និងសម្ភារៈផ្គត់ផ្គង់សុវត្ថិភាព

(ច) គ្រឿងបរិក្ខារ ឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ ដែលត្រូវបានប្រើប្រាស់សម្រាប់ការធ្វើតេស្ត ឬការត្រួតពិនិត្យទំនិញ

(ឆ) សារធាតុកាតាលីករ និងសារធាតុរំលាយ និង

(ជ) ទំនិញផ្សេងទៀតដែលមិនត្រូវបានបញ្ចូលទៅក្នុងទំនិញនោះ ប៉ុន្តែការប្រើប្រាស់នៅក្នុងផលិតកម្មទំនិញនោះ អាចត្រូវបានបង្ហាញដោយមានហេតុផលសមរម្យថាជាផ្នែកមួយនៃផលិតកម្មនោះ។

**មាត្រា៣.១៤៖ វត្ថុធាតុ ឬទំនិញដែលអាចជំនួសគ្នាបាន**

នៅពេលកំណត់ថាវត្ថុធាតុ ឬទំនិញដែលអាចជំនួសគ្នាបានមានដើមកំណើត គឺត្រូវធ្វើឡើងដោយការបែងចែកដោយរូបវន្តនៃទំនិញឬវត្ថុធាតុនីមួយៗនៃទំនិញនោះ ឬនៅពេលមានដែលទំនិញនោះលាយឡំគ្នា គឺត្រូវធ្វើឡើងដោយប្រើវិធីគ្រប់គ្រងបញ្ជីសារពើភណ្ឌដែលត្រូវបានទទួលស្គាល់ នៅក្នុងគោលការណ៍គណនេយ្យទទួលស្គាល់ទូទៅនៃភាគីនាំចេញ និងគួរប្រើវិធីពេញមួយឆ្នាំសារពើពន្ធ។

## ផ្នែក ខ
## នីតិវិធីប្រតិបត្តិនៃវិញ្ញាបនបត្រដើមកំណើត

### មាត្រា៣.១៥៖ សំអាងដើមកំណើត

១. ឯកសារខាងក្រោមនេះត្រូវចាត់ទុកជា សំអាងដើមកំណើត៖

(ក) វិញ្ញាបនបត្រដើមកំណើតចេញដោយស្ថាប័នចេញវិញ្ញាបនបត្រ អនុលោមតាមមាត្រា ៣.១៦ ឬ

(ខ) ប្រតិវេទន៍ដើមកំណើតដោយអ្នកនាំចេញដែលមានការអនុញ្ញាត អនុលោមតាមមាត្រា ៣.១៧។

២. សំអាងដើមកំណើតត្រូវ៖

(ក) ធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬទម្រង់ផ្សេងទៀត រួមទាំងទម្រង់អេឡិចត្រូនិក ដូចដែលបានជូនដំណឹងដោយភាគីនាំចូល

(ខ) បញ្ជាក់ថា ទំនិញមានដើមកំណើត និងបំពេញគ្រប់តម្រូវការនៃជំពូកនេះ និង

(គ) មានព័ត៌មានគ្រប់តាមព័ត៌មានតម្រូវជាអប្បរមា ដូចមានចែងក្នុងឧបសម្ព័ន្ធ៣-គ។

៣. ភាគីនីមួយៗត្រូវផ្ដល់នូវសំអាងដើមកំណើតដែលមានសុពលភាពរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលបានចេញ ឬបានបំពេញរួចរាល់។

### មាត្រា៣.១៦៖ វិញ្ញាបនបត្រដើមកំណើត

១. វិញ្ញាបនបត្រដើមកំណើតត្រូវចេញដោយស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញនោះ នៅពេលមានការស្នើសុំដោយអ្នកនាំចេញ ផលិតករ ឬតំណាងដែលទទួលបានការអនុញ្ញាតរបស់ពួកគេ។

២. អ្នកនាំចេញ ផលិតករ ឬតំណាងដែលទទួលបានការអនុញ្ញាតរបស់ពួកគេ ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ ឬមធ្យោបាយអេឡិចត្រូនិកសម្រាប់វិញ្ញាបនបត្រដើមកំណើត ទៅស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញ ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់ភាគីនាំចេញ។

៣. វិញ្ញាបនបត្រដើមកំណើតត្រូវ៖

(ក) មានទម្រង់ដូចមានចែងក្នុងឧបសម្ព័ន្ធ ៣-ឃ

(ខ) មានលេខវិញ្ញាបនបត្រដើមកំណើតផ្សេងៗពីគ្នា

(គ) ធ្វើឡើងជាភាសាអង់គ្លេស និង

(ឃ) មានហត្ថលេខា និងត្រាដែលមានការអនុញ្ញាតរបស់ស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញ។ ហត្ថលេខា និងត្រានេះត្រូវធ្វើឡើងដោយដៃផ្ទាល់ ឬមធ្យោបាយអេឡិចត្រូនិក។

៤. វិញ្ញាបនបត្រដើមកំណើតអាច៖

(ក) បង្ហាញវិក្កយបត្រពីរឬច្រើនដែលចេញសម្រាប់ការដឹកជញ្ជូនតែមួយ ឬ

(ខ) មានទំនិញច្រើនមុខ ប្រសិនបើទំនិញនីមួយៗមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាទំនិញមានដើមកំណើតដោយឡែកពីគ្នាក្នុងសិទ្ធិរបស់ខ្លួន។

៥. ក្នុងកាលៈទេសៈដែលវិញ្ញាបនបត្រដើមកំណើតមានព័ត៌មានមិនត្រឹមត្រូវស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញអាចៈ

(ក) ចេញវិញ្ញាបនបត្រដើមកំណើតថ្មីមួយទៀត ហើយធ្វើមោឃភាពវិញ្ញាបនបត្រដើមកំណើតដើម ឬ

(ខ) ធ្វើការកែប្រែលើវិញ្ញាបនបត្រដើមកំណើតដើមដោយឆូតចោលកំហុស និងសរសេរបន្ថែម ឬកែតម្រូវ។ រាល់ការកែប្រែត្រូវបញ្ជាក់ដោយហត្ថលេខា និងត្រាដែលមានការអនុញ្ញាតរបស់ស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញ។

៦. ភាគីនីមួយៗត្រូវផ្តល់ឈ្មោះ ហត្ថលេខាគំរូ [5] អាសយដ្ឋាន និងត្រាផុសផ្លូវការនៃស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញទៅឱ្យភាគីម្ខាងទៀត។ រាល់ការកែប្រែជាបន្តបន្ទាប់ត្រូវជូនដំណឹងភ្លាមៗ។ ភាគីម្ខាងត្រូវព្យាយាមបង្កើតគេហទំព័រដែលមានសុវត្ថិភាពដើម្បីបង្ហាញព័ត៌មានខាងលើចាប់ពីរយៈពេល ៣ឆ្នាំចុងក្រោយ ហើយគេហទំព័រនេះត្រូវផ្តល់ឱ្យភាគីម្ខាងទៀតអាចចូលទៅប្រើប្រាស់បាន។

៧. វិញ្ញាបនបត្រដើមកំណើតត្រូវចេញនៅមុនពេលឬនៅពេលដឹកជញ្ជូនទំនិញ ឬក្នុងរយៈពេលប្រាំពីរថ្ងៃនៃប្រតិទិន [6] បន្ទាប់ពីកាលបរិច្ឆេទនៃការដឹកជញ្ជូនទំនិញ។ ក្នុងករណីលើកលែងដែលវិញ្ញាបនបត្រដើមកំណើតមិនត្រូវបានចេញនៅមុន ឬនៅពេលដឹកជញ្ជូនទំនិញ ឬក្នុងរយៈពេល ៧ថ្ងៃនៃប្រតិទិន បន្ទាប់ពីការដឹកជញ្ជូនទំនិញ ដោយសារកំហុសអចេតនា ការលុបចោល ឬមូលហេតុដែលសមស្របផ្សេងទៀត ឬក្នុងកាលៈទេសៈដូចមានចែងក្នុងវាក្យខណ្ឌ៥(ក) វិញ្ញាបនបត្រដើមកំណើតអាចត្រូវបានចេញជាលក្ខណៈប្រតិសកម្ម ប៉ុន្តែមិនលើសពីរយៈពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការដឹកជញ្ជូនទំនិញ។ ក្នុងករណីនោះ វិញ្ញាបនបត្រដើមកំណើតត្រូវចេញដោយមានពាក្យ "ISSUED RETROACTIVELY"។

៨. ក្នុងករណីវិញ្ញាបនបត្រដើមកំណើតច្បាប់ដើម ត្រូវបានលួច បាត់បង់ ឬបំផ្លាញ អ្នកនាំចេញ ផលិតករ ឬតំណាងដែលទទួលបានការអនុញ្ញាតរបស់ពួកគេអាចដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញ ដើម្បីទទួលបានច្បាប់ចម្លងដែលមានការបញ្ជាក់នៃវិញ្ញាបនបត្រដើមកំណើតច្បាប់ដើម។ ច្បាប់ចម្លងនេះត្រូវៈ

(ក) ចេញមិនយូរជាងរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រដើមកំណើតច្បាប់ដើម

(ខ) ចេញដោយផ្អែកលើពាក្យស្នើសុំរបស់វិញ្ញាបនបត្រដើមកំណើតច្បាប់ដើម

(គ) មានលេខ និងកាលបរិច្ឆេទដូចគ្នានឹងលេខ និងកាលបរិច្ឆេទនៃវិញ្ញាបនបត្រដើមកំណើតច្បាប់ដើម និង

(ឃ) មានបង្ហាញដោយពាក្យ "CERTIFIED TRUE COPY" ។

---

[5] តម្រូវការដើម្បីផ្សព្វផ្សាយហត្ថលេខាគំរូ គឺមិនចាំបាច់ នៅពេលដែលស្ថាប័នចេញវិញ្ញាបនបត្រដើមកំណើតបានបង្កើតគេហទំព័រដែលមានព័ត៌មានពាក់ព័ន្ធនៃវិញ្ញាបនបត្រដើមកំណើត ដែលភាគីនាំចូលអាចចូលទៅប្រើប្រាស់បាន។

[6] ដើម្បីឱ្យកាន់តែច្បាស់ជាងនេះ "៧ថ្ងៃនៃប្រតិទិន" ត្រូវរាប់បញ្ចូលទាំងកាលបរិច្ឆេទនៃការដឹកជញ្ជូន ។

**មាត្រា៣.១៧៖ ប្រតិវេទន៍ដើមកំណើត**

១. ប្រតិវេទន៍ដើមកំណើត យោងតាមមាត្រា៣.១៥.១(ខ) អាចនឹងត្រូវបំពេញដោយអ្នកនាំចេញដែលមានការអនុញ្ញាតស្របតាមអត្ថន័យនៃមាត្រា៣.១៩។

២. ប្រតិវេទន៍ដើមកំណើតត្រូវ៖

(ក) បំពេញព័ត៌មានដូចមានចែងក្នុងឧបសម្ព័ន្ធ៣-គ

(ខ) ធ្វើឡើងជាភាសាអង់គ្លេស

(គ) មានឈ្មោះ និងហត្ថលេខារបស់បុគ្គលដែលបញ្ជាក់ និង

(ឃ) មានកាលបរិច្ឆេទលើប្រតិវេទន៍ដើមកំណើតត្រូវបានចេញ។

**មាត្រា៣.១៨៖ វិក្កយបត្រចេញដោយភាគីទីបី**

ភាគីនាំចូលមិនត្រូវបដិសេធសំណើប្រើប្រាស់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធដោយព្រោះតែមូលហេតុថា វិក្កយបត្រមិនបានចេញដោយអ្នកនាំចេញ ឬផលិតកររបស់ទំនិញមួយ ក្នុងករណីដែលទំនិញនោះបំពេញតាមលក្ខខណ្ឌតម្រូវនានាក្នុងជំពូកនេះ។

**មាត្រា៣.១៩៖ អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត**

១. ភាគីនីមួយៗត្រូវរៀបចំឱ្យមានការផ្តល់សិទ្ធិអនុញ្ញាតឱ្យអ្នកនាំចេញដែលនាំចេញទំនិញក្រោមកិច្ចព្រមព្រៀងនេះ ជាអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។ អ្នកនាំចេញដែលស្នើសុំការផ្តល់សិទ្ធិនេះ ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ ឬក្នុងទម្រង់អេឡិចត្រូនិច និងត្រូវបំពេញតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ នូវការជានាចាំបាច់ដើម្បីផ្ទៀងផ្ទាត់ស្ថានភាពដើមកំណើតនៃទំនិញដែលមានក្នុងប្រតិវេទន៍ដើមកំណើត។ អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញអាចផ្តល់សិទ្ធិជាអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត អាស្រ័យតាមលក្ខខណ្ឌនានា ដែលខ្លួនចាត់ទុកថាសមស្រប រាប់បញ្ចូលនូវចំណុចដូចខាងក្រោម៖

(ក) អ្នកនាំចេញបានចុះបញ្ជីត្រឹមត្រូវ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីនាំចេញ

(ខ) អ្នកនាំចេញដឹង និងយល់ពី វិធានដើមកំណើតដូចមានចែងក្នុងជំពូកនេះ

(គ) អ្នកនាំចេញមានបទពិសោធក្នុងកម្រិតសមរម្យលើការនាំចេញ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីនាំចេញ

(ឃ) អ្នកនាំចេញមានប្រវត្តិអនុលោមភាពល្អ ដែលបានវាស់វែងដោយការគ្រប់គ្រងហានិភ័យរបស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ

(ង) អ្នកនាំចេញ ក្នុងករណីជាពាណិជ្ជករ អាចទទួលសេចក្តីប្រកាសចេញដោយផលិតករបញ្ជាក់ពីស្ថានភាពដើមកំណើតនៃទំនិញ ដែលត្រូវបំពេញលើប្រតិវេទន៍ដើមកំណើតដោយអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត និងការត្រៀមរួចជាស្រេចរបស់ផលិតករដើម្បីសហការក្នុងដំណើរការផ្ទៀងផ្ទាត់អនុលោមតាមមាត្រា៣.២២ និងបំពេញរាល់ការតម្រូវនៃជំពូកនេះ និង

(ច) អ្នកនាំចេញមានបញ្ជីគណនេយ្យ និងប្រព័ន្ធរក្សាកំណត់ត្រា ដែលរក្សាថែទាំបានល្អ ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីនាំចេញ។

២. អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញត្រូវៈ

(ក) ធ្វើឱ្យនីតិវិធី និងលក្ខខណ្ឌតម្រូវស្តីពីអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតបានដឹងលឺដល់សាធារណៈ និងងាយស្រួលស្វែងរក

(ខ) ផ្តល់សិទ្ធិជាអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬជាទម្រង់អេឡិចត្រូនិច

(គ) ផ្តល់ឱ្យអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតនូវលេខកូដសម្គាល់សិទ្ធិ ដែលត្រូវតែដាក់បញ្ចូលក្នុងប្រតិវេទន៍ដើមកំណើត និង

(ឃ) ផ្លាស់ប្តូរព័ត៌មាន[7] របស់អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតរបស់គូភាគីជាមួយនឹងភាគីដទៃទៀតតាមរយៈគេហទំព័រដែលមានសុវត្ថិភាព ឬតាមរយៈមធ្យោបាយអេឡិចត្រូនិចផ្សេងទៀតពាក់ព័ន្ធនឹងការផ្តល់សិទ្ធិអនុញ្ញាត។

៣. ទោះបីជាមានការចែងក្នុងវាក្យខណ្ឌ២(ឃ) ភាគីម្ខាងមិនតម្រូវឱ្យផ្តល់ទៅភាគីម្ខាតទៀតនូវព័ត៌មានដែលមានចែងក្នុងវាក្យខណ្ឌនោះឡើយ ប្រសិនបើភាគីម្ខាងនោះបានបង្កើតគេហទំព័រសុវត្ថិភាពរបស់ខ្លួន ដែលមានព័ត៌មានខាងលើ ហើយដែលភាគីម្ខាងទៀតអាចចូលប្រើប្រាស់បាន។

៤. អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតត្រូវមានកាតព្វកិច្ចដូចខាងក្រោមៈ

(ក) អនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ អាចចូលទៅប្រើប្រាស់កំណត់ត្រា និងអាជីវកម្មដ្ឋាន សម្រាប់គោលបំណងតាមដានការប្រើប្រាស់សិទ្ធិអនុញ្ញាត អនុលោមតាមមាត្រា៣.២៥

(ខ) បំពេញប្រតិវេទន៍ដើមកំណើតសម្រាប់តែទំនិញ ដែលអ្នកនាំចេញបានទទួលសិទ្ធិអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញឱ្យធ្វើដូចនេះបាន និងនៅពេលដែលអ្នកនាំចេញនោះមានឯកសារសមស្របទាំងអស់ដែលបញ្ជាក់ពីស្ថានភាពទទួលដើមកំណើតនៃទំនិញពាក់ព័ន្ធនាពេលបំពេញប្រតិវេទន៍នោះ

(គ) ទទួលខុសត្រូវពេញលេញលើប្រតិវេទន៍ដើមកំណើតទាំងអស់ រួមទាំងកំហុសទាំងឡាយផងដែរ និង

(ឃ) ជូនដំណឹងឱ្យបានឆាប់រហ័សដល់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ នូវរាល់ការផ្លាស់ប្តូរពាក់ព័ន្ធនឹងព័ត៌មានដូចមានចែងក្នុងវាក្យខណ្ឌ(ខ)។

៥. អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ ត្រូវតាមដានការប្រើប្រាស់សិទ្ធិអនុញ្ញាត រាប់បញ្ចូលទាំងការផ្ទៀងផ្ទាត់ប្រតិវេទន៍ដើមកំណើតដោយអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត និងដកហូតសិទ្ធិ នៅពេលដែលលក្ខខណ្ឌមានចែងក្នុងកថាខណ្ឌ១ មិនត្រូវបានបំពេញ។

---

[7] ព័ត៌មានទាំងនោះរួមមាន ឈ្មោះផ្លូវការ និងអាសយដ្ឋានរបស់អ្នកនាំចេញ លេខកូដសម្គាល់របស់អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត កាលបរិច្ឆេទផ្តល់សិទ្ធិ និងកាលកំណត់ (ប្រសិនបើមាន) នៃការផ្តល់សិទ្ធិជាអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត និងបញ្ជីទំនិញដែលទទួលបានអនុញ្ញាតយ៉ាងហោចណាស់ក្នុងកម្រិតជំពូកតាមប្រព័ន្ធ HS។

៦. អ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាតត្រូវរៀបចំដើម្បីដាក់ជូនតាមសំណើរបស់រដ្ឋបាលគយនៃភាគីនាំចូលនៅពេលណាមួយ នូវរាល់ឯកសារសមស្របដែលបញ្ជាក់ពីស្ថានភាពដើមកំណើតរបស់ទំនិញពាក់ព័ន្ធ រាប់បញ្ចូលទាំងការអះអាងរបស់អ្នកផ្គត់ផ្គង់ ឬផលិតករ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីនាំចូល ក៏ដូចជាការបំពេញតាមការតម្រូវនានានៃជំពូកនេះ។

## មាត្រា៣.២០៖ ការស្នើសុំអនុវត្តប្រព្រឹត្តិកម្មអនុគ្រោះពន្ធ

១. ភាគីនាំចូលត្រូវផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ អនុលោមតាមកិច្ចព្រមព្រៀងនេះ ដល់ទំនិញដែលមានដើមកំណើតដោយផ្អែកលើសំអាងដើមកំណើត

២. លុះត្រាតែមានការចែងផ្សេងក្នុងជំពូកនេះ សម្រាប់គោលបំណងនៃការស្នើសុំអនុវត្តប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ភាគីនាំចូលត្រូវកំណត់ឱ្យអ្នកនាំចូលត្រូវ៖

(ក) ធ្វើសេចក្តីប្រកាសក្នុងប្រតិវេទន៍គយរបស់ខ្លួនថាទំនិញនោះបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ជាទំនិញមានដើមកំណើត

(ខ) មានសំអាងដើមកំណើតមានសុពលភាពនៅពេលធ្វើសេចក្តីប្រកាសដូចក្នុងវាក្យខណ្ឌ (ក) និង

(គ) ផ្តល់សំអាងដើមកំណើតច្បាប់ដើម ឬច្បាប់ចម្លងមានការបញ្ជាក់ ទៅភាគីនាំចូលប្រសិនបើតម្រូវដោយភាគីនាំចូល

៣. ទោះជាមានការចែងនៅកថាខណ្ឌ១ និង២ក៏ដោយ ភាគីនាំចូលអាចនឹងមិនតម្រូវឱ្យមានសំអាងដើមកំណើតប្រសិនបើ៖

(ក) តម្លៃគិតពន្ធគយនៃការនាំចូលមិនលើស ២០០ដុល្លារអាមេរិច ឬចំនួនសមមូលជារូបិយវត្ថុរបស់ភាគីនាំចូល ឬចំនួនណាមួយលើសនេះ តាមការកំណត់របស់ភាគីនាំចូល ឬ

(ខ) ទំនិញនោះជាទំនិញដែលភាគីនាំចូលបានលើកលែងការតម្រូវ

ក្នុងលក្ខខណ្ឌដែលការនាំចូលមិនបង្កជាផ្នែកនៃលំដាប់បណ្តាក់គ្នានៃការនាំចូលដែលធ្វើឡើង ឬរៀបចំគម្រោងឡើងក្នុងគោលបំណងគេចពីកាតព្វកិច្ចអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីនាំចូលពាក់ព័ន្ធនឹងការស្នើសុំអនុវត្តប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ក្រោមកិច្ចព្រមព្រៀងនេះ។

៤. ក្នុងករណីសមស្រប រដ្ឋបាលគយនៃភាគីនាំចូលអាចតម្រូវឱ្យ អ្នកនាំចូលដាក់ឯកសារគាំទ្រជាភស្តុតាងថា ទំនិញទាំងនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានដើមកំណើត ដោយអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ជំពូកនេះ។

៥. អ្នកនាំចូលត្រូវបង្ហាញថាលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា៣.៩ ត្រូវបានបំពេញ និងផ្តល់ភស្តុតាងនេះតាមសំណើរបស់រដ្ឋបាលគយនៃភាគីនាំចូល។

៦. នៅពេលដែលសំអាងដើមកំណើត ត្រូវបានដាក់ជូនរដ្ឋបាលគយនៃភាគីនាំចូលក្រោយកាលកំណត់នៃរយៈពេលសម្រាប់ការដាក់សំអាងដើមកំណើតនោះ សំអាងដើមកំណើតដូចនេះ អាចនៅតែត្រូវបានទទួល អាស្រ័យតាមច្បាប់ បទប្បញ្ញត្តិ ឬការអនុវត្តបែបរដ្ឋបាលរបស់ភាគីនាំចូល នៅពេលការខកខានក្នុងការពិនិត្យមើលរយៈពេលនេះ បណ្តាលមកពីករណីប្រធានស័ក្តិ ឬមូលហេតុសមស្របណាមួយដែលផុតពីការគ្រប់គ្រងរបស់អ្នកនាំចូល ឬនាំចេញ។

**មាត្រា៣.២១៖ ការស្នើសុំប្រព្រឹត្តិកម្មអនុគ្រោះពន្ធក្រោយពេលទំនិញនាំចូលរួច**

១. ភាគីនីមួយៗ ដោយផ្អែកតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ត្រូវកំណត់ថានៅពេលទំនិញមួយអាចនឹងបានបំពេញលក្ខខណ្ឌជាទំនិញមានដើមកំណើត នៅពេលនាំចូលក្នុងភាគីម្ខាងនោះ អ្នកនាំចូលនៃទំនិញនោះអាច ស្នើសុំការបង្វិលសងប្រាក់ពន្ធដែលលើស និមុត្តធានា ឬប្រាក់ធានាដែលបានបង់ ក្នុងកំឡុងពេលដែលចែងដោយច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីម្ខាងនោះ និងក្រោយកាលបរិច្ឆេទដែលទំនិញត្រូវបាននាំចូល ដោយមូលហេតុដែលទំនិញនោះមិនទាន់បានត្រូវផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ដោយបង្ហាញដល់រដ្ឋបាលគយនៃភាគីនោះ ដូចខាងក្រោម៖

(ក) សំអាងដើមកំណើត និងភស្តុតាងផ្សេងទៀតដែលបញ្ជាក់ថាទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាទំនិញមានដើមកំណើត និង

(ខ) ឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការនាំចូល តាមការតម្រូវរបស់រដ្ឋបាលគយដើម្បីជាភស្តុតាងសមស្របនៃប្រព្រឹត្តិកម្មអនុគ្រោះពន្ធដែលស្នើសុំ។

២. ទោះបីមានចែងក្នុងកថាខណ្ឌ១ ក៏ដោយ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ភាគីនីមួយៗអាចតម្រូវឱ្យអ្នកនាំចូលជូនដំណឹងដល់រដ្ឋបាលគយរបស់ភាគីម្ខាងនោះនូវគោលបំណងរបស់ខ្លួនក្នុងការស្នើសុំប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាពេលនាំចូល។

**មាត្រា៣.២២៖ ការពិនិត្យផ្ទៀងផ្ទាត់**

១. សម្រាប់គោលបំណងក្នុងការកំណត់ថា ទំនិញមួយដែលបាននាំចូលទៅកាន់ភាគីម្ខាង ពីភាគីម្ខាងទៀតមាន ឬគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាទំនិញមានដើមកំណើតក្រោមជំពូកនេះអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចូលអាចអនុវត្តដំណើរការផ្ទៀងផ្ទាត់ ដោយមធ្យោបាយដូចតទៅ៖

(ក) សំណើសុំព័ត៌មានបន្ថែមជាលាយលក្ខណ៍អក្សរ ពីអ្នកនាំចូល

(ខ) សំណើសុំព័ត៌មានបន្ថែមជាលាយលក្ខណ៍អក្សរ ពីអ្នកនាំចេញ ឬផលិតករ

(គ) សំណើជាលាយលក្ខណ៍អក្សរ ស្នើសុំជំនួយពីអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញក្នុងការផ្ទៀងផ្ទាត់ដើមកំណើតនៃទំនិញ ក្នុងវង្វង់ដែនសមត្ថកិច្ច និងធនធានដែលមានរបស់ភាគីនាំចេញ

(ឃ) ទស្សនកិច្ចផ្ទៀងផ្ទាត់នៅអាជីវកម្មដ្ឋានរបស់ អ្នកនាំចេញ ឬផលិតករក្នុងភាគីនាំចេញដើម្បីអង្កេតលើទីកន្លែង និងដំណើរការផលិតទំនិញ និងពិនិត្យផ្ទៀងផ្ទាត់កំណត់ត្រានានាពាក់ព័ន្ធនឹងដើមកំណើត រួមទាំងឯកសារគណនេយ្យនានា[៥] ឬ

(ង) នីតិវិធីផ្សេងទៀតដែលគូភាគីអាចឯកភាពគ្នា។

២. ភាគីនាំចូលត្រូវ៖

(ក) សម្រាប់គោលបំណងនៃវាក្យខណ្ឌ១(ខ) បញ្ជូននូវសំណើជាលាយលក្ខណ៍អក្សរភ្ជាប់ជាមួយសំអាងដើមកំណើត និងមូលហេតុនៃការស្នើសុំទៅអ្នកនាំចេញ ឬផលិតករនៃទំនិញ

---

[៥] ទស្សនកិច្ចផ្ទៀងផ្ទាត់ក្រោមវាក្យខណ្ឌនេះ ត្រូវអនុវត្តបានតែក្រោយពេលដំណើរការនៃការផ្ទៀងផ្ទាត់ ដោយអនុលោមតាមវាក្យខណ្ឌ (គ) ត្រូវបានដាក់ចេញ។

(ខ) សម្រាប់គោលបំណងនៃវាក្យខណ្ឌ១(គ) បញ្ជូននូវសំណើជាលាយលក្ខណ៍អក្សរភ្ជាប់ជាមួយសំអាងដើមកំណើត និងមូលហេតុនៃការសុំទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចេញ និង

(គ) សម្រាប់គោលបំណងនៃវាក្យខណ្ឌ១(ឃ) ស្នើសុំការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នកនាំចេញ ឬផលិតករដែលជាម្ចាស់អាជីវកម្មដ្ឋានដែលនឹងត្រូវទទួលទស្សនកិច្ច និងអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចេញ និងបញ្ជាក់ពីកាលបរិច្ឆេទ និងទីតាំងដែលស្នើសុំសម្រាប់ទស្សនកិច្ច និងគោលបំណងជាក់លាក់។

៣. តាមសំណើរបស់ភាគីនាំចូល ទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់នៅអាជីវកម្មដ្ឋានរបស់អ្នកនាំចេញ ឬផលិតករ អាចប្រព្រឹត្តទៅបាន ដោយមានការយល់ព្រម និងជំនួយរបស់ភាគីនាំចេញ អនុលោមតាមនីតិវិធីដែលបានឯកភាពគ្នារវាងភាគីនាំចូល និងភាគីនាំចេញ។

៤. សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់ក្រោមវាក្យខណ្ឌ១(ក) ដល់(ឃ) ភាគីនាំចូល ត្រូវ៖

(ក) អនុញ្ញាតឱ្យអ្នកនាំចូល អ្នកនាំចេញ ផលិតករ ឬស្ថាប័នចេញវិញ្ញាប័នបត្រ ឬអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចេញ រវាងអំឡុងពេល ៣០ និង៩០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលសំណើសុំព័ត៌មានជាលាយលក្ខណ៍អក្សរក្រោមវាក្យខណ្ឌ១(ក) ដល់(គ) ដើម្បីឆ្លើយតប

(ខ) អនុញ្ញាតឱ្យអ្នកនាំចេញ ផលិតករ ឬអាជ្ញាធរមានសមត្ថកិច្ច យល់ព្រម ឬបដិសេធនូវសំណើសុំក្នុងអំឡុងពេល ៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលសំណើសុំជាលាយលក្ខណ៍អក្សរសម្រាប់ទស្សនកិច្ចផ្ទៀងផ្ទាត់ ក្រោមវាក្យខណ្ឌ១(ឃ) និង

(គ) ធ្វើការសម្រេចចិត្ត បន្ទាប់ពីការពិនិត្យផ្ទៀងផ្ទាត់ក្នុងអំឡុងពេល ៩០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលព័ត៌មានចាំបាច់ ដើម្បីធ្វើសេចក្តីសម្រេច។

៥. សម្រាប់គោលបំណងនៃកថាខណ្ឌ១ ភាគីនាំចូល ត្រូវផ្តល់នូវការជូនដំណឹងជាលាយលក្ខណ៍អក្សរនូវលទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់ ជាមួយហេតុផលសម្រាប់លទ្ធផលនោះដល់អ្នកនាំចូល អ្នកនាំចេញ ឬផលិតករនៃទំនិញ អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចេញដែលបានទទួលសំណើ សុំផ្ទៀងផ្ទាត់នោះ។

៦. រដ្ឋបាលគយរបស់ភាគីនាំចូល អាចពន្យារការអនុវត្តប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ខណៈពេលកំពុងរង់ចាំលទ្ធផលពិនិត្យផ្ទៀងផ្ទាត់។ ភាគីនាំចូល ត្រូវអនុញ្ញាតឱ្យបញ្ចេញទំនិញ ប៉ុន្តែអាចតម្រូវថាការបញ្ចេញទំនិញនេះត្រូវជាកម្មវត្ថុនៃការបង់និមុត្តិធានា អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

## មាត្រា៣.២៣៖ ការបដិសេធប្រព្រឹត្តិកម្មអនុគ្រោះពន្ធ

១. រដ្ឋបាលគយរបស់ភាគីនាំចូល អាចបដិសេធប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ក្នុងលក្ខខណ្ឌដែល៖

(ក) ទំនិញមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃជំពូកនេះ ឬ

(ខ) អ្នកនាំចូល អ្នកនាំចេញ ឬផលិតករ ខកខាន ឬមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធផ្សេងទៀតនៃជំពូកនេះ ដើម្បីទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធ។

២. ក្នុងករណីបដិសេធលើសំណើសុំប្រើប្រាស់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ រដ្ឋបាលគយនៃភាគីនាំចូល ត្រូវផ្តល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទៅអ្នកនាំចូលដែលមានហេតុផលលើសេចក្តីសម្រេចនោះ។

៣. រដ្ឋបាលគយរបស់ភាគីនាំចូល អាចកំណត់ថាទំនិញមិនបានបំពេញគ្រប់លក្ខខណ្ឌជាទំនិញមានដើមកំណើត និងអាចបដិសេធប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ក្នុងលក្ខខណ្ឌដែលៈ

(ក) រដ្ឋបាលគយរបស់ភាគីនាំចូល មិនបានទទួលព័ត៌មានគ្រប់គ្រាន់ សម្រាប់ធ្វើការកំណត់ថាទំនិញមានដើមកំណើត

(ខ) អ្នកនាំចេញ ផលិតករ ឬ អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចេញ មិនបានឆ្លើយតបចំពោះសំណើសុំជាលាយលក្ខណ៍អក្សរនូវព័ត៌មានដែលអនុលោមតាមមាត្រា៣.២២ ឬ

(គ) សំណើសុំទស្សនកិច្ចពិនិត្យផ្ទៀងផ្ទាត់ ដែលអនុលោមក្នុងមាត្រា៣.២២ ត្រូវបានបដិសេធ។

## មាត្រា៣.២៤៖ ភាពលម្អៀង ឬកំហុសតិចតួច

រដ្ឋបាលគយរបស់ភាគីនាំចូល មិនត្រូវយកចិត្តទុកដាក់ទៅលើភាពលម្អៀង ឬកំហុសតិចតួច ដូចជាភាពខុសគ្នាបន្តិចបន្តួចលើឯកសារនានា ការខ្វះចន្លោះព័ត៌មាន កំហុសពីការវាយអក្សរ ឬការបោះពុម្ពអក្សរចេញខុសទីតាំងកំណត់ ក្នុងករណីដែលភាពលម្អៀង ឬកំហុសតិចតួចទាំងនេះ មិនបង្កើតជាការសង្ស័យទៅលើស្ថានភាពដើមកំណើតទំនិញទេ។

## មាត្រា៣.២៥៖ តម្រូវការរក្សាកំណត់ត្រា

១. ភាគីនីមួយៗ ត្រូវតម្រូវឱ្យៈ

(ក) អ្នកនាំចេញ ផលិតករ ស្ថាប័នចេញវិញ្ញាបនបត្រ ឬអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ត្រូវរក្សាទុកយ៉ាងតិចណាស់ក្នុងរយៈពេល ៥ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញសំអាងដើមកំណើត ឬក្នុងរយៈពេលវែងជាងនេះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនូវកំណត់ត្រាចាំបាច់ទាំងអស់ដើម្បីបញ្ជាក់ថា ទំនិញក្នុងសំអាងដើមកំណើតដែលបានចេញនោះ ទទួលបានដើមកំណើតត្រឹមត្រូវ និង

(ខ) អ្នកនាំចូលរបស់ខ្លួន រក្សាទុកឱ្យបានយ៉ាងតិចក្នុងរយៈពេល ៥ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃទំនិញនាំចូល ឬក្នុងរយៈពេលវែងជាងនេះ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនូវកំណត់ត្រាចាំបាច់ទាំងអស់ដើម្បីបញ្ជាក់ថាទំនិញដែលបានដាក់ស្នើសុំប្រព្រឹត្តិកម្មអនុគ្រោះពន្ធ មានដើមកំណើត។

២. កំណត់ត្រានានាមានចែងក្នុងកថាខណ្ឌ១ អាចរក្សានៅក្នុងឧបករណ៍ផ្ទុកណាមួយដែលអនុញ្ញាតឱ្យទាញទិន្នន័យវិញបានភ្លាមៗ រួមមាន ទម្រង់ឌីជីថល អេឡិចត្រូនិច អុបទិក ម៉ាញ៉េទិក ឬទម្រង់ជាលាយលក្ខណ៍អក្សរ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់ភាគីម្ខាង។

**មាត្រា៣.២៦៖ ការពិគ្រោះយោបល់**

គូភាគីត្រូវពិគ្រោះយោបល់នៅពេលចាំបាច់ដោយធានាថា ជំពូកនេះត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព មានឯកសណ្ឋានភាព និងមានសង្គតិភាព ដើម្បីសម្រេចឱ្យបាននូវស្មារតី និងគោលបំណងនៃកិច្ចព្រមព្រៀងនេះ។

**មាត្រា៣.២៧៖ ប្រព័ន្ធអេឡិចត្រូនិចសម្រាប់ការផ្លាស់ប្តូរព័ត៌មានដើមកំណើត**

គូភាគីអាចអភិវឌ្ឍប្រព័ន្ធអេឡិចត្រូនិចសម្រាប់ការផ្លាស់ប្តូរព័ត៌មានដើមកំណើតដើម្បីធានាដល់ការអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធិភាពនៃជំពូកនេះ ក្នុងស្មារតីកំណត់រួមគ្នាដោយគូភាគី។

**មាត្រា៣.២៨៖ បញ្ញត្តិអន្តរកាលចំពោះទំនិញឆ្លងកាត់**

ភាគីម្ខាងត្រូវផ្តល់នូវប្រព្រឹត្តិកម្មអនុគ្រោះពន្ធ លើទំនិញមានដើមកំណើត ដែលគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ចំពោះភាគីម្ខាងនោះ៖

(ក) ត្រូវបានកំពុងតែដឹកជញ្ជូនទៅកាន់ភាគីម្ខាងនោះ អនុលោមតាមមាត្រា៣.៩ ឬ

(ខ) មិនទាន់ត្រូវបាននាំចូលក្នុងភាគីម្ខាងនោះ

ប្រសិនបើការទាមទារមានសុពលភាព អនុលោមតាមមាត្រា៣.២០ ចំពោះប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ត្រូវបានធ្វើឡើងក្នុងអំឡុងពេល ១៨០ថ្ងៃ នៃកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះសម្រាប់ភាគីម្ខាងនោះ ជាកម្មវត្ថុនៃការដាក់ជូនរដ្ឋបាលគយនៃភាគីនាំចូលនូវសំអាងដើមកំណើតដែលចេញតាមក្រោយរួមជាមួយនឹងឯកសារបង្ហាញថា ទំនិញនោះត្រូវបានដឹកជញ្ជូនត្រង់ អនុលោមតាមមាត្រា៣.៩។

**មាត្រា៣.២៩៖ ការផាកពិន័យ**

ភាគីនីមួយៗត្រូវអនុម័តជាថ្មី ឬរក្សាការផាកពិន័យដែលសមស្រប ឬវិធានការផ្សេងទៀត ដែលប្រឆាំងនឹងការបំពានច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួនពាក់ព័ន្ធនឹងជំពូកមួយនេះ។

**មាត្រា៣.៣០៖ ភាសាទំនាក់ទំនង**

ការប្រាស្រ័យទាក់ទងរវាងភាគីនាំចូល និងភាគីនាំចេញ ត្រូវធ្វើឡើងជាភាសាអង់គ្លេស។

**មាត្រា៣.៣១៖ ចំណុចទំនាក់ទំនង**

ក្នុងអំឡុងពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ភាគីនីមួយៗត្រូវចាត់តាំងចំណុចទំនាក់ទំនងមួយ ឬច្រើនសម្រាប់ការអនុវត្តជំពូកនេះ ហើយជូនដំណឹងទៅភាគីម្ខាងទៀតនូវព័ត៌មានទំនាក់ទំនងនៃចំណុចទំនាក់ទំនងនោះ ឬចំណុចទំនាក់ទំនងទាំងនោះ។ ភាគីនីមួយៗ ត្រូវជូនដំណឹងភ្លាមៗដល់ភាគីម្ខាងទៀតនូវរាល់ការផ្លាស់ប្តូរណាមួយចំពោះព័ត៌មានទំនាក់ទំនងទាំងនោះ។

**មាត្រា៣.៣២៖ ឯកសារគាំទ្រដល់ការដឹកជញ្ជូនផ្ទាល់**

សម្រាប់គោលបំណងនៃការអនុវត្តមាត្រា៣.៩ ក្នុងករណីការដឹកជញ្ជូនត្រូវបានអនុវត្តឆ្លងកាត់ដែនដីនៃប្រទេសអន្តរការីមួយឬច្រើន ក្រៅពីដែនដីរបស់គូភាគី នោះឯកសារដែលត្រូវប្រគល់ជូនអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធនៃភាគីនាំចូល មានដូចខាងក្រោម៖

(ក) អញ្ញត្តប័ណ្ណដឹកជញ្ជូនដែលចេញនៅក្នុងដែនដីនៃភាគីនាំចេញដែលរាប់បញ្ចូលទាំងឯកសារដឹកជញ្ជូននានារួមបញ្ចូលគ្នាដែលគ្របដណ្តប់ទាំងស្រុងនូវច្រកផ្លូវដឹកជញ្ជូននៃទំនិញមួយ ចេញពីភាគីនាំចេញទៅភាគីនាំចូល ឬ

(ខ) ឯកសារគាំទ្រពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមាន ដើម្បីជាភស្តុតាងបញ្ជាក់ថា តម្រូវការដូចមានចែងក្នុងមាត្រា៣.៩ ត្រូវបានបំពេញ។

# ឧបសម្ព័ន្ធ ៣-ខ
# ប្រព្រឹត្តិកម្មសម្រាប់ទំនិញជាក់លាក់

## ១. ការផ្តល់ដើមកំណើតទំនិញ

(ក) “ទំនិញជាក់លាក់” យោងតាមមាត្រា៣.៥ ដូចមានក្នុងបញ្ជី ក្រោមកថាខណ្ឌ៧និងការធ្វើវិសោធនកម្មជាបន្តបន្ទាប់ទៀត ដែលត្រូវបាននាំចូលមកវិញជាទំនិញដែលមិនឆ្លងកាត់ដំណើរការណាមួយក្រៅពីប្រតិបត្តិការក្នុងដែនដីនៃភាគីនាំចូលមកវិញសម្រាប់ការនាំចេញ ដូចមានចែងក្នុងមាត្រា៣.៧ ត្រូវបានចាត់ទុកថា មានដើមកំណើតនៅក្នុងដែនដីនៃភាគីម្ខាងនោះ ប្រសិនបើតម្លៃសរុបនៃធាតុចូលមិនមានដើមកំណើត [1] មិនលើសពី ៤០ភាគរយ នៃតម្លៃ FOB នៃទំនិញសម្រេចដែលស្ថានភាពដើមកំណើតត្រូវបានទទួល។

(ខ) លើកលែងតែមានចែងផ្សេងពីឧបសម្ព័ន្ធនេះ វិធាននានាពាក់ព័ន្ធនៅក្នុងជំពូកនេះ *ត្រូវយកមកអនុវត្តដូចគ្នា* ចំពោះការផ្តល់ដើមកំណើតនៃទំនិញដែលមាត្រា៣.៥ ត្រូវអនុវត្ត។

## ២. នីតិវិធីជាក់លាក់សម្រាប់ការអនុវត្តមាត្រា ៣.៥

(ក) វិញ្ញាបនបត្រដើមកំណើតសម្រាប់ទំនិញដែលស្ថិតនៅក្រោមមាត្រា៣.៥ ត្រូវចេញដោយស្ថាប័នចេញវិញ្ញាបនបត្រដើមកំណើត[2] នៃភាគីនាំចេញ ដោយផ្អែកលើផ្នែក (ខ) នៃជំពូកនេះ។

(ខ) ស្ថាប័នចេញវិញ្ញាបនបត្រដើមកំណើតរបស់ភាគីនាំចេញ ត្រូវបង្ហាញក្នុងវិញ្ញាបនបត្រដើមកំណើតថាទំនិញស្ថិតនៅក្រោមមាត្រា៣.៥

(គ) លើកលែងតែមានចែងផ្សេងពីឧបសម្ព័ន្ធនេះ បណ្តាមាត្រាពាក់ព័ន្ធនៅក្នុងផ្នែក (ខ) នៃជំពូកនេះ *ត្រូវយកមកអនុវត្តដូចគ្នា* ចំពោះទំនិញដែលមាត្រា៣.៥ ត្រូវអនុវត្ត ។

(ឃ) ប្រទេសកូរ៉េត្រូវជួយដល់អាជ្ញាធរគយកម្ពុជា ដើម្បីធ្វើការផ្ទៀងផ្ទាត់ទំនិញដែលស្ថិតក្រោមមាត្រា៣.៥ អនុលោមតាមមាត្រាពាក់ព័ន្ធនៅក្នុងផ្នែក (ខ) នៃជំពូកនេះ។

## ៣. ការការពារពិសេស

(ក) នៅពេលភាគីម្ខាងកំណត់ថា មានការកើនឡើងនៃការនាំចូលទំនិញណាមួយស្ថិតក្រោមមាត្រា៣.៥ ចូលទៅក្នុងដែនដីនៃភាគីម្ខាងនោះ នៅក្នុងបរិមាណ និងលក្ខខណ្ឌដែលបង្ក ឬគំរាមកំហែងធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុករបស់ខ្លួន ភាគីម្ខាងនោះត្រូវមានសិទ្ធិក្នុងការព្យួរការអនុវត្តមាត្រា៣.៥ ចំពោះទំនិញនោះសម្រាប់

---

[1] "តម្លៃសរុបនៃធាតុចូលមិនមានដើមកំណើត" ត្រូវមានន័យថាតម្លៃនៃវត្ថុធាតុដើមមិនមានដើមកំណើតដែលបានបន្ថែមទៅខាងក្នុងក៏ដូចជាវត្ថុធាតុដើមណាមួយដែលបានបន្ថែម និងរាល់ការចំណាយផ្សេងទៀតដែលបូកបន្ថែមមកពីខាងក្រៅប្រទេសកម្ពុជា និងប្រទេសកូរ៉េ រួមទាំងការចំណាយដឹកជញ្ជូនផងដែរ។

[2] ចំពោះប្រទេសកូរ៉េ សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ "ស្ថាប័នចេញវិញ្ញាបនបត្រដើមកំណើត" មានន័យថា អាជ្ញាធរគយកូរ៉េ។

អំឡុងពេលមួយ ពីព្រោះវាអាចចាត់ទុកថាចាំបាច់ក្នុងការគាំពារឬដោះស្រាយផលប៉ះពាល់ ឬការគំរាមកំហែងធ្វើឱ្យមានផលប៉ះពាល់ដល់ឧស្សាហកម្មក្នុងស្រុករបស់ភាគីនោះ។

(ខ) ភាគីម្ខាងដែលមានបំណងព្យួរការអនុវត្តមាត្រា៣.៥ អនុលោមតាមវាក្យខណ្ឌ(ក) ត្រូវជូនដំណឹងទៅភាគីម្ខាងទៀត ២ខែ មុនការចាប់ផ្តើមនៃរយៈពេលព្យួរ និងផ្តល់ឱកាសឱ្យភាគីម្ខាងទៀតក្នុងការពិភាក្សាទាក់ទងនឹងការព្យួរដែលបានស្នើសុំ។

(គ) អំឡុងពេលដែលបានលើកឡើងនៅក្នុងវាក្យខណ្ឌ(ក) អាចត្រូវពន្យារពេល ប្រសិនបើភាគីម្ខាងដែលបានអនុវត្តការព្យួរនោះកំណត់ថា ការបន្តព្យួរនោះនៅតែចាំបាច់ដើម្បីការគាំពារឬដោះស្រាយផលប៉ះពាល់។

(ឃ) ក្នុងកាលៈទេសៈធ្ងន់ធ្ងរ នៅពេលដែលការពន្យាពេលអាចនឹងបង្កឱ្យមានការខូចខាតដែលពិបាកក្នុងការប៉ះប៉ូវ ការព្យួរការអនុវត្តនៃមាត្រា៣.៥ ក្រោមវាក្យខណ្ឌ(ក) អាចត្រូវបានអនុវត្តជាបណ្តោះអាសន្ន ដោយគ្មានការជូនដំណឹង ពីរខែជាមុនទៅភាគីម្ខាងទៀត ក្នុងលក្ខខណ្ឌដែល ការជូនដំណឹងនឹងត្រូវបានធ្វើឡើងមុនពេលការព្យួរនោះមានប្រសិទ្ធភាព។

(ង) នៅពេលភាគីម្ខាងបានកំណត់ក្នុងវាក្យខណ្ឌ(ក) និងតម្រូវការដូចមានចែងក្នុងវាក្យខណ្ឌ (ខ) ត្រូវបានបំពេញ ភាគីពាក់ព័ន្ធនោះអាចព្យួរការអនុវត្តមាត្រា៣.៥ ជាឯកតោភាគី និងដោយគ្មានលក្ខខណ្ឌ ដោយៈ
   (១) មិនមានកាតព្វកិច្ចដើម្បីបញ្ជាក់ថាមានផលប៉ះពាល់ធ្ងន់ធ្ងរ
   (២) មិនមានកាតព្វកិច្ចត្រូវធ្វើកិច្ចពិគ្រោះយោបល់ជាមុន
   (៣) មិនមានការកំណត់រយៈពេល ឬចំនួននៃការព្យួរ និង
   (៤) មិនមានកាតព្វកិច្ចត្រូវផ្តល់សំណង។

## ៤. ការពិនិត្យឡើងវិញប្រចាំឆ្នាំ

(ក) ភាគីម្ខាងនោះត្រូវធ្វើការពិនិត្យឡើងវិញលើការអនុវត្ត និងប្រតិបត្តិការនៃមាត្រា៣.៥ ដោយគណៈកម្មាធិការចម្រុះ។ សម្រាប់គោលបំណងនេះៈ
   (១) ភាគីនាំចេញត្រូវផ្តល់ជូនគណៈកម្មាធិការចម្រុះនូវរបាយការណ៍អង្គហេតុសង្ខេបស្តីពីប្រតិបត្តិការនៃមាត្រា៣.៥ រួមទាំងស្ថិតិនាំចេញទំនិញនីមួយៗ ដែលមានក្នុងបញ្ជីក្នុងកថាខណ្ឌ៧ ដល់ភាគីនាំចូលក្នុងរយៈពេលមួយឆ្នាំកន្លងមក និង
   (២) ភាគីនាំចូល ត្រូវផ្តល់ជូនតាមការស្នើសុំរបស់គណៈកម្មាធិការចម្រុះនូវព័ត៌មានពាក់ព័ន្ធនឹងការបដិសេធ ចំពោះការសុំប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ប្រសិនបើមាន រួមទាំងចំនួនវិញ្ញាបនបត្រដើមកំណើតដែលត្រូវបានបដិសេធមិនបានទទួលយក និងហេតុផលសម្រាប់ការបដិសេធ។

(ខ) គណៈកម្មាធិការចម្រុះអាចស្នើសុំព័ត៌មានបន្ថែម ដែលអាចចាត់ទុកថាជាការចាំបាច់សម្រាប់ការពិនិត្យឡើងវិញនៃការអនុវត្តនិងប្រតិបត្តិការមាត្រា៣.៥ ពីភាគីនាំចេញ។

(គ) ដោយពិចារណាលើលទ្ធផលនៃការពិនិត្យឡើងវិញ ដែលមានចែងក្នុងវាក្យខណ្ឌ (ក) គណៈកម្មាធិការចម្រុះអាចផ្តល់អនុសាសន៍ ដែលអាចចាត់ទុកថាជាការចាំបាច់។

## ៥. ការដោះស្រាយវិវាទ

រាល់វិវាទណាមួយទាក់ទងនឹងការបកស្រាយ ការអនុវត្ត ឬការប្រើឧបសម្ព័ន្ធនេះ មិនត្រូវយកមកអនុវត្ត ចំពោះនីតិវិធីនានា និងយន្តការ ដូចមានចែងក្នុងជំពូកទី៨ (ការដោះស្រាយវិវាទ) ឡើយ។

## ៦. ការពាក់ព័ន្ធនឹងបញ្ញត្តិដទៃទៀតនៃកិច្ចព្រមព្រៀងនេះ

គ្មានបញ្ញត្តិណាមួយក្នុងឧបសម្ព័ន្ធនេះ ត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ក្រោមកិច្ចព្រមព្រៀងនេះឡើយ រួមទាំងមាត្រា៥.២ (ការអនុវត្តវិធានការការពារ)។

## ៧. បញ្ជីទំនិញ

ខាងក្រោមនេះត្រូវជាបញ្ជីទំនិញដែលស្ថិតនៅក្រោមឧបសម្ព័ន្ធនេះ។ ភាគីម្ខាងអាចស្នើសុំធ្វើវិសោធនកម្មបញ្ជីទំនិញ ក្នុងកថាខណ្ឌនេះ ដែលភាគីម្ខាងទៀតត្រូវពិចារណាដោយសុចរិត និងស្មោះត្រង់។ ការធ្វើវិសោធនកម្មនេះត្រូវអនុម័តនៅពេលមានការឯកភាពពីគូភាគី។

| No | HS 2002 | Description of Goods |
|---|---|---|
| 1 | 2923.90 | - Other |
| 2 | 3907.10 | - Polyacetals |
| 3 | 3907.20 | - Other polyethers |
| 4 | 3908.10 | - Polyamide -6, -11, -12, -6,6, -6,9, -6,10 or -6,12 |
| 5 | 3910.00 | Silicones in primary forms |
| 6 | 3923.10 | - Boxes, cases, crates and similar articles |
| 7 | 3923.30 | - Carboys, bottles, flasks and similar articles |
| 8 | 3923.50 | - Stoppers, lids, caps and other closures |
| 9 | 3923.90 | - Other |
| 10 | 3926.90 | - Other |
| 11 | 6107.11 | - - Of cotton |
| 12 | 6107.12 | - - Of man-made fibres |
| 13 | 6107.19 | - - Of other textile materials |
| 14 | 6107.91 | - - Of cotton |
| 15 | 6107.92 | - - Of man-made fibres |
| 16 | 6107.99 | - - Of other textile materials |
| 17 | 6108.21 | - - Of cotton |
| 18 | 6108.22 | - - Of man-made fibres |
| 19 | 6108.29 | - - Of other textile materials |
| 20 | 6108.91 | - - Of cotton |
| 21 | 6108.92 | - - Of man-made fibres |
| 22 | 6108.99 | - - Of other textile materials |
| 23 | 6111.20 | - Of cotton |
| 24 | 6114.20 | - Of cotton |
| 25 | 6115.19 | - - Of other textile materials |
| 26 | 6115.20 | - Women's full-length or knee-length hosiery, measuring per single yarn less than 67 decitex |
| 27 | 6115.92 | - - Of cotton |
| 28 | 6115.93 | - - Of synthetic fibres |
| 29 | 6115.99 | - - Of other textile materials |
| 30 | 6117.10 | - Shawls, scarves, mufflers, mantillas, veils and the like |
| 31 | 6117.20 | - Ties, bow ties and cravats |

| | | |
|---|---|---|
| 32 | 6117.90 | - Parts |
| 33 | 6201.11 | - - Of wool of fine animal hair |
| 34 | 6201.12 | - - Of cotton |
| 35 | 6201.13 | - - Of man-made fibres |
| 36 | 6201.92 | - - Of cotton |
| 37 | 6201.93 | - - Of man-made fibres |
| 38 | 6202.12 | - - Of cotton |
| 39 | 6202.13 | - - Of man-made fibres |
| 40 | 6202.92 | - - Of cotton |
| 41 | 6202.93 | - - Of man-made fibres |
| 42 | 6203.12 | - - Of synthetic fibres |
| 43 | 6203.19 | - - Of other textile materials |
| 44 | 6203.21 | - - Of wool or fine animal hair |
| 45 | 6203.31 | - - Of wool or fine animal hair |
| 46 | 6203.32 | - - Of cotton |
| 47 | 6203.33 | - - Of synthetic fibres |
| 48 | 6203.42 | - - Of cotton |
| 49 | 6203.43 | - - Of synthetic fibres |
| 50 | 6203.49 | - - Of other textile materials |
| 51 | 6204.11 | - - Of wool or fine animal hair |
| 52 | 6204.12 | - - Of cotton |
| 53 | 6204.13 | - - Of synthetic fibres |
| 54 | 6204.31 | - - Of wool or fine animal hair |
| 55 | 6204.32 | - - Of cotton |
| 56 | 6204.33 | - - Of synthetic fibres |
| 57 | 6204.39 | - - Of other textile materials |
| 58 | 6204.41 | - - Of wool or fine animal hair |
| 59 | 6204.42 | - - Of cotton |
| 60 | 6204.43 | - - Of synthetic fibres |
| 61 | 6204.44 | - - Of artificial fibres |
| 62 | 6204.49 | - - Of other textile materials |
| 63 | 6204.51 | - - Of wool or fine animal hair |
| 64 | 6207.21 | - - Of cotton |
| 65 | 6212.10 | - Brassières |
| 66 | 6212.20 | - Girdles and panty-girdles |
| 67 | 6212.90 | - Other |
| 68 | 6213.10 | - Of silk or silk waste |
| 69 | 6213.20 | - Of cotton |
| 70 | 6401.10 | - Footwear incorporating a protective metal toe-cap |
| 71 | 6401.91 | - - Covering the knee |
| 72 | 6401.92 | - - Covering the ankle but not covering the knee |
| 73 | 6401.99 | - - Other |
| 74 | 6402.12 | - - Ski-boots, cross-country ski footwear and snowboard boots |
| 75 | 6402.19 | - - Other |
| 76 | 6402.20 | - Footwear with upper straps or thongs assembled to the sole by means of plugs |
| 77 | 6402.30 | - Other footwear, incorporating a protective metal toe-cap |
| 78 | 6402.91 | - - Covering the ankle |
| 79 | 6402.99 | - - Other |
| 80 | 6403.12 | - - Ski-boots, cross-country ski footwear and snowboard boots |
| 81 | 6403.19 | - - Other |
| 82 | 6403.20 | - Footwear with outer soles of leather, and uppers which consist of leather straps across the instep and around the big toe |

| | | |
|---|---|---|
| 83 | 6403.30 | - Footwear made on a base or platform of wood, not having an inner sole or a protective metal toe-cap |
| 84 | 6403.40 | - Other footwear, incorporating a protective metal toe-cap |
| 85 | 6403.51 | - - Covering the ankle |
| 86 | 6403.59 | - - Other |
| 87 | 6403.91 | - - Covering the ankle |
| 88 | 6403.99 | - - Other |
| 89 | 6404.11 | - - Sports footwear; tennis shoes, basketball shoes, gym shoes, training shoes and the like |
| 90 | 6404.19 | - - Other |
| 91 | 6404.20 | - Footwear with outer soles of leather or composition leather |
| 92 | 6405.10 | - With uppers of leather or composition leather |
| 93 | 6405.20 | - With uppers of textile materials |
| 94 | 6405.90 | - Other |
| 95 | 6406.10 | - Uppers and parts thereof, other than stiffeners |
| 96 | 6406.20 | - Outer soles and heels, of rubber or plastics |
| 97 | 6406.91 | - - Of wood |
| 98 | 6406.99 | - - Of other materials |
| 99 | 7015.10 | - Glasses for corrective spectacles |
| 100 | 8413.30 | - Fuel, lubricating or cooling medium pumps for internal combustion piston engines |

# ឧបសម្ព័ន្ធ ៣-គ
# តម្រូវការព័ត៌មានអប្បបរមា

១. វិញ្ញាបនបត្រដើមកំណើត

(ក) ឈ្មោះ និងអាសយដ្ឋានរបស់អ្នកនាំចេញ

(ខ) ឈ្មោះ និងអាសយដ្ឋានរបស់ផលិតករ ប្រសិនបើមាន

(គ) ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទទួល ឬអ្នកនាំចូល

(ឃ) ការពិពណ៌នានៃទំនិញ និងលេខកូដ HS របស់ទំនិញ (ក្នុងកម្រិត ៦ ខ្ទង់)

(ង) លេខយោងវិញ្ញាបនបត្រដើមកំណើត

(ច) លក្ខណៈវិនិច្ឆ័យដើមកំណើត

(ឆ) សេចក្តីប្រកាសរបស់អ្នកនាំចេញ ឬផលិតករ

(ជ) ការបញ្ជាក់ធ្វើឡើងដោយស្ថាប័នចេញវិញ្ញាបនបត្រថា ទំនិញដែលមាននៅក្នុងវិញ្ញាបនបត្រដើមកំណើតបានបំពេញតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធទាំងអស់នៃជំពូកទី៣ (វិធានដើមកំណើត) ផ្អែកលើឯកសារសំអាងដែលបានផ្តល់ជាមួយហត្ថលេខាដែលទទួលបានសិទ្ធិ និងត្រាផ្លូវការរបស់ស្ថាប័នចេញវិញ្ញាបនបត្រ

(ឈ) ប្រទេសដើមកំណើត

(ញ) ព័ត៌មានលម្អិតដើម្បីកំណត់ការដឹកជញ្ជូនដូចជា លេខវិក្កយបត្រ កាលបរិច្ឆេទចេញដំណើរ ឈ្មោះរបស់នាវា ឬលេខជើងហោះហើរយន្តហោះ និងកំពង់ផែផ្ទេរទំនិញ

(ដ) តម្លៃ FOB នៅពេលដែលលក្ខណៈវិនិច្ឆ័យដើមកំណើតសមាសភាគតម្លៃតំបន់ ត្រូវបានប្រើប្រាស់ និង

(ឋ) បរិមាណនៃទំនិញ។

២. ប្រតិវេទន៍ដើមកំណើត

(ក) ឈ្មោះ និងអាសយដ្ឋានរបស់អ្នកនាំចេញ

(ខ) ឈ្មោះ និងអាសយដ្ឋានរបស់ផលិតករ ប្រសិនបើមាន

(គ) ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទទួល ឬអ្នកនាំចូល

(ឃ) ការពិពណ៌នានៃទំនិញ និងលេខកូដ HS របស់ទំនិញ (ក្នុងកម្រិត ៦ ខ្ទង់)

(ង) ក្នុងករណីអ្នកនាំចេញទទួលបានសិទ្ធិអនុញ្ញាត លេខកូដសម្គាល់សិទ្ធិ

(ច) លេខយោងពិសេស

(ឆ) លក្ខណៈវិនិច្ឆ័យដើមកំណើត

(ជ) ការបញ្ជាក់ ធ្វើឡើងដោយហត្ថលេខីទទួលបានសិទ្ធិ ថាទំនិញដែលមាននៅក្នុងប្រតិវេទន៍ដើមកំណើត បានបំពេញតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធទាំងអស់នៃជំពូកទី៣ (វិធានដើមកំណើត)

(ឈ) ប្រទេសដើមកំណើត

(ញ) តម្លៃ FOB នៅពេលដែលលក្ខណៈវិនិច្ឆ័យដើមកំណើតសមាសភាគតម្លៃតំបន់ ត្រូវបានប្រើប្រាស់ និង

(ដ) បរិមាណនៃទំនិញ។

## ឧបសម្ព័ន្ធ ៣-ឃ
## វិញ្ញាបនបត្រដើមកំណើត
(ច្បាប់ដើម/ច្បាប់ចម្លងទី២/ច្បាប់ចម្លងលើកទី៣)

<table>
<tr><td>១. ឈ្មោះ និងអាសយដ្ឋានអ្នកនាំចេញ</td><td rowspan="3">លេខយោងវិញ្ញាបនបត្រដើមកំណើត<br>កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ<br>វិញ្ញាបនបត្រដើមកំណើតសម្រាប់អត្រាពន្ធអនុគ្រោះ<br>(រួមបញ្ចូលទាំងសេចក្តីប្រកាស និងវិញ្ញាបនបត្រ)<br><br>ទម្រង់ CK<br>ធ្វើឡើងនៅ.................................................<br>(ប្រទេស)<br><br>សូមពិនិត្យមើលកំណត់សម្គាល់នៅទំព័រខាងខ្នង</td></tr>
<tr><td>២. ឈ្មោះ និងអាសយដ្ឋានផលិតករ ប្រសិនបើដឹង</td></tr>
<tr><td>៣. ឈ្មោះ និងអាសយដ្ឋានអ្នកនាំចូល ឬអ្នកទទួលទំនិញ</td></tr>
<tr><td>៤. មធ្យោបាយដឹកជញ្ជូន និងតម្រាយផ្លូវ (លម្អិតតាមដែលដឹង)<br><br>កាលបរិច្ឆេទចេញដំណើរ<br><br>ឈ្មោះរបស់នាវា/យន្តហោះ ល-<br><br>កំពង់ផែដាក់ទំនិញចុះ</td><td>៥. សម្រាប់ការប្រើប្រាស់ជាផ្លូវការ<br><br>☐ ត្រូវបានផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ<br><br>☐ មិនត្រូវបានផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ (សូមបញ្ជាក់នូវហេតុផល)<br><br>......................................................................................<br>ហត្ថលេខា របស់ហត្ថលេខីដែលទទួលបានសិទ្ធិរបស់ភាគីនាំចូល</td></tr>
</table>

| ៦.លេខរៀងទំនិញ | ៧. ម៉ាកសញ្ញា និងចំនួនលើកញ្ចប់ | ៨. ចំនួន និងប្រភេទនៃកញ្ចប់, ការបរិយាយនៃផលិតផល (រួមមានបរិមាណ ប្រសិនបើមាន និងលេខកូដ HS នៃប្រទេសនាំចូល) | ៩. លក្ខណៈវិនិច្ឆ័យដើមកំណើត (សូមពិនិត្យមើលកំណត់សម្គាល់នៅទំព័រខាងខ្នង) | ១០. ទម្ងន់សរុប ឬបរិមាណផ្សេងទៀត និងតម្លៃ (FOB តែនៅពេលដែលលក្ខណៈវិនិច្ឆ័យដើមកំណើតសមាសភាគតម្លៃតំបន់ (RVC) ត្រូវបានប្រើប្រាស់) | ១១. លេខ និងកាលបរិច្ឆេទវិក្កយបត្រ |
|---|---|---|---|---|---|
| | | | | | |

| ១២. សេចក្ដីប្រកាសរបស់អ្នកនាំចេញ | ១៣. ការបញ្ជាក់វិញ្ញាបនបត្រ |
|---|---|
| ហត្ថលេខាខាងក្រោមនេះអះអាងថា ព័ត៌មានលម្អិត និងសេចក្ដីប្រកាសខាងលើពិតជាគឺត្រឹមត្រូវ និងបញ្ជាក់ថាទំនិញទាំងអស់ត្រូវបានផលិតក្នុង<br><br>.............................................................<br>(ប្រទេស)<br><br>ហើយដែលបានអនុលោមតាមលក្ខខណ្ឌដើមកំណើតតម្រូវដែលបានចែងសម្រាប់ ទំនិញទាំងនេះ ក្នុងតារាងអនុគ្រោះពន្ធ នៃតំបន់ពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ សម្រាប់ទំនិញដែលត្រូវបាននាំចេញទៅកាន់<br><br>.............................................................<br>(ប្រទេសនាំចូល) | ផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យដែលបានអនុវត្ត វិញ្ញាបនបត្រនេះបញ្ជាក់ថា សេចក្ដីប្រកាសរបស់អ្នកនាំចេញគឺត្រឹមត្រូវ<br><br>.............................................................................<br>ទីកន្លែង និងកាលបរិច្ឆេទ ហត្ថលេខា និងត្រារបស់អាជ្ញាធរដែលទទួលបានសិទ្ធិ |

| | |
|---|---|
| ..............................................................<br>ទីកន្លែង និងកាលបរិច្ឆេទ ហត្ថលេខា<br>របស់ហត្ថលេខីដែលទទួលបានសិទ្ធិ | |
| ១៤. វិក្កយបត្រចេញដោយភាគីទីបី | |

## កំណត់សម្គាល់នៅទំព័រខាងខ្នង

១. ភាគីដែលទទួលយកទម្រង់នេះក្នុងគោលបំណងអនុវត្តប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ (CKFTA)៖ ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ។

២. លក្ខខណ្ឌ៖ ដើម្បីទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ក្រោមកិច្ចព្រមព្រៀង CKFTA ទំនិញដែលបញ្ជូនទៅភាគីណាមួយដែលបានរៀបរាប់ខាងលើ៖

(i) ត្រូវចូលក្នុងការបរិយាយទំនិញដែលមានលក្ខណៈគ្រប់គ្រាន់អាចទទួលបានការអនុគ្រោះនៅក្នុងប្រទេសគោលដៅចុងក្រោយ

(ii) ត្រូវគោរពតាមលក្ខខណ្ឌដឹកជញ្ជូន អនុលោមតាមមាត្រា៣.៩ នៃជំពូកទី៣ (វិធានដើមកំណើត) នៃកិច្ចព្រមព្រៀង CKFTA និង

(iii) ត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យដើមកំណើតក្នុងជំពូកទី៣ (វិធានដើមកំណើត) នៃកិច្ចព្រមព្រៀង CKFTA

៣. លក្ខណៈវិនិច្ឆ័យដើមកំណើត៖ សម្រាប់ទំនិញដែលបំពេញលក្ខណៈវិនិច្ឆ័យដើមកំណើត អ្នកនាំ-ចេញ និង/ឬផលិតករត្រូវបង្ហាញក្នុងប្រអប់ ៩ នៃទម្រង់នេះតាមរបៀបដូចក្នុងតារាងខាងក្រោម៖

| ស្ថានភាពនៃការផលិត ឬកែច្នៃនៅក្នុងប្រទេសទីមួយ ដូចមានក្នុងប្រអប់១២ នៃទម្រង់នេះ | បង្ហាញក្នុងប្រអប់ ៩ |
|---|---|
| (ក) ទំនិញដែលទទួលបានទាំងស្រុង ឬផលិតទាំងស្រុងនៅក្នុងតំបន់នៃភាគីនាំចេញ ដូចមានចែងនិងកំណត់ក្នុងមាត្រា៣.៣ នៃជំពូកនេះ | WO |
| (ខ) ទំនិញដែលផលិតក្នុងតំបន់នៃភាគីនាំចេញមួយទាំងស្រុង ពីវត្ថុធាតុមានដើមកំណើត | PE |
| (គ) ទំនិញដែលបំពេញតាមវិធានជាក់លាក់សម្រាប់ផលិតផល (PSR)<br>- ការផ្លាស់ប្តូរចំណាត់ថ្នាក់ទំនិញ<br>- សមាសភាគតម្លៃតំបន់<br>- ការផ្លាស់ប្តូរចំណាត់ថ្នាក់ទំនិញ + សមាសភាគតម្លៃតំបន់<br>- ដំណើរការជាក់លាក់ | -CTC<br>-RVC ក្នុងកម្រិតដែលអាចឱ្យទំនិញទទួលបានដើមកំណើត ឧទាហរណ៍ "RVC 45%"<br>-ការរួមបញ្ចូលគ្នានៃវិធានដែលតម្រូវឱ្យទំនិញទទួលបានដើមកំណើត ឧ. " CTH+ RVC 40%"<br>-ដំណើរការជាក់លាក់ |
| (ឃ) ទំនិញដែលគោរពតាមមាត្រា៣.៥ នៃជំពូកទី៣ | មាត្រា៣.៥ |

៤. វត្ថុនីមួយៗត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់៖ គួរកត់សម្គាល់ថា រាល់ទំនិញទាំងអស់ដែលមាននៅក្នុងជើងដឹកជញ្ជូនត្រូវតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រៀងៗខ្លួន។ នេះគឺទាក់ទងជាពិសេសនៅពេលទំនិញប្រហាក់ប្រហែលគ្នាដែលមានទំហំខុសគ្នា ឬគ្រឿងបន្លាស់ ត្រូវបានដឹកជញ្ជូន។

៥. ការពិពណ៌នាអំពីទំនិញ៖ ការពិពណ៌នាអំពីទំនិញ ត្រូវតែមានលក្ខណៈលំអិតគ្រប់គ្រាន់ដើម្បីឱ្យទំនិញនេះត្រូវបានកំណត់អត្តសញ្ញាណដោយមន្ត្រីគយដើម្បីត្រួតពិនិត្យ។ ម៉ាកពាណិជ្ជកម្មផ្សេងៗក៏ត្រូវបានបញ្ជាក់ផងដែរ។

៦. តម្លៃ FOB៖ តម្លៃ FOB នៅក្នុងប្រអប់ ១០ ត្រូវបង្ហាញតែក្នុងករណីដែលលក្ខណៈវិនិច្ឆ័យសមាសភាគតម្លៃតំបន់ត្រូវបានអនុវត្ត ក្នុងការកំណត់ដើមកំណើតទំនិញ។

៧. លេខកូដតាមប្រព័ន្ធសុខដុមនីយកម្ម៖ លេខកូដតាមប្រព័ន្ធសុខដុមនីយកម្ម (កម្រិត ៦ខ្ទង់) ត្រូវកំណត់តាមភាគីនាំចូល។

៨. "អ្នកនាំចេញ"៖ ពាក្យ "អ្នកនាំចេញ" ក្នុងប្រអប់ ១២ រាប់បញ្ចូលទាំងឧស្សាហករ ឬផលិតករ។

៩. សម្រាប់ប្រើប្រាស់ផ្លូវការ៖ អាជ្ញាធរគយនៃភាគីនាំចូលត្រូវគូស (√) ក្នុងប្រអប់៥ ដើម្បីបញ្ជាក់ថាប្រព្រឹត្តិកម្មអនុគ្រោះពន្ធត្រូវបានឬមិនត្រូវបានផ្តល់ឱ្យ។

១០. វិក្កយបត្រចេញដោយភាគីទីបី៖ ក្នុងករណីដែលវិក្កយបត្រត្រូវបានចេញដោយភាគីទីបី ប្រអប់ "វិក្កយបត្រចេញដោយភាគីទីបី" តម្រូវឱ្យមានគូស (√) និងព័ត៌មានដូចជា ឈ្មោះ និងប្រទេសរបស់ក្រុមហ៊ុនដែលចេញវិក្កយបត្រ ត្រូវបង្ហាញក្នុងប្រអប់ ៨។

**ឧបសម្ព័ន្ធ ៣-ខ**

**គម្រូទម្រង់ប្រតិវេទន៍ដើមកំណើត**

ប្រតិវេទន៍ដើមកំណើត

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ

| | | | | | |
|---|---|---|---|---|---|
| ១. ឈ្មោះ និងអាសយដ្ឋានអ្នកនាំចេញ<br>លេខទូរសព្ទ៖ ទូរសារ៖ អ៊ីម៉ែល៖<br>លេខកូដសម្គាល់អ្នកនាំចេញទទួលបានសិទ្ធិ៖ លេខយោង៖ | | | | | |
| ២. ឈ្មោះ និងអាសយដ្ឋានផលិតករ (ប្រសិនបើដឹង)<br>លេខទូរសព្ទ៖ ទូរសារ៖ អ៊ីម៉ែល៖ | | | | | |
| ៣ ឈ្មោះ និងអាសយដ្ឋានអ្នកនាំចូល ឬអ្នកដឹកជញ្ជូន៖<br>លេខទូរសព្ទ៖ ទូរសារ៖ អ៊ីម៉ែល៖ | | | | | |
| ៤.ការបរិយាយទំនិញ (រួមបញ្ចូលទាំងលេខវិក្កយបត្រនិងបរិមាណ) | ៥. ចំណាត់ថ្នាក់ទំនិញតាមប្រព័ន្ធ HS | ៦.លក្ខណៈវិនិច្ឆ័យដើមកំណើត | ៧. អ្នកផលិត | ៨. តម្លៃ FOB តែក្នុងករណីលក្ខណៈវិនិច្ឆ័យសមាសភាគតម្លៃក្នុងតំបន់ត្រូវបានប្រើប្រាស់ | ៩.ប្រទេសដើមកំណើត |
| | | | | | |
| ១០. ការអង្កេត /ការរកឃើញ៖ | | | | | |

ខ្ញុំសូមបញ្ជាក់ថា៖

- ព័ត៌មាននៅក្នុងឯកសារនេះពិតជាត្រឹមត្រូវ និងច្បាស់លាស់ ហើយខ្ញុំសូមទទួលខុសត្រូវចំពោះការបញ្ជាក់នៃអំណះអំណាងនេះ។ ខ្ញុំបានយល់ថាខ្ញុំត្រូវទទួលខុសត្រូវចំពោះមុខច្បាប់លើសេចក្តីប្រកាសមិនពិតទាំងឡាយ ឬកង្វះព័ត៌មានសំខាន់ពាក់ព័ន្ធនឹងឯកសារនេះ។
- ខ្ញុំយល់ព្រមរក្សាទុក និងបង្ហាញក្នុងករណីតម្រូវ នូវឯកសារចាំបាច់ទាំងឡាយដែលគាំទ្រការប្រកាសនេះ និងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរាល់អ្នកដែលទទួលប្រតិវេទន៍នេះ នូវរាល់ការផ្លាស់ប្តូរដែលប៉ះពាល់ដល់ភាពត្រឹមត្រូវ និងសុពលភាពនៃប្រតិវេទន៍នេះ។
- ទំនិញនេះទទួលបានដើមកំណើតនៅក្នុងដែនរបស់ភាគីនាំចេញ និងអនុលោមតាមលក្ខខណ្ឌតម្រូវដើម្បីទទួលបានដើមកំណើតដែលមានចែងជាក់លាក់ចំពោះទំនិញទាំងនោះនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ។
  ការប្រកាសនេះមានចំនួន ______ ទំព័រ រាប់បញ្ចូលឯកសារភ្ជាប់ទាំងអស់។

| | |
|---|---|
| | |
| ១១. ហត្ថលេខាទទួលស្គាល់របស់ក្រុមហ៊ុន៖ | ក្រុមហ៊ុន៖ |
| ឈ្មោះ៖ | តួនាទី៖ |
| ឆ្នាំ ខែ ថ្ងៃ<br>កាលបរិច្ឆេទ៖............../................./................ | លេខទូរសព្ទ៖<br>ទូរសារ៖ |

# សេចក្តីណែនាំសម្រាប់ការបំពេញប្រតិវេទន៍ដើមកំណើត

នៅពេលដែលអ្នកនាំចេញជ្រើសរើសយកការធ្វើប្រតិវេទន៍ ដើម្បីជាសំអាងដើមកំណើត សេចក្តីណែនាំខាងក្រោមនឹងជាជំនួយក្នុងការបំពេញទម្រង់បែបបទនេះ។

សម្រាប់គោលបំណងដើម្បីទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ឯកសារនេះត្រូវបំពេញឱ្យបានពេញលេញ និងត្រឹមត្រូវក្នុងទម្រង់សរសេរដោយដៃ ឬវាយអត្ថបទកុំព្យូទ័រដោយអ្នកនាំចេញក្នុងនាមអ្នកនាំចូល នៅពេលប្រកាសអនុលោមតាមមាត្រា៣.២០.២(ខ)។ ប្រសិនបើត្រូវការកន្លែងបន្ថែម អាចប្រើប្រាស់ទំព័រថ្មីបាន។

ប្រអប់ ១៖ បញ្ជាក់ឈ្មោះផ្លូវការពេញ អាសយដ្ឋាន (រួមបញ្ចូលទីក្រុង និងប្រទេស) លេខទូរសព្ទ, ទូរសារ, អ៊ីម៉ែល, លេខសម្គាល់អ្នកនាំចេញទទួលបានសិទ្ធិរបស់អ្នកនាំចេញ ព្រមទាំងបញ្ជាក់លេខយោងសម្គាល់របស់ ប្រតិវេទន៍ដើមកំណើតនោះ។

ប្រអប់ ២ (ជម្រើស)៖ ប្រសិនបើមានផលិតករតែមួយ បញ្ជាក់ឈ្មោះផ្លូវការពេញ, អាសយដ្ឋាន (រួមបញ្ចូលទីក្រុង និងប្រទេស) លេខទូរសព្ទ, ទូរសារ, អ៊ីម៉ែលរបស់ផលិតករ។ ប្រសិនបើមានផលិតករលើសពីមួយដាក់បញ្ចូលក្នុងប្រតិវេទន៍, ត្រូវបញ្ជាក់ថា "VARIOUS" និងដាក់ភ្ជាប់ជាមួយបញ្ជីរបស់ អ្នកផលិតទាំងនោះ រួមបញ្ចូលទាំងឈ្មោះផ្លូវការ, អាសយដ្ឋាន (រួមបញ្ចូលទីក្រុង និងប្រទេស) លេខទូរសព្ទ, ទូរសារ, អ៊ីម៉ែល និងការយោងទៅទំនិញត្រូវគ្នាដែលរៀបរាប់ក្នុងប្រអប់៤។ ប្រសិនបើព័ត៌មានដែលផ្តល់ឱ្យគឺជាការសម្ងាត់ ពាក្យ "AVAILABLE UPON REQUEST" ត្រូវតែបញ្ជាក់។

ប្រអប់ ៣៖ បញ្ជាក់ឈ្មោះពេញផ្លូវការ, អាសយដ្ឋាន (រួមបញ្ចូលទីក្រុង និងប្រទេស) លេខទូរសព្ទ, ទូរសារ, អ៊ីម៉ែលរបស់អ្នកនាំចូល។

ប្រអប់ ៤៖ ផ្តល់ការបរិយាយទំនិញពេញលេញ។ ការបរិយាយត្រូវមានព័ត៌មានសំខាន់និងលម្អិតគ្រប់គ្រាន់ដើម្បីអាចត្រូវគ្នានឹងនឹងការបរិយាយទំនិញនៅក្នុងវិក្កយបត្រ និងការបរិយាយទំនិញតាមប្រព័ន្ធសុខដុមនីយកម្ម (HS)។ លេខវិក្កយបត្រដែលបង្ហាញក្នុងវិក្កយបត្រពាណិជ្ជកម្ម រួមមានបរិមាណទំនិញត្រូវតែបញ្ជាក់។ អ្នកនាំចេញអាច ចេញប្រតិវេទន៍ដើមកំណើត សម្រាប់តែទំនិញដែលទទួលបានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

ប្រអប់ ៥៖ សម្រាប់ទំនិញបរិយាយក្នុងប្រអប់ ៤, ចំណាត់ថ្នាក់ទំនិញតាមប្រព័ន្ធ HS ត្រូវបានកំណត់ក្នុងកម្រិត ៦ខ្ទង់ ។

ប្រអប់ ៦៖ សម្រាប់ទំនិញបរិយាយក្នុងប្រអប់ ៤ ត្រូវតែបញ្ជាក់លក្ខណៈវិនិច្ឆ័យដែលអាចប្រើប្រាស់បានដូចមានកំណត់ខាងក្រោម ។ វិធានដើមកំណើតដែលមានក្នុងជំពូកទី៣ (វិធានដើមកំណើត) និងឧបសម្ព័ន្ធ៣-ក (វិធានជាក់លាក់សម្រាប់ផលិតផល)

| ស្ថានភាពនៃការផលិត ឬកែច្នៃនៅក្នុងប្រទេសទីមួយ ដូចមានក្នុងប្រអប់ ១ | ដាក់ចូលក្នុងប្រអប់លេខ ៦ |
|---|---|
| (ក) ទំនិញដែលទទួលបានទាំងស្រុង ឬផលិតទាំងស្រុង នៅក្នុងតំបន់នៃភាគីនាំចេញ ដូចមានចែង និងកំណត់ក្នុងមាត្រា៣.៣ នៃជំពូកនេះ | "WO" |
| (ខ) ទំនិញដែលផលិតក្នុងតំបន់នៃភាគីនាំចេញមួយ ទាំងស្រុង ពីវត្ថុធាតុមានដើមកំណើត | "PE" |
| (គ) ទំនិញដែលបំពេញតាមវិធានជាក់លាក់សម្រាប់ផលិតផល (PSR)<br>- ការផ្លាស់ប្តូរចំណាត់ថ្នាក់ទំនិញ<br>- សមាសភាគតម្លៃតំបន់<br>- ការផ្លាស់ប្តូរចំណាត់ថ្នាក់ទំនិញ + សមាសភាគតម្លៃតំបន់<br>- ដំណើរការជាក់លាក់ | -"CTC"<br>-"RVC" ក្នុងកម្រិតដែលអាចឱ្យទំនិញទទួលបានដើមកំណើត ឧទាហរណ៍ "RVC 45%"<br>-ការរួមបញ្ចូលគ្នានៃវិធានដែលតម្រូវឱ្យទំនិញទទួលបានដើមកំណើត<br>ឧ. " CTH+ RVC 40%"<br>- "Specific Process" |
| (ឃ) ទំនិញដែលអនុមលោមតាមមាត្រា៣.៥ នៃជំពូក៣ (វិធានដើមកំណើត) | មាត្រា៣.៥ |

ប្រអប់ ៧៖ ចំពោះទំនិញបរិយាយក្នុងប្រអប់ ៤ ត្រូវដាក់ពាក្យ "YES" ប្រសិនបើអ្នកនាំចេញ គឺជាផលិតករនៃទំនិញ។ ប្រសិនបើអ្នកនាំចេញមិនមែនជាផលិតករនៃទំនិញ ត្រូវដាក់ពាក្យ "NO" និងត្រូវបន្ថែមដោយ (១) ឬ (២) អាស្រ័យលើថាតើប្រតិវេទន៍នេះផ្អែកលើ (១) ចំណេះដឹងពេញលេញរបស់ អ្នកនាំចេញ ថាទំនិញនេះមានឬគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាទំនិញមានដើមកំណើត (២) ការពឹងផ្អែករបស់អ្នកនាំចេញ លើការសរសេរជាលាយលក្ខណ៍អក្សររបស់ផលិតករជាតំណាង ថាទំនិញនេះមានលក្ខណៈសម្បត្តិជាទំនិញមានដើមកំណើត។

ប្រអប់ ៨៖ តម្លៃ FOB ត្រូវបង្ហាញតែក្នុងករណីតម្លៃសមាសភាគតំបន់ត្រូវបានប្រើប្រាស់សម្រាប់កំណត់ដើមកំណើតទំនិញ។

ប្រអប់ ៩៖ ឈ្មោះប្រទេសដើមកំណើតត្រូវកំណត់សម្រាប់ទំនិញមានដើមកំណើតទាំងអស់ សម្រាប់ភាគីកូរ៉េ (KR) និងភាគីកម្ពុជា (CA)។

ប្រអប់ ១០៖ ប្រអប់នេះអាចនឹងត្រូវប្រើ នៅពេលដែលការអង្កេត/ការរកឃើញ ពាក់ព័ន្ធនឹងការធ្វើប្រតិវេទន៍នេះ ដូចជា នៅពេលដែលទំនិញបរិយាយក្នុងប្រអប់ ៤ ជាកម្មវត្ថុនៃសេចក្តីសម្រេចវិធានបញ្ជាក់ជាមុន ឬសេចក្តីសម្រេចលើចំណាត់ថ្នាក់ទំនិញ ឬតម្លៃនៃវត្ថុធាតុ។ ស្ថាប័នចេញ វិញ្ញាបនបត្រ លេខយោង និងកាលបរិច្ឆេទ ត្រូវតែបញ្ជាក់។

ប្រអប់ ១១៖ ប្រអប់នេះត្រូវតែបំពេញអោយបានពេញលេញ ចុះហត្ថលេខា និងចុះកាលបរិច្ឆេទដោយហត្ថលេខីទទួលបានសិទ្ធិរបស់អ្នកនាំចេញ។ កាលបរិច្ឆេទដែលនឹងត្រូវបង្ហាញ ត្រូវតែជាកាលបរិច្ឆេទដែលប្រតិវេទន៍នេះបានបំពេញ និងចុះហត្ថលេខា។

## ជំពូកទី ៤
## នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម

### មាត្រា៤.១៖ និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ៖

(ក) **នីតិវិធីគយ** សំដៅដល់វិធានការទាំងឡាយ ដែលអនុវត្តដោយអាជ្ញាធរគយចំពោះទំនិញ និងមធ្យោបាយដឹកជញ្ជូន ដែលជាកម្មវត្ថុនៃច្បាប់ និងបទប្បញ្ញត្តិ និង

(ខ) **មធ្យោបាយដឹកជញ្ជូន** សំដៅដល់ប្រភេទនានានៃនាវា យានយន្ត និងអាកាសយានទាំងឡាយដែលចូល ឬចាកចេញពីដែនគយរបស់ភាគីម្ខាង ដែលមានផ្ទុកមនុស្ស ទំនិញ ឬវត្ថុផ្សេងៗ។

### មាត្រា៤.២៖ គោលបំណង

គោលបំណងជំពូកនេះ គឺដើម្បី៖

(ក) ធានាឱ្យបាននូវភាពអាចព្យាករណ៍បាន សង្គតិភាព និងតម្លាភាពក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិគយរបស់គូភាគី

(ខ) លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងអនុវត្តនីតិវិធីគយរបស់គូភាគី និងការបញ្ចេញទំនិញពីគយបានរហ័ស

(គ) សាមញ្ញកម្មនីតិវិធីគយរបស់គូភាគី និងសុខដុមនីយកម្មនីតិវិធីគយ តាមលទ្ធភាពដែលអាចធ្វើទៅបានស្របតាមបទដ្ឋានអន្តរជាតិពាក់ព័ន្ធ

(ឃ) លើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគយ និង

(ង) សម្រួលពាណិជ្ជកម្មរវាងគូភាគី ក៏ដូចជាតាមរយៈការពង្រឹងបរិយាកាសសម្រាប់ខ្សែច្រវាក់ផ្គត់ផ្គង់សកល និងតំបន់។

### មាត្រា៤.៣៖ វិសាលភាព

ជំពូកនេះត្រូវអនុវត្តចំពោះនីតិវិធីគយលើទំនិញដែលជួញដូររវាងគូភាគី និងលើមធ្យោបាយដឹកជញ្ជូននានាដែលចូល ឬចាកចេញពីដែនគយរបស់ភាគីនីមួយៗ។

### មាត្រា៤.៤៖ សង្គតិភាព

១. ភាគីនីមួយៗត្រូវធានាឱ្យបាននូវសង្គតិភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិគយទូទាំងដែនគយរបស់ខ្លួន។

២. ដើម្បីបំពេញកាតព្វកិច្ចក្នុងកថាខណ្ឌទី១ ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងអនុម័ត ឬរក្សាទុកនូវវិធានការរដ្ឋបាលដើម្បីធានានូវសង្គតិភាពក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិគយទូទាំងដែនគយរបស់ខ្លួន ដោយបង្កើតយន្តការរដ្ឋបាលដែលធានាបាននូវសង្គតិភាពក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិគយរបស់ភាគីនោះ ដោយបណ្តាការិយាល័យគយតំបន់របស់ខ្លួន។

**មាត្រា៤.៥៖ តម្លាភាព**

១. ភាគីនីមួយៗត្រូវផ្សព្វផ្សាយឱ្យបានឆាប់រហ័ស តាមប្រព័ន្ធអ៊ីនធឺណែតតាមដែលអាចធ្វើទៅបាន ដោយមិនលម្អៀង និងងាយស្រួលស្វែងរក ដើម្បីឱ្យរដ្ឋាភិបាល ពាណិជ្ជករនិងភាគីពាក់ព័ន្ធផ្សេងទៀត អាចស្វែងយល់នូវព័ត៌មានដូចខាងក្រោម៖

(ក) នីតិវិធីសម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់ (រាប់បញ្ចូលទាំងនីតិវិធីកំពង់ផែ អាកាសយានដ្ឋាន និងមាត់ច្រកផ្សេងទៀត) ព្រមទាំងទម្រង់បែបបទនិងឯកសារចាំបាច់នានា

(ខ) អត្រាពន្ធ និងអាករជាធរមាន ដែលអនុវត្តលើការនាំចូល ឬនាំចេញ

(គ) កម្រៃ និងបន្ទុកដែលបានកំណត់ដោយ ឬសម្រាប់ស្ថាប័នរដ្ឋាភិបាលលើ ឬទាក់ទងនឹងការនាំចូល ការនាំចេញ ឬឆ្លងកាត់

(ឃ) វិធានសម្រាប់ចំណាត់ថ្នាក់ ឬការកំណត់តម្លៃគិតពន្ធគយលើទំនិញសម្រាប់គោលបំណងគយ

(ង) ច្បាប់ បទប្បញ្ញត្តិ និងសេចក្តីសម្រេចរដ្ឋបាលនៃការអនុវត្តទូទៅពាក់ព័ន្ធនឹងវិធានដើមកំណើត

(ច) ការហាមឃាត់ ឬដាក់កម្រិតកំណត់លើការនាំចូល ការនាំចេញ ឬការឆ្លងកាត់

(ឆ) បញ្ញត្តិពិន័យសម្រាប់បទល្មើសនានាលើបែបបទនាំចូល នាំចេញ ឬឆ្លងកាត់

(ជ) នីតិវិធីសម្រាប់ការប្តឹងតវ៉ា ឬពិនិត្យឡើងវិញ

(ឈ) កិច្ចព្រមព្រៀងដែលជាភាគី ឬផ្នែកណាមួយនៃកិច្ចព្រមព្រៀង ជាមួយប្រទេសផ្សេងទៀតទាក់ទងនឹងការនាំចូល ការនាំចេញ ឬការឆ្លងកាត់ និង

(ច) នីតិវិធីទាក់ទងនឹងការគ្រប់គ្រងកូតាពន្ធ។

២. ជាពិសេស ភាគីនីមួយៗត្រូវធ្វើឱ្យមាន និងធ្វើបច្ចុប្បន្នភាពតាមដែលអាចធ្វើទៅបាន និងសមស្រប តាមរយៈអ៊ីនធឺណែត នូវព័ត៌មានដូចខាងក្រោម៖

(ក) ការពិពណ៌នា[1] អំពីនីតិវិធីសម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់ រួមទាំងនីតិវិធីសម្រាប់ការប្តឹងតវ៉ា ឬពិនិត្យឡើងវិញ ដែលជូនដំណឹងដល់រដ្ឋាភិបាល ពាណិជ្ជករ និងបុគ្គលពាក់ព័ន្ធផ្សេងទៀត អំពីនីតិវិធីជាក់ស្តែងសម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់

(ខ) ទម្រង់បែបបទនិងឯកសារនានាដែលតម្រូវសម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់តាមដែនដីរបស់ភាគីនោះ និង

(គ) ព័ត៌មានទំនាក់ទំនងសម្រាប់សាកសួរ ក៏ដូចជាព័ត៌មាន អំពីរបៀបនៃការស្នើសុំព័ត៌មានស្តីពីបញ្ហាគយដែលមានចែងក្នុងមាត្រា៤.៦ ។

៣. តាមលទ្ធភាពដែលអាចធ្វើទៅបាន នៅពេលបង្កើតថ្មី ឬធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិគយ ភាគីនីមួយៗត្រូវផ្សព្វផ្សាយ ឬផ្តល់នូវសំណើបង្កើត ឬធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិគយ

---

1 ភាគីនីមួយៗមានសិទ្ធិបញ្ជាក់លើគេហទំព័ររបស់ខ្លួន អំពីដែនស្របច្បាប់នៃការពិពណ៌នានេះ។

នោះ ជាមួយនឹងឱកាសសមស្របដល់បុគ្គលពាក់ព័ន្ធដើម្បីផ្តល់មតិយោបល់ លើកលែងតែការជូនដំណឹងជាមុននេះ ត្រូវបានហាមឃាត់។

## មាត្រា៤.៦៖ ចំណុចសាកសួរ

ភាគីរដ្ឋបាលគយនីមួយៗត្រូវកំណត់ចំណុចសាកសួរមួយ ឬច្រើនក្នុងការឆ្លើយតបលើការសាកសួរដោយសមហេតុផលរបស់បុគ្គលដែលចាប់អារម្មណ៍លើបញ្ហានានាពាក់ព័ន្ធនឹងគយ និងដើម្បីសម្របសម្រួលការប្រើប្រាស់ទម្រង់បែបបទ និងឯកសារតម្រូវនានា សម្រាប់ការនាំចូល ការនាំចេញ និងការឆ្លងកាត់។

## មាត្រា៤.៧៖ នីតិវិធីគយ

១. រដ្ឋបាលគយនីមួយៗត្រូវធានាថានីតិវិធីគយ និងការអនុវត្តរបស់ខ្លួន អាចព្យាករណ៍បាន មានសង្គតិភាព និងមានតម្លាភាព និងសម្រួលពាណិជ្ជកម្ម រាប់បញ្ចូលទាំងការបំពេញបែបបទបញ្ចេញទំនិញពីគយបានឆាប់រហ័ស។

២. រដ្ឋបាលគយនីមួយៗត្រូវធានាថានីតិវិធីគយរបស់ខ្លួន តាមលទ្ធភាពដែលអនុញ្ញាតដោយច្បាប់ និងបទប្បញ្ញត្តិគយរបស់ខ្លួន ដោយអនុលោមទៅតាមស្តង់ដារ និងការអនុវត្តអនុសាសន៍របស់អង្គការគយពិភពលោក។

៣. រដ្ឋបាលគយត្រូវពិនិត្យឡើងវិញនូវនីតិវិធីគយរបស់ខ្លួន ក្នុងគោលបំណងធ្វើសាមញ្ញកម្មនីតិវិធីនោះដើម្បីសម្រួលពាណិជ្ជកម្ម។

## មាត្រា៤.៨៖ ការត្រួតពិនិត្យទំនិញមុនដឹកជញ្ជូន

១. ភាគីនីមួយៗមិនត្រូវតម្រូវឱ្យមានការត្រួតពិនិត្យទំនិញមុនដឹកជញ្ជូន ពាក់ព័ន្ធទៅនឹងចំណាត់ថ្នាក់ទំនិញ និងតម្លៃគិតពន្ធគយឡើយ។

២. ដោយមិនប៉ះពាល់លើសិទ្ធិរបស់ភាគីណាមួយ ក្នុងការប្រើប្រាស់ប្រភេទផ្សេងទៀត នៃការត្រួតពិនិត្យទំនិញមុនដឹកជញ្ជូន ដែលមិនមានចែងក្នុងកថាខណ្ឌទី១ ភាគីនីមួយៗ ត្រូវបានលើកទឹកចិត្តដោយមិនឱ្យណែនាំ ឬអនុវត្តការតម្រូវថ្មីៗពាក់ព័ន្ធនឹងការប្រើប្រាស់របស់គូភាគី

៣. កថាខណ្ឌទី២ សំដៅដល់ការត្រួតពិនិត្យទំនិញមុនពេលដឹកជញ្ជូន ដែលស្ថិតក្រោមកិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យទំនិញមុនពេលដឹកជញ្ជូនក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោក និងមិនរារាំងការត្រួតពិនិត្យទំនិញមុនពេលដឹកជញ្ជូនក្នុងគោលបំណងពិនិត្យលើអនាម័យ និងភូតគាមអនាម័យ។

## មាត្រា៤.៩៖ វិធានបញ្ជាក់ជាមុន

១. មុនពេលនាំចូលទំនិញពីភាគីម្ខាងចូលទៅក្នុងដែនដីរបស់ខ្លួន ភាគីនីមួយៗត្រូវចេញវិធានបញ្ជាក់ជាមុនជាលាយលក្ខណ៍អក្សរដល់អ្នកនាំចូល អ្នកនាំចេញ ឬបុគ្គលណាមួយដែលមានមូលហេតុស្របច្បាប់ ឬអ្នកតំណាង ដែលបានដាក់ស្នើសុំជាលាយលក្ខណ៍អក្សរភ្ជាប់ដោយព័ត៌មានសំខាន់ៗ ទាក់ទងទៅនឹង៖

(ក) ចំណាត់ថ្នាក់ទំនិញ

(ខ) ថាតើទំនិញនោះជាទំនិញមានដើមកំណើត ដោយអនុលោមតាមជំពូកទី៣ (វិធានដើមកំណើតទំនិញ)

(គ) វិធីសាស្ត្រ ឬលក្ខខណ្ឌសមស្រប និងពាក្យស្នើសុំដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់តម្លៃគិតពន្ធគយ ស្ថិតក្រោមអង្គហេតុណាមួយ ដោយអនុលោមតាមកិច្ចព្រមព្រៀងស្តីពីតម្លៃគិតពន្ធគយ និង

(ឃ) បញ្ហាផ្សេងទៀត តាមការព្រមព្រៀងរវាងគូភាគី។

២. ភាគីម្ខាងអាចតម្រូវថាអ្នកដាក់ពាក្យស្នើសុំ មានអ្នកតំណាង ឬការចុះបញ្ជីស្របច្បាប់ក្នុងភាគីនោះ។ តាមលទ្ធភាពដែលអាចធ្វើទៅបាន ការតម្រូវទាំងនេះ មិនត្រូវរឹតត្បិតប្រភេទនៃបុគ្គលដែលមានសិទ្ធិស្នើសុំវិធានបញ្ជាក់ជាមុនឡើយ ជាមួយនឹងការពិចារណាសម្រាប់តម្រូវការជាក់លាក់របស់សហគ្រាសធុនតូច និងមធ្យម។ ការតម្រូវទាំងនេះ ត្រូវតែមានភាពច្បាស់លាស់ មានតម្លាភាព និងមិនបង្កើតជាមធ្យោបាយនៃការរំលោភអំណាច ឬការរើសអើងមិនសមហេតុផល។[2, 3]

៣. ភាគីនីមួយៗ ត្រូវអនុម័ត ឬប្រកាន់ខ្ជាប់នូវនីតិវិធីសម្រាប់ចេញវិធានបញ្ជាក់ជាមុនដែលៈ

(ក) កំណត់ជាក់លាក់នូវព័ត៌មានដែលតម្រូវ ដើម្បីស្នើសុំវិធានបញ្ជាក់ជាមុន

(ខ) ផ្តល់ថា ក្នុងអំឡុងពេលវាយតម្លៃលើការស្នើសុំវិធានបញ្ជាក់ជាមុន ភាគីនីមួយៗ អាចស្នើសុំឱ្យអ្នកដាក់ពាក្យ ផ្តល់ព័ត៌មានបន្ថែមដែលអាចរួមមាន គំរូនៃទំនិញ ដែលចាំបាច់ក្នុងការវាយតម្លៃលើការស្នើសុំ

(គ) ធានាថា វិធានបញ្ជាក់ជាមុន ត្រូវផ្អែកលើអង្គហេតុ និងកាលៈទេសៈ ដែលបានផ្តល់ដោយអ្នកដាក់ពាក្យស្នើសុំ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលអ្នកសម្រេចចិត្តមាន និង

(ឃ) ធានាថា វិធានបញ្ជាក់ជាមុន មានរាប់បញ្ចូលទាំងអង្គហេតុពាក់ព័ន្ធនានា និងមូលដ្ឋានសម្រាប់ការផ្តល់សម្រេច ។

៤. ភាគីនីមួយៗត្រូវចេញវិធានបញ្ជាក់ជាមុន ក្នុងរយៈពេល ៩០ថ្ងៃ ក្រោយទទួលបាននូវរាល់ព័ត៌មានចាំបាច់នានា។

៥. ភាគីម្ខាងអាចបដិសេធការចេញវិធានបញ្ជាក់ជាមុន ប្រសិនបើអង្គហេតុ និងកាលៈទេសៈដែលបង្កើតជាមូលដ្ឋាននៃវិធានបញ្ជាក់ជាមុន គឺជាកម្មវត្ថុលើការប្តឹងតវ៉ា តាមនីតិវិធីរដ្ឋបាល ឬតុលាការ។ ភាគីដែលបដិសេធការចេញវិធានបញ្ជាក់ជាមុន ត្រូវជូនដំណឹងដល់អ្នកស្នើសុំជាលាយលក្ខណ៍អក្សរភ្លាមៗ ដោយបញ្ជាក់ពីអង្គហេតុពាក់ព័ន្ធ កាលៈទេសៈ និងមូលដ្ឋាននៃការសម្រេចចិត្តរបស់ខ្លួន ក្នុងការបដិសេធការចេញវិធានបញ្ជាក់ជាមុន។

៦. ភាគីម្ខាងអាចបដិសេធលើពាក្យស្នើសុំវិធានបញ្ជាក់ជាមុន នៅពេលដែលព័ត៌មានស្នើសុំបន្ថែមជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងវាក្យខណ្ឌ ៣(ខ) ពុំបានផ្តល់ជូនក្នុងអំឡុងពេលសមស្របឬ ជាក់លាក់ណាមួយ ដែលកំណត់នៅពេលស្នើសុំព័ត៌មានបន្ថែមនោះនិងភាគីនោះ ស្នើសុំព័ត៌មានបន្ថែមជាលាយលក្ខណ៍អក្សរពីអ្នកដាក់ពាក្យ។

---

2 តាមការស្នើសុំរបស់ភាគីម្ខាង គូភាគីអាចត្រួតពិនិត្យឡើងវិញ នូវតម្រូវការនៃកថាខណ្ឌនេះទាក់ទងនឹងការចូលរួមចំណែករបស់ពួកគេ សំដៅដល់កិច្ចសម្រួលពាណិជ្ជកម្មតាមរយៈគណៈកម្មការ ស្តីពីវិធានដើមកំណើត និងនីតិវិធីគយ។

3 ភាគីនីមួយៗត្រូវធានាថាដំណើរការចុះឈ្មោះរបស់ខ្លួនមានតម្លាភាព ការដាក់ពាក្យសុំត្រូវបានពិចារណាឱ្យបានទាន់ពេលវេលា និងការសម្រេចចិត្តលើពាក្យសុំ និងហេតុផលសម្រាប់សេចក្តីសម្រេចនោះ ត្រូវបានផ្តល់ឱ្យអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ។

៧. ភាគីនីមួយៗត្រូវកំណត់សុពលភាពសម្រាប់វិធានបញ្ជាក់ជាមុន ក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការចេញវិធាននោះ។

៨. នៅពេលដែលភាគីម្ខាងដកហូត កែតម្រូវ ឬនិរាករណ៍វិធានបញ្ជាក់ជាមុនណាមួយ ភាគីនោះត្រូវផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅកាន់អ្នកស្នើសុំដោយបញ្ជាក់ពីអង្គហេតុពាក់ព័ន្ធ និងមូលដ្ឋាននៃការសម្រេចនេះ នៅពេលដែល៖

(ក) មានការផ្លាស់ប្តូរច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលទូទៅរបស់ភាគីនោះ

(ខ) ការផ្តល់ជូនព័ត៌មានមិនត្រឹមត្រូវ ឬព័ត៌មានពាក់ព័ន្ធមិនត្រូវបានទទួលស្គាល់

(គ) មានការផ្លាស់ប្តូរក្នុងអង្គហេតុ ឬកាលៈទេសៈពាក់ព័ន្ធដែលជាមូលដ្ឋាននៃការចេញវិធានបញ្ជាក់ជាមុន ឬ

(ឃ) វិធានបញ្ជាក់ជាមុននោះមានកំហុស។

៩. នៅពេលដែលភាគីម្ខាងដកហូត កែតម្រូវ ឬនិរាករណ៍វិធានបញ្ជាក់ជាមុន ជាមួយនឹងការអនុវត្តជាប្រតិសកម្ម អាចធ្វើទៅបានដូច្នេះ នៅពេលដែលវិធាននោះត្រូវបានសម្រេចដោយផ្អែកលើព័ត៌មានមិនពេញលេញ មិនត្រឹមត្រូវ មិនពិត ឬបន្លំបំភាន់តែប៉ុណ្ណោះ។

១០. ភាគីនីមួយៗ អាចបង្ហាញជាសាធារណៈនូវព័ត៌មាន ស្តីពីវិធានបញ្ជាក់ជាមុនទាំងឡាយណា ដែលគិតថាជាព័ត៌មានសំខាន់ ចំពោះភាគីដែលមានចំណាប់អារម្មណ៍ដទៃទៀត ដោយរាប់បញ្ចូលទាំងតម្រូវការ ដើម្បីការពារព័ត៌មានពាណិជ្ជកម្មដែលជាការសម្ងាត់។

## មាត្រា៤.១០៖ ការបញ្ចេញទំនិញ

១. រដ្ឋបាលគយនៃភាគីនីមួយៗត្រូវអនុម័ត ឬប្រកាន់ខ្ជាប់នីតិវិធីគយដែលសាមញ្ញសម្រាប់ការបញ្ចេញទំនិញប្រកបដោយប្រសិទ្ធភាពដើម្បីសម្រួលពាណិជ្ជកម្មរវាងគូភាគី។ កថាខណ្ឌនេះមិនត្រូវតម្រូវឱ្យភាគីម្ខាងធ្វើការបញ្ចេញទំនិញ ប្រសិនបើលក្ខខណ្ឌតម្រូវក្នុងការបញ្ចេញទំនិញរបស់ភាគីនោះមិនត្រូវបានបំពេញ។

២. យោងតាមកថាខណ្ឌទី១ ភាគីនីមួយៗត្រូវអនុម័ត ឬប្រកាន់ខ្ជាប់នីតិវិធីដែលអនុញ្ញាតឱ្យទំនិញត្រូវបានបំពេញបែបបទបញ្ចេញពីគយក្នុងរយៈពេលមិនលើសពីការតម្រូវ ដើម្បីធានាឱ្យបាននូវអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិគយ។

៣. ប្រសិនបើទំនិញទាំងឡាយណាត្រូវបានជ្រើសរើសសម្រាប់ការត្រួតពិនិត្យបន្ត ការត្រួតពិនិត្យនោះត្រូវធ្វើឡើងដោយមិនពន្យារពេល ក្នុងកម្រិតសមហេតុផលនិងចាំបាច់ ។

៤. ភាគីនីមួយៗត្រូវអនុម័តឬប្រកាន់ខ្ជាប់នីតិវិធីដែលអនុញ្ញាតឱ្យបញ្ចេញទំនិញមុនការកំណត់ចុងក្រោយលើពន្ធគយ អាករ កម្រៃ និងបន្ទុកផ្សេងៗ ប្រសិនបើការកំណត់មិនបានធ្វើឡើងនៅពេលឬមុនពេលទំនិញមកដល់ ឬត្រូវធ្វើឱ្យបានលឿនតាមដែលអាចធ្វើទៅបានក្រោយពេលទំនិញមកដល់ ក្នុងករណីដែលរាល់ការតម្រូវតាមបទប្បញ្ញតិទាំងឡាយផ្សេងទៀតត្រូវបានបំពេញគ្រប់គ្រាន់។ សម្រាប់ជាលក្ខខណ្ឌនៃការបញ្ចេញទំនិញនោះ ភាគីម្ខាងអាចតម្រូវឱ្យតម្កល់និមុត្តិធានា អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីនោះ ដែលមិនលើសពីចំនួនដែលភាគីនោះតម្រូវ ដើម្បីធានានូវការបង់ពន្ធគយ អាករ កម្រៃ និងបន្ទុកចំណាយផ្សេងៗដែលទំនិញក្រោមនិមុត្តិធានានោះត្រូវបង់ខ្ពស់បំផុត។

៥. ក្នុងគោលបំណងការពារការបាត់បង់ ឬការថយគុណភាពដែលអាចបញ្ចៀសបាននៃទំនិញដែលធាប់ខូចគុណភាព និងក្នុងលក្ខខណ្ឌដែលរាល់ការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិទាំងអស់ត្រូវបានបំពេញ ភាគីនីមួយៗអាចអនុញ្ញាតឱ្យបញ្ចេញនូវទំនិញធាប់ខូចគុណភាពពីការត្រួតពិនិត្យគយៈ
   (ក) ក្រោមស្ថានភាពទូទៅ ក្នុងរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន និង
   (ខ) ក្នុងករណីពិសេស នៅពេលដែលសមស្របអាចធ្វើទៅបាន ក្រៅម៉ោងរដ្ឋបាលរបស់អាជ្ញាធរគយនៃភាគីនោះ។

៦. ភាគីនីមួយៗអាចផ្តល់អាទិភាពសមស្របចំពោះទំនិញធាប់ខូចគុណភាពក្នុងការធ្វើកាលវិភាគត្រួតពិនិត្យ។

៧. ភាគីនីមួយៗអាចរៀបចំ ឬអនុញ្ញាតឱ្យអ្នកនាំចូលរៀបចំកន្លែងសមរម្យសម្រាប់រក្សាទុកទំនិញធាប់ខូចគុណភាពដែលរង់ចាំការបញ្ចេញទំនិញទាំងនោះ។ ភាគីនីមួយៗ អាចនឹងតម្រូវឱ្យកន្លែងរក្សាទុកទំនិញណាមួយដែលរៀបចំដោយអ្នកនាំចូល ត្រូវបានទទួលការអនុញ្ញាត ឬការកំណត់ដោយអាជ្ញាធរពាក់ព័ន្ធរបស់ខ្លួន។ ការផ្លាស់ទីនៃទំនិញទៅកាន់កន្លែងរក្សាទុកទាំងនោះ រាប់បញ្ចូលទាំងការអនុញ្ញាតឱ្យប្រតិបត្តិករបញ្ជូនទំនិញទាំងនោះ អាចជាកម្មវត្ថុនៃការអនុញ្ញាត ក្នុងករណីតម្រូវពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ ដោយអនុលោមតាមច្បាប់ក្នុងប្រទេសរបស់ខ្លួន ក្នុងករណីអាចធ្វើទៅបាន ភាគីនីមួយៗអាចរៀបចំឱ្យមាននូវនីតិវិធីចាំបាច់ សម្រាប់ការបញ្ចេញទំនិញនៅនឹងកន្លែងរក្សាទុកទំនិញទាំងនោះតែម្តង តាមសំណើរបស់អ្នកនាំចូល។

**មាត្រា៤.១១៖ ការគ្រប់គ្រងហានិភ័យ**

១. ភាគីនីមួយៗត្រូវអនុម័ត ឬប្រកាន់ខ្ជាប់អភិក្រម និងបច្ចេកទេសគ្រប់គ្រងហានិភ័យសម្រាប់ការត្រួតពិនិត្យគយ។

២. ភាគីនីមួយៗត្រូវបង្កើត ឬប្រើប្រាស់ការគ្រប់គ្រងហានិភ័យ ក្នុងបរិបទដើម្បីជៀសវាងការរើសអើងដោយបំពាន ឬមិនសមហេតុផល ឬរឹតត្បិតបែបក្លែងបន្លំ ចំពោះពាណិជ្ជកម្មអន្តរជាតិ។

៣. ភាគីនីមួយៗត្រូវផ្តោតការយកចិត្តទុកដាក់ត្រួតពិនិត្យគយ និងក្នុងករណីដែលអាចធ្វើបាន រួមទាំងការត្រួតពិនិត្យតាមព្រំដែនពាក់ព័ន្ធផ្សេងទៀត លើទំនិញដែលមានហានិភ័យខ្ពស់ និងពន្លឿនការបញ្ចេញទំនិញដែលមានហានិភ័យទាប។ ភាគីនីមួយៗក៏អាចជ្រើសរើសដោយចោះៗ នូវទំនិញ ដើម្បីត្រួតពិនិត្យ ដែលជាផ្នែកមួយនៃការគ្រប់គ្រងហានិភ័យផងដែរ។

៤. ភាគីនីមួយៗត្រូវអនុវត្តយន្តការការគ្រប់គ្រងហានិភ័យដោយផ្អែកលើការវាយតម្លៃកម្រិតហានិភ័យតាមរយៈលក្ខណៈវិនិច្ឆ័យជ្រើសរើសដែលសមស្រប។ លក្ខណៈវិនិច្ឆ័យជ្រើសរើសនេះ អាចមានដូចជាលេខ HS Code លក្ខណៈធម្មជាតិ និងការបរិយាយទំនិញ ប្រទេសដើមកំណើត ប្រទេសដែលទំនិញត្រូវបានដឹកចេញ តម្លៃនៃទំនិញ កំណត់ត្រាអនុលោមភាពរបស់ពាណិជ្ជករ និងប្រភេទមធ្យោបាយដឹកជញ្ជូន។

៥. រដ្ឋបាលគយនៃភាគីនីមួយៗត្រូវដោះដូរគ្នាទៅវិញទៅមកនូវការអនុវត្តល្អ ស្តីពីបច្ចេកទេសនៃការគ្រប់គ្រងហានិភ័យ។

## មាត្រា៤.១២៖ សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ

១. ក្នុងគោលបំណងពន្លឿនការបញ្ចេញទំនិញពីគយ ភាគីនីមួយៗត្រូវអនុម័ត ឬប្រកាន់ខ្ជាប់នូវសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដើម្បីធានាអនុលោមភាពជាមួយច្បាប់ និងបទប្បញ្ញត្តិស្ដីពីគយ ឬបញ្ហាពាក់ព័ន្ធផ្សេងទៀតរបស់ភាគីនោះ។

២. ភាគីនីមួយៗត្រូវជ្រើសរើសបុគ្គល ឬទំនិញសម្រាប់ការធ្វើសវនកម្មក្រោយពេលបញ្ចេញ ទំនិញពីគយ នៅក្នុងបរិបទដោយផ្អែកលើហានិភ័យ ដែលអាចរាប់បញ្ចូលលក្ខណៈវិនិច្ឆ័យជ្រើសរើសសមស្រប។ ភាគីនីមួយៗ ត្រូវធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយប្រកបដោយតម្លាភាព។ នៅពេលបុគ្គលនោះបានចូលរួមក្នុងដំណើរការសវនកម្ម និងលទ្ធផលសម្រេចត្រូវបានរៀបចំរួច ភាគីនោះត្រូវជូនដំណឹងដល់បុគ្គលដែលរងសវនកម្ម ដោយមិនត្រូវពន្យារពេល អំពី៖

(ក) លទ្ធផល

(ខ) ហេតុផលនៃលទ្ធផលនោះ និង

(គ) សិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គល។

៣. គូភាគីត្រូវទទួលស្គាល់ថា ព័ត៌មានដែលទទួលបានពីការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ អាចនឹងត្រូវយកទៅប្រើប្រាស់បន្តទៀតសម្រាប់កិច្ចការរដ្ឋបាល ឬក្នុងប្រព័ន្ធតុលាការ។

៤. ភាគីនីមួយៗត្រូវប្រើប្រាស់លទ្ធផលសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយក្នុងការអនុវត្តការគ្រប់គ្រងហានិភ័យ តាមដែលអាចធ្វើទៅបាន។

## មាត្រា៤.១៣៖ ការសិក្សារយៈពេលបញ្ចេញទំនិញពីគយ

១. ភាគីនីមួយៗត្រូវបានលើកទឹកចិត្តឱ្យធ្វើការវាស់វែងរយៈពេលដែលតម្រូវសម្រាប់បញ្ចេញ ទំនិញដោយរដ្ឋបាលគយ ឱ្យបានទៀងទាត់តាមពេលកំណត់ណាមួយ និងធ្វើឡើងក្នុងលក្ខណៈមិនប្រែប្រួល និងផ្សព្វផ្សាយពីលទ្ធផលដែលបានសិក្សា ដោយប្រើប្រាស់មធ្យោបាយដូចជា *សេចក្ដីណែនាំសម្រាប់វាស់វែងរយៈពេលតម្រូវសម្រាប់បញ្ចេញទំនិញ* ដែលចេញដោយអង្គការគយពិភពលោក ជាមួយនឹងទស្សនៈដើម្បី៖

(ក) វាយតម្លៃវិធានការកិច្ចសម្រួលពាណិជ្ជកម្មរបស់ខ្លួន និង

(ខ) ពិចារណាលើឱកាសសម្រាប់ធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនូវពេលវេលាតម្រូវសម្រាប់បញ្ចេញទំនិញ។

២. ភាគីនីមួយៗត្រូវបានលើកទឹកចិត្តឱ្យចែករំលែកនូវបទពិសោធន៍របស់ខ្លួនក្នុងការសិក្សារយៈពេលបញ្ចេញទំនិញពីគយ ដែលបានយោងនៅក្នុងកថាខណ្ឌទី១ រួមមានវិធីសាស្ត្រដែលបានប្រើប្រាស់ និងបញ្ហាកកស្ទះដែលបានរកឃើញ។

## មាត្រា៤.១៤៖ ការត្រួតពិនិត្យឡើងវិញ និងបណ្ដឹងតវ៉ា

១. ភាគីនីមួយៗត្រូវអនុញ្ញាតដល់បុគ្គលណាមួយដែលទទួលសេចក្ដីសម្រេចរដ្ឋបាល[4] ពីអាជ្ញាធរគយរបស់ខ្លួន មានសិទ្ធិក្នុងដែនដីរបស់ខ្លួនលើ៖

---

4 សម្រាប់គោលបំណងនៃមាត្រានេះ "សេចក្ដីសម្រេចរដ្ឋបាល" មានន័យថា សេចក្ដីសម្រេចដែលមានលក្ខណៈគតិយុត្តិ ដែលប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចនៃបុគ្គលជាក់លាក់ណាមួយ ក្នុងករណីដោយឡែក។ ភាគីត្រូវយល់ថា សេចក្ដីសម្រេចរដ្ឋបាលដែលចែងក្នុងមាត្រានេះ គ្រប

(ក) បណ្ដឹងតវ៉ារដ្ឋបាលឬការពិនិត្យឡើងវិញដោយអាជ្ញាធររដ្ឋបាលដែលមានកម្រិតខ្ពស់ជាង ឬឯករាជ្យពីមន្ត្រី ឬការិយាល័យដែលបានចេញសេចក្ដីសម្រេចនោះ និង

(ខ) បណ្ដឹងតាមប្រព័ន្ធតុលាការ ឬការពិនិត្យឡើងវិញនៃសេចក្ដីសម្រេចនោះ។

២. ភាគីនីមួយៗត្រូវអនុញ្ញាតឱ្យអ្នកនាំចេញ ឬផលិតករ ផ្ដល់ព័ត៌មានដោយផ្ទាល់ទៅភាគី ដើម្បីពិនិត្យឡើងវិញ និងស្នើសុំភាគីនោះ រក្សាព័ត៌មានសម្ងាត់យោងទៅតាមមាត្រា៤.១៥។

## មាត្រា៤.១៥៖ ព័ត៌មានសម្ងាត់

នៅពេលដែលភាគីម្ខាងផ្ដល់ព័ត៌មានទៅកាន់ភាគីម្ខាងទៀត និងចាត់ទុកជាព័ត៌មានសម្ងាត់ ភាគីដែលទទួលបានព័ត៌មានត្រូវរក្សាព័ត៌មានសម្ងាត់ ដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិគយរបស់ខ្លួន។

## មាត្រា៤.១៦៖ កិច្ចសហប្រតិបត្តិការគយ

១. រដ្ឋបាលគយរបស់ភាគីនីមួយៗ ក្នុងករណីសមស្របអាចជួយគ្នាទៅវិញទៅមក ពាក់ព័ន្ធនឹងការងារដូចខាងក្រោម៖

(ក) ការអនុវត្ត និងការប្រតិបត្តិនៃជំពូកនេះ

(ខ) ការអភិវឌ្ឍ និងការអនុវត្តល្អរបស់គយ និងបច្ចេកទេសគ្រប់គ្រងហានិភ័យ

(គ) សាមញ្ញកម្ម និងសុខដុមនីយកម្មនីតិវិធីគយ

(ឃ) ការលើកកម្ពស់ជំនាញបច្ចេកទេស និងការប្រើប្រាស់បច្ចេកវិទ្យា

(ង) ការអនុវត្តកិច្ចព្រមព្រៀងតម្លៃគិតពន្ធគយ

(ច) ការផ្លាស់ប្ដូរនូវស្ថិតិនៃការអនុវត្ត FTA ទម្រង់ និងប្រភេទដែលនឹងត្រូវឯកភាពដោយភាគីទាំងពីរ និង

(ឆ) បញ្ហាគយផ្សេងទៀត ដែលគូភាគីអាចកំណត់រួមគ្នា។

២. តាមករណីសមស្រប រដ្ឋបាលគយនៃភាគីទាំងពីរអាចចែករំលែកនូវព័ត៌មាន និងបទពិសោធន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍរដ្ឋបាលគយ។

៣. តាមដែលអាចធ្វើទៅបាន ភាគីនីមួយៗត្រូវជូនដំណឹងឱ្យបានទាន់ពេលវេលាទៅភាគីម្ខាងទៀត ពាក់ព័ន្ធនឹងការផ្លាស់ប្ដូរបែបរដ្ឋបាលសំខាន់ៗ ការកែសម្រួលច្បាប់និងបទប្បញ្ញត្តិ ឬវិធានការនានាពាក់ព័ន្ធនឹងច្បាប់ និងបទប្បញ្ញត្តិគ្រប់គ្រងលើការនាំចូល ឬការនាំចេញ ដែលអាចមានផលប៉ះពាល់ដល់ការអនុវត្តជំពូកនេះ។ ការជូនដំណឹងនេះអាចធ្វើឡើងជាភាសាអង់គ្លេស ឬភាសារបស់សាមីភាគីម្ខាង ហើយការជូនដំណឹងនេះនឹងត្រូវផ្ដល់ទៅឱ្យមន្ត្រីទំនាក់ទំនង ដូចមានកំណត់ក្នុងមាត្រា៤.១៧។

---

ដណ្ដប់លើវិធានការរដ្ឋបាល ក្នុងអត្ថន័យនៃមាត្រា XX នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ ឬការខកខានក្នុងការអនុវត្តវិធានការ ឬសេចក្ដីសម្រេច ដែលមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិ និងប្រព័ន្ធច្បាប់ របស់ភាគីនោះ។ ដើម្បីដោះស្រាយការខកខាននេះ ភាគីអាចប្រកាន់ខ្ជាប់នូវជម្រើសយន្តការរដ្ឋបាល ឬយន្តការដោះបន្ទាល់ផ្នែកច្បាប់ផ្សេងទៀត ដើម្បីឱ្យអាជ្ញាធរគយចេញសេចក្ដី សម្រេចរដ្ឋបាលឱ្យបានឆាប់រហ័សជំនួសឱ្យសិទ្ធិក្នុងការដាក់បណ្ដឹងតវ៉ា ក្រោមវាក្យខណ្ឌ១(ក)។

**មាត្រា៤.១៧៖ ការពិគ្រោះយោបល់ និងមន្ត្រីទំនាក់ទំនង**

១. រដ្ឋបាលគយរបស់ភាគីនីមួយៗអាចស្នើឱ្យមានការពិគ្រោះយោបល់នៅពេលណាមួយជាមួយរដ្ឋបាលគយនៃភាគីម្ខាងទៀត ស្តីពីបញ្ហាសំខាន់ដែលកើតឡើងពីការអនុវត្ត ឬការប្រតិបត្តិនៃជំពូកនេះ ឬអង្គហេតុ ក្នុងករណីដែលមានហេតុផលសមរម្យ ឬអង្គហេតុដែលផ្តល់ដោយភាគី ស្នើសុំ។

២. ក្នុងករណីដែលការពិគ្រោះយោបល់ដូចនេះមិនអាចដោះស្រាយបញ្ហាបាន ភាគីស្នើសុំអាចបញ្ជូនបញ្ហានេះ ទៅគណៈកម្មការ ស្តីពីវិធានដើមកំណើត និងនីតិវិធីគយ ដូចមានកំណត់ក្នុង មាត្រា ៤.១៨។

៣. រដ្ឋបាលគយនីមួយៗត្រូវចាត់តាំងមន្ត្រីទំនាក់ទំនងមួយឬច្រើន សម្រាប់គោលបំណងនៃជំពូកនេះ។ ព័ត៌មាននៃមន្ត្រីទំនាក់ទំនង ត្រូវជូនដំណឹងឱ្យបានឆាប់រហ័សដល់ភាគីម្ខាងទៀតចំពោះរាល់ការផ្លាស់ប្តូរព័ត៌មានលម្អិតនៃមន្ត្រីទំនាក់ទំនងទាំងនោះ។

**មាត្រា៤.១៨៖ គណៈកម្មការ ស្តីពីវិធានដើមកំណើត និងនីតិវិធីគយ**

១. គូភាគីបង្កើតគណៈកម្មការ ស្តីពីវិធានដើមកំណើត និងនីតិវិធីគយ (ដែលតទៅនេះ ហៅកាត់ថា "គណៈកម្មការ") ដោយរួមមានអ្នកតំណាង[5] ចាត់តាំងដោយភាគីនីមួយៗ។

២. គណៈកម្មការ ត្រូវជានាមុខងារសមស្របលើជំពូកនេះ និងជំពូកទី៣ (វិធានដើមកំណើត) និងពិនិត្យរាល់បញ្ហាដែលកើតឡើងពីការអនុវត្តជំពូកទាំងនេះ។

៣. មុខងាររបស់គណៈកម្មការ អាចរួមបញ្ចូល៖

(ក) ការពិនិត្យឡើងវិញ ការពិភាក្សា ការលើកសំណើ និងការបង្កើតអនុសាសន៍សមស្របដល់គណៈកម្មាធិការ តាមការចាំបាច់លើ៖

(i) ការគ្រប់គ្រងអនុវត្តជំពូកនេះ ឬជំពូកទី ៣ (វិធានដើមកំណើត) ប្រកបដោយប្រសិទ្ធភាព សង្គតិភាព និងភាពស្របគ្នា រួមទាំងការបកស្រាយ និងការអនុវត្តខ្លឹមសារនានានៃជំពូកទាំងពីរ និងការពង្រឹងកិច្ចសហប្រតិបត្តិការទាក់ទងទៅនឹងជំពូកទាំងនេះ និង

(ii) ពិនិត្យឡើងវិញនូវ ឧបសម្ព័ន្ធ ៣-ក (វិធានជាក់លាក់សម្រាប់ផលិតផល) លើការបំលែងប្រព័ន្ធសុខដុមនីយកម្ម (ដែលតទៅនេះ ហៅកាត់ថា "ប្រព័ន្ធ HS")។

(ខ) ការពិគ្រោះយោបល់ និងប្រឹងប្រែងដោះស្រាយបញ្ហានានាដែលអាចកើតមានឡើងរវាងគូភាគីពាក់ព័ន្ធនឹងចំណាត់ថ្នាក់ទំនិញក្រោមប្រព័ន្ធ HS និងការបកស្រាយរបស់ជំពូកនេះ និងជំពូកទី៣ (វិធានដើមកំណើត)។

(គ) ការពិនិត្យឡើងវិញនូវលទ្ធភាពក្នុងការកែសម្រួល និងឈានទៅសម្រេចឱ្យមានការឯកភាពលើសេចក្តីកែសម្រួល នៃជំពូកនេះ និងជំពូកទី៣(វិធានដើមកំណើត) និង

(ឃ) ដោះស្រាយបញ្ហានានា ដែលបានចាត់ដោយគណៈកម្មាធិការចម្រុះ ដល់គណៈកម្មការ។

៤. គណៈកម្មការត្រូវប្រជុំរៀងរាល់ឆ្នាំដោយឆ្លាស់គ្នារវាងគូភាគី ឬតាមការព្រមព្រៀងរវាងគូភាគី។

---

[5] សម្រាប់ភាគីកូរ៉េ រដ្ឋបាលគយកូរ៉េជាតំណាង។ ចំណែកភាគីកម្ពុជា នឹងត្រូវដឹកនាំរួមគ្នាដោយតំណាងក្រុមការងារវិធានដើមកំណើត និងក្រុមការងារនីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម។

# ជំពូកទី៥
# ឧបាស្រ័យពាណិជ្ជកម្ម

## ផ្នែក ក៖ វិធានការការពារ

### មាត្រា៥.១៖ និយមន័យ

វាក្យស័ព្ទបច្ចេកទេសដែលប្រើសម្រាប់គោលបំណងនៃផ្នែកនេះ ត្រូវបានកំណត់និយមន័យ ដូចតទៅ៖

**ឧស្សាហកម្មក្នុងស្រុក** សំដៅដល់ពាក់ព័ន្ធនឹងទំនិញនាំចូល ក្រុមផលិតករជារួមដែលផលិតទំនិញដូចគ្នា ឬទំនិញមានលក្ខណៈប្រកួតប្រជែងផ្ទាល់ ហើយដែលមានប្រតិបត្តិការក្នុងដែនដីនៃភាគីម្ខាង ឬក្រុមផលិតករទាំងឡាយដែលមានផលិតផលសរុបនៃទំនិញដូចគ្នាឬទំនិញមានលក្ខណៈប្រកួតប្រជែងផ្ទាល់ក្នុងទំហំសមាមាត្រភាគច្រើននៃផលិតកម្មក្នុងស្រុកនៃទំនិញដូចគ្នា ឬទំនិញមានលក្ខណៈប្រកួតប្រជែងផ្ទាល់នោះ។

**វិធានការការពារ** សំដៅដល់វិធានការដែលបានពណ៌នាក្នុងមាត្រា៥.២។

**ការខូចខាតធ្ងន់ធ្ងរ** សំដៅដល់ផលប៉ះពាល់រួមជាដុំកំភួនដល់ឧស្សាហកម្មក្នុងស្រុក។

**ការគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរ** សំដៅដល់ការខូចខាតធ្ងន់ធ្ងរដែលប្រាកដថានឹងកើតមានឡើងដោយផ្អែកលើអង្គហេតុនានា និងមិនត្រូវផ្អែកតែលើការអះអាងដោយគ្មានភស្តុតាង លើការប៉ាន់ស្មាន ឬលើភាពដែលអាចកើតមានឡើងដែលស្ថិតនៅឆ្ងាយនៅឡើយនោះទេ និង

**រយៈពេលអន្តរកាល** សំដៅដល់ពាក់ព័ន្ធនឹងទំនិញជាក់លាក់ណាមួយ រយៈពេលគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រហូតដល់រយៈពេល ៣ឆ្នាំ ក្រោយកាលបរិច្ឆេទនៃការបញ្ចប់ការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយ ដោយអនុលោមតាមតារាងសន្យាពន្ធគយរបស់ភាគីម្ខាងនោះ ដូចមានក្នុងឧបសម្ព័ន្ធ២-ក (ការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយ)។

### មាត្រា៥.២៖ ការដាក់វិធានការការពារ

១. ប្រសិនបើ ជាលទ្ធផលនៃការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយក្រោមកិច្ចព្រមព្រៀងនេះ ទំនិញមានដើមកំណើតនៃភាគីម្ខាងទៀតកំពុងត្រូវបាននាំចូលទៅក្នុងដែនដីនៃភាគីម្ខាង ក្នុងបរិមាណកើនឡើងយ៉ាងគំហុកទោះជាក្នុងតួលេខដាច់ខាតឬតួលេខធៀបនឹងឧស្សាហកម្មក្នុងស្រុកក៏ដោយ ហើយដែលក្រោមស្ថានភាពនេះ បង្កឱ្យមានជាដុំកំភួននូវការខូចខាតធ្ងន់ធ្ងរ ឬការគំរាម កំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកដែលផលិតទំនិញដូចគ្នា ឬទំនិញមានលក្ខណៈប្រកួតប្រជែងផ្ទាល់ ភាគីម្ខាងនោះអាចដាក់ចេញនូវវិធានការដូចខាងក្រោម ក្នុងកម្រិតចាំបាច់ដើម្បីទប់ស្កាត់ ឬដោះស្រាយ ការខូចខាតធ្ងន់ធ្ងរនោះដល់ឧស្សាហកម្មក្នុងស្រុករបស់ខ្លួន និងក្នុងការសម្រួលដល់ការកែសម្រួលស្ថានភាពរបស់ឧស្សាហកម្មក្នុងស្រុករបស់ខ្លួន៖

(ក) ព្យួរការបន្តកាត់បន្ថយនូវរាល់អត្រាពន្ធគយនៃទំនិញនោះដូចមានចែងក្រោមកិច្ចព្រមព្រៀងនេះ ឬ

(ខ) ដំឡើងអត្រាពន្ធគយនៃទំនិញនោះ ត្រឹមកម្រិតមួយមិនឱ្យលើសអត្រាណាមួយដែលទាបជាងគេ ក្នុងចំណោមអត្រាពីរខាងក្រោម៖

(i) អត្រាពន្ធគយអនុវត្តន៍សម្រាប់ប្រជាជាតិទទួលបានភាពអនុគ្រោះបំផុត (MFN) លើទំនិញនោះ ដែលនៅជាធរមាននៅពេលដាក់វិធានការការពារនេះ ឬ

(ii) អត្រាពន្ធគយមូលដ្ឋាន ដែលមានបញ្ជាក់ក្នុងតារាងសន្យាពន្ធគយ ក្នុងឧបសម្ព័ន្ធ ២-ក (ការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយ) អនុលោមតាមមាត្រា២.៤ (ការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយ)។

២. គូភាគីយល់ឃើញថា ទាំងការកំណត់កូតាអត្រាពន្ធគយ ឬទាំងការរឹតត្បិតបរិមាណជាទម្រង់នៃវិធានការការពារដែលមិនត្រូវបានអនុញ្ញាតឡើយ។

**មាត្រា៥.៣៖ លក្ខខណ្ឌ និងដែនកំណត់**

១. ភាគីម្ខាងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីម្ខាងទៀត អំពីការចាប់ផ្ដើមការស៊ើបអង្កេតដូចមានពណ៌នាក្នុងកថាខណ្ឌ២ និងត្រូវពិគ្រោះយោបល់ជាមុនជាមួយភាគីម្ខាងទៀតក្នុងរយៈពេលវែងតាមការអាចអនុវត្តបាន មុននឹងដាក់វិធានការការពារ ដើម្បីត្រួតពិនិត្យឡើងវិញនូវព័ត៌មាននានាទទួលបានពីការស៊ើបអង្កេត និងដើម្បីផ្លាស់ប្ដូរយោបល់គ្នាអំពីវិធានការការពារ។

២. ភាគីម្ខាងអាចដាក់វិធានការការពារបាន លុះត្រាតែអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីម្ខាងនោះបានធ្វើការស៊ើបអង្កេត ដោយអនុលោមតាមមាត្រា៣ និងមាត្រា៤.២(គ) នៃកិច្ចព្រមព្រៀង ស្ដីពីវិធានការការពារតែប៉ុណ្ណោះ។ ក្នុងន័យនេះ មាត្រា៣ និងមាត្រា៤.២(គ) នៃកិច្ចព្រមព្រៀង ស្ដីពីវិធានការការពារត្រូវបានដាក់បញ្ចូលក្នុង និងក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ *ដោយយកមកអនុវត្តដូចគ្នា* ។

៣. នៅក្នុងការស៊ើបអង្កេតដូចមានពណ៌នាក្នុងកថាខណ្ឌ២ខាងលើ ភាគីម្ខាងនោះត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា៤.២(ក) នៃកិច្ចព្រមព្រៀង ស្ដីពីវិធានការការពារ។ ក្នុងន័យនេះ មាត្រា៤.២(ក) នៃកិច្ចព្រមព្រៀង ស្ដីពីវិធានការការពារ ត្រូវដាក់បញ្ចូលក្នុង និងក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ *ដោយយកមកអនុវត្តដូចគ្នា* ។

៤. ភាគីនីមួយៗ ត្រូវធានាថាអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនបិទបញ្ចប់ការស៊ើបអង្កេតទាំងនេះ ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទផ្ដួចផ្ដើមការស៊ើបអង្កេត។

៥. មិនមានភាគីណាមួយ អាចដាក់វិធានការការពារ៖

(ក) លើកលែងតែក្នុងករណី និងក្នុងកម្រិតចាំបាច់ដើម្បីទប់ស្កាត់ ឬដោះស្រាយការខូចខាតធ្ងន់ធ្ងរ និងដើម្បីសម្រួលដល់ការកែសម្រួល។

(ខ) លើសពីរយៈពេល ២ឆ្នាំ ឡើយ លើកលែងតែរយៈពេលនេះ អាចត្រូវបានបន្តរហូតដល់រយៈពេល ១ឆ្នាំ បន្ថែមទៀត ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចូលនោះ

ដោយអនុលោមតាមនីតិវិធីដូចមានចែងក្នុងមាត្រានេះ សម្រេចថាវិធានការការពារនេះនៅបន្តមានភាពចាំបាច់ក្នុងការទប់ស្កាត់ ឬដោះស្រាយការខូចខាតធ្ងន់ធ្ងរ និងក្នុងការសម្រួលដល់ការកែសម្រួល និងសម្រេចផងដែរថា មានភស្តុតាងបញ្ជាក់ថាឧស្សាហកម្មក្នុងស្រុកកំពុងធ្វើការកែសម្រួល ប្រសិនបើរយៈពេលសរុបនៃការអនុវត្តវិធានការការពារនេះ រួមទាំងការអនុវត្តចាប់ផ្ដើមអនុវត្ត និងរយៈពេលបន្តមិនត្រូវលើសពីរយៈពេល ៣ឆ្នាំ នោះទេ។ ឬ

(គ) លើសពីកាលបរិច្ឆេទកំណត់នៃរយៈពេលអន្តរកាលឡើយ។

៦. ភាគីម្ខាងមិនត្រូវដាក់វិធានការការពារច្រើនជាងមួយដងលើទំនិញតែមួយឡើយ រហូតទាល់តែរយៈពេលស្មើនឹងរយៈពេលនៃវិធានការការពារដែលបានដាក់ពីមុនរួមទាំងរយៈពេលបន្តណាក៏ដោយបានកន្លងផុតសិន ដោយគិតចាប់ការបញ្ចប់នៃវិធានការការពារដែលបានដាក់ពីមុននោះ ប្រសិនបើរយៈពេលនៃការមិនដាក់វិធានការការពារនោះ មានរយៈពេលយ៉ាងហោចណាស់ ២ឆ្នាំ។

៧. នៅពេលដែលរយៈពេលរំពឹងទុកនៃវិធានការការពារនេះលើសពីរយៈពេល ១ឆ្នាំ ភាគីនាំចូលនោះត្រូវដកចេញជាបណ្ដើរៗនូវវិធានការការពារនេះ នៅក្នុងចន្លោះពេលទៀងទាត់។

៨. នៅពេលភាគីម្ខាងបញ្ចប់នូវវិធានការការពារ អត្រាពន្ធគយអនុវត្តន៍ត្រូវតែជាអត្រាពន្ធគយដែលគួរបន្តនៅជាធរមាន ប្រសិនបើមិនមានការដាក់វិធានការការពារនេះទេនោះ ដោយស្របតាមតារាងសន្យាពន្ធគយរបស់ខ្លួនក្នុងឧបសម្ព័ន្ធ២-ក (ការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយ)។

## មាត្រា៥.៤៖ វិធានការការពារបណ្ដោះអាសន្ន

១. នៅក្នុងកាលៈទេសៈធ្ងន់ធ្ងរដែលក្នុងនោះ ការពន្យារពេលនឹងបង្កឱ្យមានការខូចខាតដែលនឹងពិបាកជួសជុល ភាគីម្ខាងអាចអនុវត្តវិធានការការពារក្នុងរយៈពេលបណ្ដោះអាសន្នបាន ហើយត្រូវតែជាវិធានការក្នុងទម្រង់ដូចមានចែងក្នុងមាត្រា៥.២.១(ក) ឬមាត្រា៥.២.១(ខ) បន្ទាប់ពីអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីម្ខាងនោះចេញសេចក្ដីសម្រេចបឋមថា មានភស្តុតាងច្បាស់លាស់បង្ហាញថាការនាំចូលទំនិញមានដើមកំណើតពីភាគីម្ខាងទៀតបានកើនឡើង ដោយសារការកាត់បន្ថយ ឬការលុបបំបាត់ពន្ធគយក្រោមកិច្ចព្រមព្រៀងនេះ ហើយការនាំចូលនេះបង្កឱ្យមានជាដុំកំភួននូវការខូចខាតធ្ងន់ធ្ងរ ឬគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក។

២. មុនពេលអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីម្ខាងអាចចេញសេចក្ដីសម្រេចបឋម ភាគីម្ខាងនោះដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តិក្នុងស្រុករបស់ខ្លួន ត្រូវបោះផ្សាយសេចក្ដីជូនដំណឹងជាសាធារណៈក្នុងព្រឹត្តិបត្រព័ត៌មានផ្លូវការ ដោយបញ្ជាក់នូវវិធីដែលភាគីមានប្រយោជន៍ រួមទាំងអ្នកនាំចូល និងអ្នកនាំចេញ អាចទទួលបានច្បាប់ចម្លងមិនមែនជាព័ត៌មានសម្ងាត់នៃពាក្យស្នើសុំដាក់វិធានការការពារបណ្ដោះអាសន្ន ហើយតាមការដែលអាចអនុវត្តបាន ត្រូវផ្ដល់ដល់ភាគីមានប្រយោជន៍នូវឱកាសគ្រប់គ្រាន់ ក្នុងការផ្ដល់ភស្តុតាង និងមតិយោបល់លើពាក្យស្នើសុំដាក់វិធានការការពារបណ្ដោះអាសន្ននោះ បន្ទាប់ពីកាលបរិច្ឆេទដែលខ្លួនបោះផ្សាយសេចក្ដីជូនដំណឹងនោះ។

៣. ភាគីដែលអនុវត្តវិធានការការពារបណ្តោះអាសន្ននេះ ត្រូវជូនដំណឹងដល់ភាគីម្ខាងទៀត មុនពេលអនុវត្តវិធានការការពារបណ្តោះអាសន្ន ហើយត្រូវចាប់ផ្តើមការពិគ្រោះយោបល់ភ្លាមៗជាមួយភាគីម្ខាងទៀត បន្ទាប់ពីអនុវត្តនូវវិធានការការពារបណ្តោះអាសន្ននេះ។

៤. រយៈពេលនៃរាល់វិធានការការពារបណ្តោះអាសន្ន មិនត្រូវលើសពីរយៈពេល ២០០ថ្ងៃឡើយ ហើយក្នុងអំឡុងពេលនេះ ភាគីម្ខាងដែលអនុវត្តវិធានការនេះ ត្រូវអនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៥.៣.២ និងមាត្រា៥.៣.៣។

៥. ភាគីម្ខាងនោះត្រូវបង្វិលសងវិញភ្លាមៗនូវប្រាក់ពន្ធគយបន្ថែម ប្រសិនបើការស៊ើបអង្កេត ដូចមានពណ៌នាក្នុងមាត្រា៥.៣.២ មិនមានលទ្ធផលរកឃើញដែលអាចបញ្ជាក់ថាលក្ខខណ្ឌតម្រូវនានាដូចមានចែងក្នុងមាត្រា៥.២ ត្រូវបានបំពេញ។ រយៈពេលនៃវិធានការការពារបណ្តោះអាសន្នត្រូវយកមករាប់បញ្ចូលក្នុងរយៈពេលសរុបដូចមានពណ៌នាក្នុងមាត្រា៥.៣.៥(ខ)។

**មាត្រា៥.៥៖ សំណង**

១. ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពេលភាគីម្ខាងអនុវត្តវិធានការការពារ ភាគីម្ខាងនោះត្រូវផ្តល់ដល់ភាគីម្ខាងទៀត នូវឱកាសពិគ្រោះយោបល់ជាមួយខ្លួនពាក់ព័ន្ធនឹងមធ្យោបាយពេញលេញ ក្នុងការផ្តល់សំណងពាណិជ្ជកម្ម ក្នុងទម្រង់ជាសម្បទានដែលសមមូលជាដុំកំភួនទៅនឹងផលប៉ះពាល់ពាណិជ្ជកម្ម ឬសមមូលទៅនឹងតម្លៃនៃពន្ធគយបន្ថែម ដែលរំពឹងថានឹងកើតចេញពីវិធានការការពារនោះ។ ភាគីម្ខាងដែលអនុវត្តវិធានការការពារនោះត្រូវផ្តល់សំណងនេះ ដូចដែលគូភាគី ឯកភាពគ្នា ទៅវិញទៅមក។

២. ប្រសិនគូភាគីមិនអាចឈានដល់ការឯកភាពគ្នាលើសំណងតាមរយៈការពិគ្រោះយោបល់ក្រោមកថាខណ្ឌ១ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីការពិគ្រោះយោបល់នេះបានចាប់ផ្តើម ភាគីម្ខាងដែលទំនិញមានដើមកំណើតរបស់ខ្លួនត្រូវបានដាក់វិធានការការពារលើ អាចព្យួរការអនុវត្តសម្បទានពាក់ព័ន្ធនឹងទំនិញមានដើមកំណើតដែលមានផលប៉ះពាល់ពាណិជ្ជកម្មសមមូលជាដុំកំភួនទៅនឹងវិធានការការពាររបស់ភាគីម្ខាងដែលអនុវត្តវិធានការការពារនេះ ។

៣. សិទ្ធិនៃការព្យួរដូចមានចែងក្នុងកថាខណ្ឌ២ខាងលើនេះ មិនត្រូវអនុវត្តក្នុងរយៈពេល ២ឆ្នាំ ដំបូងដែលក្នុងអំឡុងពេលនោះវិធានការការពារនៅបន្តនៅជាធរមានឡើយ ប្រសិនបើវិធានការការពារនោះត្រូវបានដាក់ ដោយសារការកើនឡើងក្នុងតួលេខដាច់ខាតនូវការនាំចូល ហើយអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកនេះ។

៤. កាតព្វកិច្ចផ្តល់សំណងក្រោមកថាខណ្ឌ១ របស់ភាគីអនុវត្តវិធានការការពារ និងសិទ្ធិព្យួរសម្បទានរបស់ភាគីម្ខាងទៀតក្រោមកថាខណ្ឌ២ ត្រូវបញ្ចប់នៅពេលវិធានការការពារត្រូវបានបញ្ចប់។

៥. រាល់សំណង ត្រូវផ្អែកជាមូលដ្ឋានលើរយៈពេលសរុបនៃការអនុវត្តវិធានការការពារបណ្តោះអាសន្ន និងរយៈពេលសរុបនៃវិធានការការពារ។

## មាត្រា៥.៦៖ វិធានការការពារសកល

១. ភាគីនីមួយៗរក្សាសិទ្ធិ និងកាតព្វកិច្ចនានាក្រោមមាត្រា XIX នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងក្រោមកិច្ចព្រមព្រៀង ស្តីពីវិធានការការពារ។ កិច្ចព្រមព្រៀងនេះមិនផ្តល់ឱ្យនូវសិទ្ធិ ឬបង្កើតនូវកាតព្វកិច្ចបន្ថែមដល់គូភាគី ពាក់ព័ន្ធនឹងវិធានការដែលបានដាក់ចេញក្រោមតាមមាត្រា XIX នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀង ស្តីពីវិធានការការពារឡើយ។

២. តបតាមសំណើរបស់ភាគីម្ខាងទៀត ភាគីម្ខាងដែលមានបំណងដាក់វិធានការការពារសកល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមៗ អំពីព័ត៌មាននានាពាក់ព័ន្ធនឹងការចាប់ផ្តើម ការស៊ើបអង្កេតវិធានការការពារសកល សេចក្តីសម្រេចបឋម និងលទ្ធផលរកឃើញចុងក្រោយនៃការស៊ើបអង្កេតនេះ។

៣. មិនមានសមាជិកណាមួយអាចអនុវត្ត ចំពោះទំនិញតែមួយ និងក្នុងពេលតែមួយ បានឡើយនូវ៖

(ក) វិធានការការពារបណ្តោះអាសន្ន ឬវិធានការការពារ និង

(ខ) វិធានការក្រោមមាត្រា XIX នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងក្រោមកិច្ចព្រមព្រៀង ស្តីពីវិធានការការពារ។

# ផ្នែក ខ៖ ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ

## មាត្រា៥.៧៖ បទប្បញ្ញត្តិទូទៅ

១. លើកលែងតែមានចែងផ្សេងពីនេះក្នុងកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗ រក្សាសិទ្ធិ និងកាតព្វកិច្ចទាំងឡាយរបស់ខ្លួនក្រោមមាត្រា VI នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងកិច្ចព្រមព្រៀង ស្តីពីវិធានការពន្ធប៉ះប៉ូវ ចំពោះការអនុវត្តពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ។

២. ក្រោយពីដាក់វិធានការបណ្តោះអាសន្ននានា និងមុនពេលចេញសេចក្តីសម្រេចចុងក្រោយ គូភាគីត្រូវធានាឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន នូវការលាតត្រដាងពេញលេញ និងប្រកបដោយខ្លឹមសារនូវរាល់អង្គហេតុនិងការពិចារណាចាំបាច់នានាដែលជាមូលដ្ឋានក្នុងការសម្រេចដាក់វិធានការ ដោយមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចក្រោមមាត្រា៦.៥ នៃកិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងមាត្រា១២.៤ នៃកិច្ចព្រមព្រៀង ស្តីពីការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវឡើយ។ ការលាតត្រដាងនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវផ្តល់ឱ្យនូវពេលវេលាគ្រប់គ្រាន់ដល់ភាគីមានប្រយោជន៍ក្នុងការផ្តល់មតិយោបល់។

៣. ដើម្បីលើកកម្ពស់តម្លាភាពក្នុងការអនុវត្តកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក គូភាគីត្រូវសង្កេតការអនុវត្តនានាពាក់ព័ន្ធនឹងករណីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ឬពន្ធប៉ះប៉ូវ រវាងគូភាគីទាំងពីរ ដូចខាងក្រោម ៖

(ក) នៅពេលដែលកម្រិតនៃការលក់បង្ខូចថ្លៃត្រូវបានបង្កើតឡើង គណនា ឬត្រួតពិនិត្យ ឡើងវិញក្រោមមាត្រា២, ៩.៣, ៩.៥, និង ១១ នៃកិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ទោះផ្អែកលើមូលដ្ឋានប្រៀបធៀបតាមវិធីសាស្ត្រ មធ្យមភាគធៀបនឹងមធ្យមភាគ

ឬប្រតិបត្តិការធៀបនឹងប្រតិបត្តិការ ឬមធ្យមភាគធៀបនឹងប្រតិបត្តិការ ក្រោមមាត្រា២.៤.២ នៃកិច្ចព្រមព្រៀង ស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ រាល់កម្រិតនៃការលក់បង្ខូចថ្លៃដាច់ដោយឡែកនីមួយៗ ទោះជាក្នុងតម្លៃវិជ្ជមាន ឬអវិជ្ជមានក៏ដោយ គួរត្រូវបានគណនាក្នុងទម្រង់ជាមធ្យមភាគ។

(ខ) ភាគីម្ខាងដែលធ្វើការស៊ើបអង្កេត ត្រូវស្នើឱ្យអ្នកនាំចេញ ឬផលិតករក្នុងដែនដីរបស់ភាគីម្ខាងទៀត បំពេញព័ត៌មានឆ្លើយតបនឹងកម្រងសំណួររបស់ខ្លួនឱ្យបានទាន់ពេលវេលា។ នៅពេលភាគីម្ខាងដែលធ្វើការស៊ើបអង្កេត រកឃើញភាពខ្វះចន្លោះក្នុង ព័ត៌មានឆ្លើយតបនឹងកម្រងសំណួររបស់អ្នកនាំចេញ ឬផលិតករ ដែលទទួលបានមុនកាល បរិច្ឆេទកំណត់ ឬតម្រូវឱ្យមានការបំភ្លឺសម្រាប់គោលបំណងនៃការស៊ើបអង្កេត ភាគីម្ខាងដែលធ្វើការស៊ើបអង្កេតត្រូវទាមទារឱ្យផ្តល់ព័ត៌មានដែលខ្វះចន្លោះនោះ ឬស្នើសុំឱ្យមាន ការបំភ្លឺនូវព័ត៌មាននានាពាក់ព័ន្ធនឹងការឆ្លើយតបនឹងកម្រងសំណួរនោះ។ នីតិវិធីនេះមិនត្រូវ ប្រើប្រាស់ដើម្បីបង្កការពន្យារពេលដោយមិនចាំបាច់នានាក្នុងដំណើការស៊ើបអង្កេត ឬគេចវេសពីកាលបរិច្ឆេទកំណត់ ដូចមានចែងក្នុងច្បាប់ និងបទដ្ឋានគតិយុត្តិរបស់ភាគីម្ខាងដែលធ្វើការស៊ើបអង្កេតនោះឡើយ។

៤. ប្រសិនបើសេចក្តីសម្រេច សម្រេចឱ្យដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃស្របតាមមាត្រា៩.១ នៃកិច្ចព្រមព្រៀង ស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ភាគីម្ខាងដែលចេញសេចក្តីសម្រេចនោះអាចអនុវត្តវិធានពន្ធទាបជាង (Lesser Duty Rule) ដោយការដាក់ពន្ធដែលទាបជាងកម្រិតលក់បង្ខូចថ្លៃ ប្រសិនបើពន្ធទាបជាងនេះ នឹងមានកម្រិតល្មមគ្រប់គ្រាន់ក្នុងការលុបបំបាត់ការខូចខាតដល់ឧស្សាហកម្មក្នុងស្រុក។

## មាត្រា៥.៨៖ ការផ្តល់ព័ត៌មាន និងការពិគ្រោះយោបល់

១. នៅពេលដែលអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីម្ខាង ទទួលបានពាក្យស្នើសុំការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ដែលមានឯកសារគាំទ្រភ្ជាប់មកជាមួយត្រឹមត្រូវ ពាក់ព័ន្ធនឹងទំនិញនាំចូលពីភាគីម្ខាងទៀត ហើយមិនលើសពីរយៈពេល ១៥ថ្ងៃ មុនពេលចាប់ផ្តើមការស៊ើបអង្កេត ភាគីម្ខាងនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីម្ខាងទៀត អំពីការទទួលបានពាក្យសុំនេះ។

២. នៅពេលដែលអាជ្ញាធរស៊ើបអង្កេតរបស់ភាគីម្ខាងទទួលបានពាក្យស្នើសុំពន្ធប៉ះប៉ូវដែលមានឯកសារគាំទ្រភ្ជាប់មកជាមួយត្រឹមត្រូវ ពាក់ព័ន្ធនឹងទំនិញនាំចូលពីភាគីម្ខាងទៀត ហើយមុនពេលចាប់ផ្តើមការស៊ើបអង្កេត ភាគីម្ខាងនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីម្ខាងទៀតអំពីការទទួលបានពាក្យស្នើសុំនោះ និងត្រូវផ្តល់ដល់ភាគីម្ខាងទៀតនោះ នូវការជួបពិគ្រោះយោបល់លើពាក្យស្នើសុំនោះជាមួយអាជ្ញាធរស៊ើបអង្កេតរបស់ខ្លួន តាមការសមស្រប និងដោយអនុលោមតាមវិធាននីតិវិធីដែលមានចែងក្នុងច្បាប់ និងបទដ្ឋានគតិយុត្តិក្នុងស្រុករបស់ខ្លួន។

៣. គូភាគីអះអាងនូវសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្រោមឧបសម្ព័ន្ធ២ នៃកិច្ចព្រមព្រៀង ស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងជាពិសេសកថាខណ្ឌ៥ នៃឧបសម្ព័ន្ធនេះ និងក្រោមមាត្រា១២.៧ និងមាត្រា១២.៨ នៃកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធន និងវិធានការពន្ធប៉ះប៉ូវ។ ក្នុងករណីអាជ្ញាធរស៊ើបអង្កេតមានបំណងចេញសេចក្តីសម្រេចដោយផ្អែកលើអង្គហេតុដែលអាចស្វែងរកបានស្របតាមមាត្រា៦.៨ នៃកិច្ចព្រមព្រៀង ស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងមាត្រា១២.៧ នៃកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវ អាជ្ញាធរស៊ើបអង្កេតនោះ ត្រូវខិតខំប្រឹងប្រែងផ្តល់នូវការពន្យល់ដោយមានហេតុផលសមរម្យ និងគ្រប់គ្រាន់អំពី៖

(ក) ការចង្អុលបង្ហាញ អំពីស្ថានភាពដែលតម្រូវឱ្យប្រើប្រាស់អង្គហេតុនានាដែលអាចស្វែងរកបាន

(ខ) ព័ត៌មានដែលភាគីមានប្រយោជន៍មិនបានផ្តល់ជូនអាជ្ញាធរស៊ើបអង្កេត និង

(គ) អង្គហេតុនានាដែលអាជ្ញាធរស៊ើបអង្កេតសម្រេចដាក់ជំនួសព័ត៌មានដូចមានក្នុងវាក្យខណ្ឌ (ខ)។

## មាត្រា៥.៩៖ ការសន្យា

១. បន្ទាប់ពីអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចូលនោះ ចាប់ផ្តើមការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចថ្លៃ ឬពន្ធប៉ះប៉ូវ ភាគីនាំចូលនោះត្រូវបញ្ជូននូវព័ត៌មានលាយលក្ខណ៍អក្សរអំពីនីតិវិធីស្នើសុំអាជ្ញាធររបស់ខ្លួនឱ្យពិចារណាទទួលយកការសន្យាកែសម្រួលថ្លៃ ឬការសន្យាណាមួយ រួមទាំងរយៈពេលសម្រាប់ដាក់ចេញ និងបញ្ចប់ការសន្យាទាំងនេះ ទៅស្ថានទូតរបស់ភាគីនាំចេញដែលប្រចាំក្នុងភាគីនាំចូល ឬទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនាំចេញនោះ។

២. នៅក្នុងការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចថ្លៃ នៅពេលដែលអាជ្ញាធររបស់ភាគីនាំចូលបានចេញសេចក្តីសម្រេចបឋមថាមានការលក់បង្ខូចថ្លៃ និងមានការខូចខាតបណ្តាលមកពីការលក់បង្ខូចថ្លៃនោះ ភាគីនាំចូលនោះ ត្រូវផ្តល់ការពិចារណាដ៏ត្រឹមត្រូវ និងផ្តល់ឱកាសដល់ អ្នកនាំចេញរបស់ភាគីនាំចេញនោះ សម្រាប់ការពិគ្រោះយោបល់លើសំណើការសន្យាកែសម្រួលថ្លៃដែលក្នុងនោះ ប្រសិនបើសំណើការសន្យាកែសម្រួលថ្លៃនោះត្រូវបានទទួលយកអាចឈានដល់ការព្យួរការស៊ើបអង្កេតនេះ ដោយគ្មានការដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃឡើយ តាមរយៈវិធីសាស្ត្រដែលមានចែងក្នុងច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់ភាគីនាំចូលនោះ។

៣. នៅក្នុងការស៊ើបអង្កេតពន្ធប៉ះប៉ូវ នៅពេលដែលអាជ្ញាធររបស់ភាគីនាំចូលបានចេញសេចក្តីសម្រេចបឋមថាមានការឧបត្ថម្ភធន និងមានការខូចខាតបណ្តាលមកពីការឧបត្ថម្ភធននោះ ភាគីនាំចូលនោះ ត្រូវផ្តល់ការពិចារណាដ៏ត្រឹមត្រូវ និងផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីនាំចេញ និងអ្នកនាំចេញរបស់ភាគីនាំចេញនោះ សម្រាប់ការពិគ្រោះយោបល់លើសំណើការសន្យា ដែលក្នុងនោះប្រសិនបើសំណើការសន្យានោះត្រូវបានទទួលយក អាចឈានដល់ការព្យួរការស៊ើបអង្កេតនេះ ដោយមិនមានការដាក់ពន្ធប៉ះប៉ូវ តាមរយៈវិធីសាស្ត្រដែលមានចែងក្នុងច្បាប់ បទដ្ឋានគតិយុត្ត និងនីតិវិធីរបស់ភាគីនាំចូលនោះ។

**មាត្រា៥.១០៖ ការស៊ើបអង្កេតក្រោយបញ្ចប់**

ភាគីម្ខាង ត្រូវខិតខំប្រឹងប្រែងពិនិត្យដោយប្រុងប្រយ័ត្នបំផុតលើរាល់ពាក្យស្នើសុំ ឱ្យចាប់ផ្តើមការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចចំពោះទំនិញមានដើមកំណើតនាំចូលភាគីម្ខាងទៀត ដែលវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃចំពោះទំនិញនោះ ត្រូវបានដកចេញក្នុងរយៈពេល ១២ខែមុន ដែលជាលទ្ធផលនៃការត្រួតពិនិត្យឡើងវិញ។ លើកលែងតែការពិនិត្យមុនពេលចាប់ផ្តើមស៊ើបអង្កេត ចង្អុលបង្ហាញថាកាលៈទេសៈបានប្រែប្រួល នោះការស៊ើបអង្កេតនេះមិនត្រូវបន្តឡើយ។

**មាត្រា៥.១១៖ ការវាយតម្លៃរួមបញ្ចូលគ្នា**

ដោយមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចក្រោមមាត្រា៣.៣ នៃកិច្ចព្រមព្រៀង ស្តីពីការប្រឆាំងការលក់បង្ខូចថ្លៃ និងមាត្រា១៥.៣ នៃកិច្ចព្រមព្រៀង ស្តីពីការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវ នៅពេលការនាំចូលពីប្រទេសច្រើនលើសពីមួយ ជាកម្មវត្ថុរួមគ្នានៃការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចថ្លៃ ឬពន្ធប៉ះប៉ូវ ភាគីម្ខាងត្រូវពិនិត្យដោយប្រុងប្រយ័ត្នបំផុត ថាតើការវាយតម្លៃរួមបញ្ចូលគ្នាពីផលប៉ះពាល់នៃការនាំចូល ពីភាគីម្ខាងទៀតមានលក្ខណៈសមស្របឬទេ ដោយពិចារណាលើស្ថានភាពនៃការប្រកួតប្រជែងរវាងទំនិញនាំចូល និងស្ថានភាពនៃការប្រកួតប្រជែងរវាងទំនិញនាំចូល និងទំនិញក្នុងស្រុក។

**មាត្រា៥.១២៖ ការមិនអនុវត្តការយន្តការដោះស្រាយវិវាទ**

មិនមានភាគីណាមួយ អាចប្រើប្រាស់យន្តការដោះស្រាយវិវាទក្រោមជំពូកទី៨ (ការដោះស្រាយទំនាស់) ចំពោះរាល់បញ្ហាដែលកើតមានឡើងក្រោមផ្នែកនេះឡើយ។

# ជំពូកទី ៦
# កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

## មាត្រា៦.១៖ គោលបំណង

១. ដោយទទួលស្គាល់សារៈសំខាន់នៃគំនិតផ្តួចផ្តើមកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសនានាដែលកំពុងអនុវត្ត គូភាគីឯកភាពទទួលយកបន្ថែមនូវភាពជាដៃគូសេដ្ឋកិច្ចដែលមានស្រាប់នៅក្នុងផ្នែក ដែលគូភាគីទាំងពីរអាចទទួលបានផលប្រយោជន៍ពីគ្នាទៅវិញទៅមក ដោយពិចារណាលើកម្រិតខុសគ្នានៃការអភិវឌ្ឍ និងសមត្ថភាពរបស់គូភាគី។

២. គូភាគីឯកភាពថា កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស មានគោលបំណងបង្រួមគម្លាតនៃការអភិវឌ្ឍរវាងគូភាគី និងពង្រីកអត្ថប្រយោជន៍ទៅវិញទៅមក ចេញពីការអនុវត្ត និងការប្រើប្រាស់កិច្ចព្រមព្រៀងនេះ។

៣. គូភាគីឯកភាពថា កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមានគោលបំណងបំពេញតម្រូវការជាក់លាក់ និងលក្ខខណ្ឌតម្រូវ ដែលស្របទៅនឹងវិស័យអាទិភាពក្រោមកិច្ចព្រមព្រៀងនេះ តាមរយៈការអនុវត្តសកម្មភាពកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស រួមទាំងកម្មវិធីពង្រឹងសមត្ថភាពនិងជំនួយបច្ចេកទេស និងជាពិសេសកម្មវិធីការងារ។

៤. គូភាគីទទួលស្គាល់ភាពចាំបាច់ក្នុងការពង្រឹង និងលើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្ម និងវិនិយោគ ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

## មាត្រា៦.២៖ វិស័យសម្រាប់កិច្ចសហប្រតិបត្តិការ

១. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្រោមជំពូកនេះ ត្រូវគាំទ្រដល់ការអនុវត្ត និងការប្រើប្រាស់កិច្ចព្រមព្រៀងនេះប្រកបដោយបរិយាប័ន្ន ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព តាមរយៈសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ឬការវិនិយោគ ដូចមានចែងក្នុងកម្មវិធីការងារ។

២. គូភាគីត្រូវស្វែងរក និងអនុវត្តសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដូចជាការកសាងសមត្ថភាព និងជំនួយបច្ចេកទេស ដែលផ្តោតលើវិស័យនានា ដូចខាងក្រោម៖

(ក) ពាណិជ្ជកម្ម និងការជំរុញការវិនិយោគ

(ខ) កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

(គ) ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

(ឃ) បទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារ និងនីតិវិធីវាយតម្លៃអនុលោមភាព

(ង) វិធានការអនាម័យ និងភូតគាមអនាម័យ

(ច) ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការវិនិយោគ

(ឆ) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

(ជ) ការអភិវឌ្ឍឧស្សាហកម្ម

(ឈ) បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និង

(៣) វិស័យផ្សេងៗទៀត ដូចបានព្រមព្រៀងរវាងគូភាគី។

៣. **ការជំរុញពាណិជ្ជកម្ម៖** គូភាគីត្រូវសហការគ្នាក្នុងការជំរុញសកម្មភាពពាណិជ្ជកម្ម និងការវិនិយោគ តាមរយៈទីភ្នាក់ងាររដ្ឋាភិបាល ឬអង្គភាពផ្សេងៗ។ កិច្ចសហប្រតិបត្តិការនេះអាចរួមបញ្ចូល ប៉ុន្តែ មិនកំណត់ត្រឹមតែ ការរៀបចំសកម្មភាពជំរុញពាណិជ្ជកម្មនិងការវិនិយោគ ដូចជាបេសកកម្មពាណិជ្ជកម្ម និងការវិនិយោគ សិក្ខាសាលា និងវេទិកាពាណិជ្ជកម្មជាប្រចាំ។

៤. **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖** គូភាគីទទួលស្គាល់នូវកាលានុវត្តភាពដែលមានស្រាប់ក្នុងការរៀបចំកិច្ចសហប្រតិបត្តិការ និងបច្ចេកទេសក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ នេសាទ វារីវប្បកម្ម កសិ-ឧស្សាហកម្ម សន្តិសុខស្បៀង អេកូទេសចរណ៍ និងការវិនិយោគក្នុងកសិដ្ឋាន និងបរិក្ខានានា ដើម្បីផ្តល់អត្ថប្រយោជន៍ដល់គ្នាទៅវិញទៅមក។

៥. **ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖** ដោយទទួលស្គាល់នូវតួនាទីស្នូលរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងការសម្រួលនិងពង្រីកពាណិជ្ជកម្ម គូភាគីត្រូវសហការគ្នាជំរុញការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីទទួលបានអត្ថប្រយោជន៍អតិបរមាពីការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ កិច្ចសហប្រតិបត្តិការនេះអាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមតែការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការពង្រឹងគោលនយោបាយនិងបទប្បញ្ញត្តិ ស្តីពីការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការដោះស្រាយបញ្ហាប្រឈមទាក់ទងនឹងការអភិវឌ្ឍ និងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៦. **បទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារ និងនីតិវិធីវាយតម្លៃភាពអនុលោម ៖** ដោយទទួលស្គាល់នូវតួនាទីសំខាន់នៃបទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារ និងនីតិវិធីវាយតម្លៃភាពអនុលោម ក្នុងការសម្រួលពាណិជ្ជកម្មទំនិញ គូភាគីត្រូវពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួន ដោយឈរលើមូលដ្ឋាននៃផលប្រយោជន៍ទៅវិញទៅមក។ កិច្ចសហប្រតិបត្តិការនេះ អាចរួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹមតែការអភិវឌ្ឍមន្ទីរពិសោធន៍សាកល្បង និងបណ្តាញទទួលស្គាល់គុណភាព ក៏ដូចជាកម្មវិធីសាកល្បង និងការអភិវឌ្ឍបទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារ និងនីតិវិធីវាយតម្លៃភាពអនុលោម នៅក្នុងវិស័យដែលមានផលចំណេញទៅវិញទៅមក។

៧. **វិធានការអនាម័យ និងភូតគាមអនាម័យ៖** ដោយទទួលស្គាល់នូវសារៈសំខាន់នៃវិធានការអនាម័យ និងភូតគាមអនាម័យ (តទៅនេះហៅកាត់ថា SPS) ក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើពាណិជ្ជកម្ម ហើយទន្ទឹមនឹងនេះផងដែរ ការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ គូភាគីត្រូវបង្កើតកិច្ចសហប្រតិបត្តិការដើម្បីផលប្រយោជន៍ទៅវិញទៅមករបស់គូភាគី។

៨. **ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការវិនិយោគ៖** ដោយទទួលស្គាល់នូវតួនាទីដ៏សំខាន់នៃក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការវិនិយោគ ក្នុងការសម្រួលពាណិជ្ជកម្ម និងឱកាសវិនិយោគ ជាមួយនឹងជំនួយជាហិរញ្ញវត្ថុ និងបច្ចេកទេស ដែលកៀរគរ និងផ្តល់មូលនិធិពីគូភាគី គូភាគីត្រូវធ្វើកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍ និងពង្រឹងក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្ម។ កិច្ចសហប្រតិបត្តិការ

នេះ អាចរួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹមតែ ការជួយដល់ការអភិវឌ្ឍប្រព័ន្ធច្បាប់ ដូចជា ច្បាប់ស្តីពីកិច្ចសន្យា ច្បាប់ស្តីពីពាណិជ្ជកម្ម ច្បាប់ស្តីពីចំណីអាហារ និងច្បាប់ដទៃទៀត ដែលមានការព្រមព្រៀងពីគូភាគី។

៩. **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖** គូភាគីនឹងត្រូវស្វែងរកកាលានុវត្តភាព ដើម្បីធ្វើកិច្ចសហប្រតិបត្តិការក្នុងវិស័យនានា រួមទាំង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំណង់ បច្ចេកវិទ្យាសំណង់ និងការរចនាហេដ្ឋារចនាសម្ព័ន្ធសំណង់។

១០. **ការអភិវឌ្ឍឧស្សាហកម្ម៖** គូភាគីត្រូវជំរុញកិច្ចសហប្រតិបត្តិការផ្នែកឧស្សាហកម្មដែលបានកែសម្រួលឱ្យប្រសើរឡើង ដើម្បីទទួលបានវិបុលភាពទៅវិញទៅមក នៅក្នុងវិស័យនានា រួមទាំងការធ្វើពិពិធកម្ម និងការធ្វើឱ្យកាន់តែប្រសើរឡើងនូវរចនាសម្ព័ន្ធឧស្សាហកម្ម ការកសាងហេដ្ឋារចនាសម្ព័ន្ធថាមពលសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម និងទីផ្សារសម្ភារៈឧស្សាហកម្មនិងបរិក្ខារសំណង់ ដើម្បីឆ្លើយតបនឹងតម្រូវការ និងការផ្គត់ផ្គង់។

១១. **បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍៖** ដោយទទួលស្គាល់នូវការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (តទៅនេះហៅកាត់ថា ICT) និងការអនុវត្តធុរកិច្ចសេវាកម្មពាក់ព័ន្ធនឹង ICT ទាំងក្នុងបរិបទក្នុងស្រុក និងអន្តរជាតិ ដែលដឹកនាំដោយវិស័យឯកជន គូភាគី ត្រូវធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីលើកកម្ពស់ការអភិវឌ្ឍ ICT និងសេវាកម្មពាក់ព័ន្ធនឹង ICT ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមាពីការប្រើប្រាស់ ICT។ កិច្ចសហប្រតិបត្តិការនេះ អាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមតែ ការពង្រឹងគោលនយោបាយ ICT ការបង្កើតសេវាកម្មពាក់ព័ន្ធនឹង ICT ការផ្តល់សេវាកម្មរដ្ឋាភិបាលអេឡិចត្រូនិក ការអភិវឌ្ឍមាតិកា បណ្តាញសន្តិសុខនិងការការពារសិទ្ធិឯកជន បណ្តាញហេដ្ឋារចនាសម្ព័ន្ធ ឧស្សាហកម្មច្នៃប្រឌិតនិងពហុមេឌា និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ICT។

១២. កិច្ចសហប្រតិបត្តិការ ដើម្បីកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចនៃជំងឺរាតត្បាតជាសកល ដូចបានចែងនៅក្នុងឧបសម្ព័ន្ធ៦-ក។

## មាត្រា៦.៣៖ ការកសាងសមត្ថភាព និងជំនួយបច្ចេកទេស

ដោយទទួលស្គាល់នូវគម្លាតនៃការអភិវឌ្ឍ និងគម្លាតសមត្ថភាពរវាងគូភាគី និងសារៈសំខាន់នៃការកសាងសមត្ថភាពសម្រាប់ការពង្រីកពាណិជ្ជកម្ម និងការវិនិយោគ គូភាគី ត្រូវអភិវឌ្ឍសកម្មភាពការកសាងសមត្ថភាព និងជំនួយបច្ចេកទេស ដូចបានព្រមព្រៀងដោយគូភាគី ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ និងវិស័យផ្សេងៗទៀត ដូចបានព្រមព្រៀងរវាងគូភាគី។

## មាត្រា៦.៤៖ គណៈកម្មការ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

១. ក្នុងគោលបំណងដើម្បីអនុវត្តជំពូកនេះប្រកបដោយប្រសិទ្ធភាព គណៈកម្មការ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដែលមានសមាសភាពជាអ្នកតំណាងរដ្ឋាភិបាលនៃភាគីនីមួយៗ ត្រូវបានបង្កើតឡើង។

២. មុខងាររបស់គណៈកម្មការ ត្រូវរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមតែសកម្មភាពដូចខាងក្រោម៖

(ក) អភិវឌ្ឍ និងសម្របសម្រួលកម្មវិធីការងារ និងយន្តការអនុវត្ត

(ខ) ធ្វើការជាមួយគណៈកម្មការដទៃទៀត ដើម្បីបង្កើត និងរក្សាទំនាក់ទំនង និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាព លើសកម្មភាពកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបញ្ហាពាក់ព័ន្ធនានា និង

(គ) តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីការងារ ដើម្បីវាយតម្លៃវឌ្ឍនភាពកម្មវិធីការងារ ក៏ដូចជាផ្តល់អនុសាសន៍ដល់គូភាគី នៅពេលចាំបាច់ ដើម្បីពង្រឹងការអនុវត្ត។

**មាត្រា៦.៥៖ កម្មវិធីការងារ**

១. សម្រាប់គោលបំណងនៃជំពូកនេះ កម្មវិធីការងារសំដៅដល់បញ្ជីនៃសកម្មភាពកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដែលត្រូវបានកំណត់ដោយគូភាគី។ កម្មវិធីការងារនឹងត្រូវបានត្រួតពិនិត្យដោយគណៈកម្មការ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធិភាព។

២. កម្មវិធីការងារនឹងត្រូវរៀបចំបង្កើតដោយគណៈកម្មការ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដោយមានការពិគ្រោះយោបល់ ជាមួយគណៈកម្មការដែលបានបង្កើតឡើងដទៃទៀត ក្នុងកិច្ចព្រមព្រៀងនេះ ដោយពិចារណាលើវិស័យអាទិភាព នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។

៣. ដើម្បីជំរុញការអនុវត្ត និងការប្រើប្រាស់កិច្ចព្រមព្រៀងនេះប្រកបដោយប្រសិទ្ធិភាព នៅក្នុងកម្មវិធីការងារ គូភាគីត្រូវផ្តល់អាទិភាពលើការបង្កើតកិច្ចសហប្រតិបត្តិការ តាមដែលអាចធ្វើទៅបាន ដូចខាងក្រោម៖

(ក) គាំទ្រការអភិវឌ្ឍធនធានមនុស្ស ការកសាងសមត្ថភាព ជំនួយបច្ចេកទេស ការផ្លាស់ប្តូរយោបល់និងព័ត៌មាន និងការគាំទ្រហិរញ្ញវត្ថុពីធនធានដែលមាន

(ខ) លើកកម្ពស់ការយល់ដឹងរបស់សាធារណៈ អំពីវិស័យរួមសំខាន់ៗ របស់គូភាគី

(គ) ពង្រឹងការទទួលបានព័ត៌មាន និងកាលានុវត្តភាពសម្រាប់ធុរកិច្ច

(ឃ) ធ្វើការស្រាវជ្រាវ និងអភិវឌ្ឍរួមគ្នា រួមទាំងការផ្លាស់ប្តូរអ្នកជំនាញផងដែរ

(ង) ចែករំលែកបទពិសោធន៍ ឧត្តមានុវត្តន៍ និងគម្រូល្អៗ សម្រាប់ការអភិវឌ្ឍវិស័យរួមសំខាន់ៗ

(ច) រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍

(ឆ) ផ្ទេរបច្ចេកវិទ្យា

(ជ) រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញ និងសិក្ខាសាលារួមគ្នា ដើម្បីផ្សព្វផ្សាយចំណេះដឹង និងបទពិសោធន៍ក្នុងការអនុវត្តច្បាប់ និងបង្កើតគម្រោង ដើម្បីពង្រឹងច្បាប់ទាក់ទងនឹងពាណិជ្ជកម្ម និងការវិនិយោគ

(ឈ) ពង្រឹងកិច្ចសហប្រតិបត្តិការនៅវេទិកាពាក់ព័ន្ធនៅក្នុងតំបន់ និងអន្តរជាតិ និង

(ញ) ទម្រង់នៃកិច្ចសហប្រតិបត្តិការដទៃទៀត ដូចបានព្រមព្រៀងរវាងគូភាគី។

៤. កម្មវិធីការងារនឹងត្រូវបានកែសម្រួលដោយគណៈកម្មការ ប្រសិនបើមានការចាំបាច់ ដោយមានការឯកភាពពីគូភាគី។

៥. ភាគីនីមួយៗនឹងត្រូវចាត់តាំងមន្ត្រីពាក់ព័ន្ធជាមន្ត្រីបង្គោលសម្រាប់សម្របសម្រួលការអនុវត្តកម្មវិធីការងារ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។ ភាគីនីមួយៗត្រូវផ្តល់ព័ត៌មានទំនាក់ទំនងលម្អិតអំពីមន្ត្រីបង្គោលរៀងៗខ្លួន ហើយជូនដំណឹងភ្លាមៗអំពីការផ្លាស់ប្តូរមន្ត្រីបង្គោល ឬការកែប្រែណាមួយអំពីព័ត៌មានលម្អិតរបស់មន្ត្រីបង្គោល។

៦. គូភាគីត្រូវស្វែករកកាលានុវត្តភាពនានាដើម្បីបញ្ចូលគម្រោងវិនិយោគអាទិភាពនៅក្នុងវិស័យជាប្រយោជន៍សម្រាប់ភាគីនីមួយៗ នៅក្នុងកម្មវិធីការងារ។

## មាត្រា៦.៦៖ ធនធាន

១. គូភាគីត្រូវផ្តល់ធនធានសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្រោមជំពូកនេះ យោងទៅតាមការព្រមព្រៀងរវាងគូភាគី។

២. គូភាគីត្រូវប្រើប្រាស់មធ្យោបាយហិរញ្ញវត្ថុដែលមានស្រាប់ ឬធនធានដទៃទៀតសម្រាប់កម្មវិធីការងារនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ក្រោមកិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ក្នុងស្រុករបស់ភាគីនីមួយៗ។

៣. ដោយផ្អែកលើមូលដ្ឋាននៃការផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក គូភាគីអាចពិចារណាកិច្ចសហប្រតិបត្តិការជាមួយ និងការរួមចំណែកពី៖

(ក) ភាគីដទៃ ដៃគូអភិវឌ្ឍន៍ ឬ

(ខ) អង្គការ ឬស្ថាប័ននៅក្នុងអនុតំបន់ តំបន់ ឬអន្តរជាតិ

ដែលមានចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍ កិច្ចសហប្រតិបត្តិ និងភាពជាដៃគូ ដែលមានផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ដើម្បីគាំទ្រការអភិវឌ្ឍកម្មវិធីការងារ។

## មាត្រា៦.៧៖ ការមិនអនុវត្តការដោះស្រាយវិវាទ

យន្តការដោះស្រាយវិវាទនៅក្នុងកិច្ចព្រមព្រៀងនេះ មិនត្រូវយកមកអនុវត្តចំពោះបញ្ហាណាមួយ ដែលកើតមានឡើងក្រោមជំពូកនេះឡើយ។

## ជំពូកទី ៧
## តម្លាភាព

### មាត្រា៧.១៖ និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ៖

**សេចក្តីសម្រេចរដ្ឋបាលអនុវត្តទូទៅ** សំដៅដល់សេចក្តីសម្រេចរដ្ឋបាល ឬការបកស្រាយដែលអនុវត្តចំពោះបុគ្គលទាំងអស់ និងគ្រប់ស្ថានភាពអង្គហេតុ ដែលស្ថិតនៅក្នុងដែនអំណាចរបស់សេចក្តីសម្រេចរដ្ឋបាល និងដែលបង្កើតនូវបទដ្ឋានប្រតិបត្តិមួយ ប៉ុន្តែមិនរាប់បញ្ចូល៖

(ក) សេចក្តីសម្រេចដែលត្រូវបានធ្វើឡើងក្នុងដំណើរការនីតិវិធីរដ្ឋបាល ឬនីតិវិធីប្រហាក់ប្រហែលតុលាការ ដែលអនុវត្តចំពោះបុគ្គល ទំនិញ ឬសេវាជាក់លាក់នៃភាគីម្ខាងទៀតនៅក្នុងករណីជាក់លាក់មួយ ឬ

(ខ) សេចក្តីសម្រេចដែលធ្វើការវិនិច្ឆ័យពាក់ព័ន្ធនឹងសកម្មភាព ឬការអនុវត្តជាក់លាក់មួយ។

### មាត្រា៧.២៖ ការបោះពុម្ពផ្សាយ

១. ភាគីនីមួយៗត្រូវធានាថាច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងសេចក្តីសម្រេចរដ្ឋបាលអនុវត្តទូទៅពាក់ព័ន្ធនឹងបញ្ហាណាមួយដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ត្រូវបានបោះពុម្ពផ្សាយភ្លាមៗ ឬធ្វើឱ្យអាចរកបានជាសាធារណៈនៅក្នុងទម្រង់ណាមួយ ដែលអនុញ្ញាតឱ្យបុគ្គលពាក់ព័ន្ធ និងភាគីម្ខាងទៀត បានដឹងពីច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងសេចក្តីសម្រេចរដ្ឋបាលទាំងនេះ។

២. ក្នុងករណីដែលអាចធ្វើទៅបាននិងអាចអនុវត្តបាន ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន ភាគីនីមួយៗត្រូវ៖

(ក) បោះពុម្ពផ្សាយជាមុននូវវិធានការដែលមានចែងនៅក្នុងកថាខណ្ឌទី១ ដែលខ្លួនរៀបចំអនុម័ត និង

(ខ) ផ្តល់ជូនបុគ្គលពាក់ព័ន្ធ និងភាគីម្ខាងទៀតនូវឱកាសសមស្របចំពោះការផ្តល់មតិយោបល់លើវិធានការដែលបានដាក់ស្នើទាំងនេះ។

### មាត្រា៧.៣៖ ព័ត៌មាន

តាមការស្នើសុំរបស់ភាគីម្ខាង ក្នុងករណីដែលអាចធ្វើទៅបាននិងអាចអនុវត្តបាន ភាគីម្ខាងទៀតត្រូវផ្តល់នូវព័ត៌មាន និងឆ្លើយតបភ្លាមៗ ចំពោះសំណួរពាក់ព័ន្ធនឹងវិធានការជាក់ស្តែង ឬវិធានការដែលបានដាក់ស្នើដែលមានចែងនៅក្នុងមាត្រា៧.២ ដែលភាគីស្នើសុំ ចាត់ទុកថាអាចមានផលប៉ះពាល់ដល់ប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ ដោយមិនគិតថាភាគីស្នើសុំនោះ ត្រូវបានជូនដំណឹងអំពីវិធានការនោះពីមុនមកទេ។

### មាត្រា៧.៤៖ ដំណើរការនីតិវិធីរដ្ឋបាល

ដើម្បីគ្រប់គ្រងច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងសេចក្តីសម្រេចរដ្ឋបាលអនុវត្តទូទៅរបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហាណាមួយដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ក្នុងទម្រង់មួយដែលមានសង្គតិភាព មិនលម្អៀង និងសមស្របនៅក្នុងដំណើរការនីតិវិធីរដ្ឋបាលរបស់ខ្លួនដែលបានអនុវត្តនូវវិធានការទាំងឡាយដែលមានចែងនៅក្នុងមាត្រា៧.២ ចំពោះបុគ្គល ទំនិញ ឬសេវាជាក់លាក់នៃភាគីម្ខាងទៀតក្នុងករណីជាក់លាក់ ភាគីនីមួយៗត្រូវធានាថា៖

(ក) ក្នុងករណីដែលអាចធ្វើទៅបានដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន បុគ្គលនៃភាគីម្ខាងទៀតដែលរងផលប៉ះពាល់ដោយផ្ទាល់ពីដំណើរការនីតិវិធី ត្រូវបានផ្តល់ជូននូវការជូនដំណឹងសមស្រប អំពីពេលវេលាដែលដំណើរការនីតិវិធីត្រូវបានផ្តួចផ្តើម រួមបញ្ចូលទាំងការពិពណ៌នាអំពីលក្ខណៈនៃដំណើរការនីតិវិធី សេចក្តីបញ្ជាក់របស់អាជ្ញាធរច្បាប់ដែលមានសមត្ថកិច្ចលើដំណើរការនីតិវិធីដែលបានផ្តួចផ្តើម និងការពិពណ៌នាទូទៅ អំពីបញ្ហាណាមួយដែលស្ថិតក្នុងភាពចម្រូងចម្រាស់

(ខ) បុគ្គលនៃភាគីម្ខាងទៀតដែលរងផលប៉ះពាល់ដោយផ្ទាល់ពីដំណើរការនីតិវិធី ត្រូវបានផ្តល់ឱ្យនូវឱកាសសមស្រប ដើម្បីបង្ហាញអង្គហេតុ និងសេចក្តីសំអាងនានាក្នុងការគាំទ្រជំហររបស់បុគ្គលនោះ នៅមុនពេលមានសកម្មភាពរដ្ឋបាលស្ថាពរណាមួយកើតឡើង ប្រសិនបើពេលវេលា លក្ខណៈនៃដំណើរការនីតិវិធី និងផលប្រយោជន៍សាធារណៈអនុញ្ញាត និង

(គ) នីតិវិធីទាំងនោះត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

## មាត្រា៧.៥៖ ការត្រួតពិនិត្យឡើងវិញ និងការប្តឹងតវ៉ា

១. ភាគីនីមួយៗត្រូវបង្កើត ឬរក្សាទុក នូវសាលាជម្រះក្តី ឬនីតិវិធី ក្នុងប្រព័ន្ធតុលាការ ឬប្រហាក់ប្រហែលនឹងតុលាការ ឬរដ្ឋបាល សម្រាប់គោលបំណងនៃការពិនិត្យឡើងវិញភ្លាមៗ និងការកែតម្រូវបណ្តឹងរដ្ឋបាលទាំងឡាយពាក់ព័ន្ធនឹងបញ្ហាណាមួយដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ដែលត្រូវបានបញ្ជាក់អះអាងផងដែរ។ សាលាជម្រះក្តីទាំងនេះ ត្រូវមិនលម្អៀង និងភាពឯករាជ្យពីស្ថាប័ន ឬអាជ្ញាធរដែលត្រូវបានប្រគល់សិទ្ធិអនុវត្តវិធានរដ្ឋបាល និងមិនត្រូវមានផលប្រយោជន៍ជាដុំកំភួនណាមួយនៅក្នុងសេចក្តីសម្រេចនៃបញ្ហាឡើយ។

២. ភាគីនីមួយៗត្រូវធានាថានៅក្នុងសាលាជម្រះក្តី ឬនីតិវិធីណាមួយទាំងនេះ គូភាគីក្នុងដំណើរការនីតិវិធី ត្រូវបានផ្តល់ជូននូវសិទ្ធិទទួលបាន៖

(ក) ឱកាសសមស្រប ដើម្បីគាំទ្រ ឬការពារជំហររបស់ខ្លួនផ្ទាល់ និង

(ខ) សេចក្តីសម្រេចដែលផ្អែកលើភស្តុតាង និងការដាក់កំណត់ហេតុ ឬកំណត់ហេតុដែលបានចងក្រងដោយអាជ្ញាធររដ្ឋបាល ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន។

៣. ដោយផ្អែកទៅលើការប្តឹងតវ៉ា និងត្រួតពិនិត្យឡើងវិញបន្ថែមទៀតដូចដែលមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញតិក្នុងស្រុករបស់ខ្លួន ភាគីនីមួយៗ ត្រូវធានាថា សេចក្តីសម្រេចណាមួយដែលមានចែងនៅក្នុងវាក្យខណ្ឌទី២(ខ) ត្រូវបានអនុវត្តដោយនិងត្រូវដឹកនាំការអនុវត្តរបស់ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធនឹងបណ្តឹងរដ្ឋបាលដែលជាកម្មវត្ថុ។

## មាត្រា៧.៦៖ កិច្ចសហប្រតិបត្តិការ ស្តីពីការលើកកម្ពស់ការបង្កើនតម្លាភាព និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

១. គូភាគីឯកភាពគ្នាធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលើកកម្ពស់តម្លាភាពពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិ។

២. គូភាគីអះអាងដោះស្រាយដើម្បីប្រយុទ្ធប្រឆាំងនឹងការសូកប៉ាន់ និងអំពើពុករលួយក្នុងពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិរបស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលអាចអនុវត្តបានរបស់ខ្លួន។

៣. ដោយផ្សារភ្ជាប់ទៅនឹងគោលការណ៍រដ្ឋបាលល្អ គូភាគីឯកភាពគ្នាធ្វើកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់គុណភាពនិយ័តកម្ម និងសម្មិទ្ធកម្ម រួមបញ្ចូលទាំងតាមរយៈការផ្លាស់ប្តូរព័ត៌មាន និងឧត្តមានុវត្តន៍អំពីគោលនយោបាយ និងបទដ្ឋានគតិយុត្តរបស់គូភាគីរៀងៗខ្លួន។

# ជំពូកទី ៨
# ការដោះស្រាយវិវាទ

## មាត្រា៨.១៖ និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ៖

**ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម** សំដៅដល់ក្រុមប្រឹក្សាជំនុំជម្រះដែលត្រូវបានបង្កើតឡើងក្រោមមាត្រា៨.៧

**មជ្ឈត្តករ** សំដៅដល់សមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះដែលត្រូវបានបង្កើតឡើងក្រោមមាត្រា៨.៧

**បេក្ខជន** សំដៅដល់បុគ្គលដែលស្ថិតក្រោមការពិចារណាសម្រាប់ការតែងតាំងជាមជ្ឈត្តករក្រោមមាត្រា៨.៩

**ភាគីប្តឹងតវ៉ា** សំដៅដល់ភាគីម្ខាងដែលស្នើសុំបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មក្រោមមាត្រា៨.៧ និង

**ភាគីរងបណ្តឹង** សំដៅដល់ភាគីម្ខាងដែលត្រូវបានចោទប្រកាន់ថាបានរំលោភបំពានទៅនឹងកិច្ចព្រមព្រៀងនេះ ដូចមានចែងក្នុងមាត្រា៨.៣។

## មាត្រា៨.២៖ គោលបំណង

១. គោលបំណងនៃជំពូកនេះ គឺដើម្បីផ្តល់ឱ្យនូវដំណើរការប្រកបដោយស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព និងតម្លាភាពសម្រាប់ការបញ្ចៀស និងការដោះស្រាយវិវាទដែលកើតឡើងពីកិច្ចព្រមព្រៀងនេះ។

២. ជានិច្ចកាល គូភាគីត្រូវខិតខំប្រឹងប្រែងឯកភាពគ្នាលើការបកស្រាយ និងការអនុវត្តកិច្ចព្រមព្រៀងនេះ ហើយត្រូវព្យាយាមសម្រេចឱ្យបាននូវដំណោះស្រាយ ដែលមានការពេញចិត្តទាំងសងខាង ចំពោះបញ្ហាដែលត្រូវបានលើកឡើងដោយអនុលោមតាមជំពូកនេះ តាមរយៈកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់។

## មាត្រា៨.៣៖ វិសាលភាព

១. លើកលែងតែមានចែងផ្សេងពីនេះ ជំពូកនេះត្រូវយកមកអនុវត្តសម្រាប់ការបញ្ចៀស ឬការដោះស្រាយវិវាទរវាងគូភាគី ចំពោះការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ នៅពេលណាដែលភាគីម្ខាងពិចារណាថា៖

(ក) វិធានការអនុម័តដោយភាគីម្ខាងទៀត មិនមានសង្គតិភាពជាមួយនឹងកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ឬ

(ខ) ភាគីម្ខាងទៀត បានខកខានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ។

២. ជំពូកនេះមិនត្រូវអនុវត្តឡើយ ចំពោះជំពូកទី៦ (កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច) ផ្នែក ខ (ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ) ក្រោមជំពូកទី៥ (ឧបាស្រ័យពាណិជ្ជកម្ម) មាត្រា ២.១៥ (វិធានការអនាម័យនិងភូតគាមអនាម័យ) និងមាត្រា៧.៦ (កិច្ចសហប្រតិបត្តិការ ស្តីពីការលើកកម្ពស់ការបង្កើនតម្លាភាព និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ) និងឧបសម្ព័ន្ធ៣-ខ (ប្រព្រឹត្តិកម្មចំពោះទំនិញជាក់លាក់មួយចំនួន)។

## មាត្រា៨.៤៖ ជម្រើសវេទិកា

១. នៅពេលមានវិវាទកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ និងក្រោមកិច្ចព្រមព្រៀងដទៃទៀតដែលភាគីទាំងពីរជាភាគី រួមទាំងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ភាគីប្តឹងតវ៉ាអាចប្រើ

ប្រាស់នីតិវិធីដោះស្រាយវិវាទដែលមានស្រាប់ក្រោមកិច្ចព្រមព្រៀងទាំងនោះ ក្នុងការដោះស្រាយវិវាទ។

២. នៅពេលភាគីប្តឹងតវ៉ាបានស្នើសុំបង្កើត ឬបញ្ជូនរឿងក្តីទៅក្រុមប្រឹក្សាជំនុំជម្រះសម្រាប់ការដោះស្រាយវិវាទក្រោមកិច្ចព្រៀងណាមួយដូចដែលមានចែងនៅក្នុងកថាខណ្ឌ១ វេទិកាដែលត្រូវបានជ្រើសរើសនេះ ត្រូវយកមកប្រើប្រាស់ផ្តាច់មុខ ដោយមិនអាចប្រើប្រាស់វេទិកាដទៃទៀតបានឡើយ។

## មាត្រា៨.៥៖ ការពិគ្រោះយោបល់

១. ភាគីណាមួយ អាចស្នើសុំការពិគ្រោះយោបល់ជាមួយភាគីម្ខាងទៀត លើរាល់បញ្ហានានាពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តកិច្ចព្រមព្រៀងនេះ ដូចមានចែងក្នុងមាត្រា៨.៣.១។

២. ភាគីដែលស្នើសុំការពិគ្រោះយោបល់ត្រូវធ្វើសំណើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវផ្តល់នូវសំអាងហេតុ រួមបញ្ចូលទាំងការកំណត់ អំពីវិធានការដាក់លាក់ដែលចោទជាបញ្ហា និងការចង្អុលបង្ហាញអំពីមូលដ្ឋានអង្គហេតុ និងមូលដ្ឋានច្បាប់សម្រាប់ពាក្យបណ្តឹងនេះ។

៣. ភាគីរងបណ្តឹងត្រូវឆ្លើយតបក្នុងរយៈពេល ១០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើសុំការពិគ្រោះយោបល់។

៤. គូភាគីត្រូវចូលរួមការពិគ្រោះយោបល់ដោយសុចរិត និងស្មោះត្រង់ក្នុងរយៈពេល ៣០ថ្ងៃ ឬ១៥ថ្ងៃក្នុងករណីបន្ទាន់ រួមបញ្ចូលទាំងករណីពាក់ព័ន្ធនឹងទំនិញងាយខូចគុណភាព គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើសុំការពិគ្រោះយោបល់ ក្នុងគោលបំណងដើម្បីសម្រេចបាននូវដំណោះស្រាយដែលមានការពេញចិត្តទាំងសងខាង។ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះការពិគ្រោះយោបល់ត្រូវធ្វើឡើងក្នុងទឹកដីនៃភាគីរងបណ្តឹង។

៥. ក្នុងអំឡុងពេលពិគ្រោះយោបល់ គូភាគីត្រូវផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ ដើម្បីជួយឱ្យមានការពិនិត្យបានពេញលេញ ថាតើវិធានការដែលចោទជាបញ្ហានោះ អាចប៉ះពាល់ដល់ការប្រតិបត្តិនិងការអនុវត្តនូវកិច្ចព្រមព្រៀងនេះ តាមរបៀបណា។ គូភាគីត្រូវប្រព្រឹត្តដូចគ្នាចំពោះរាល់ព័ត៌មានសម្ងាត់ដែលបានផ្លាស់ប្តូរគ្នាក្នុងដំណើរការពិគ្រោះយោបល់ ដោយឈរលើមូលដ្ឋានដូចគ្នានឹងភាគីដែលផ្តល់ព័ត៌មាននោះផងដែរ។

៦. ការពិគ្រោះយោបល់ក្រោមមាត្រានេះ ត្រូវរក្សាជាការសម្ងាត់ និងដោយមិនត្រូវប៉ះពាល់ដល់សិទ្ធិនានារបស់ភាគីណាមួយក្នុងនីតិវិធីបណ្តឹងបន្តឡើយ។

## មាត្រា៨.៦៖ អន្តរការី ការផ្សះផ្សា និងសន្ធានកម្ម

១. អន្តរការី ការផ្សះផ្សា និងសន្ធានកម្ម គឺជានីតិវិធីបណ្តឹងដែលធ្វើឡើងដោយស្ម័គ្រចិត្ត ប្រសិនបើគូភាគីឯកភាពគ្នាដូច្នេះ។

២. អន្តរការី ការផ្សះផ្សា ឬសន្ធានកម្ម អាចត្រូវបានស្នើឡើងដោយភាគីណាមួយ នៅគ្រប់ពេលទាំងអស់។ នីតិវិធីបណ្តឹងទាំងនេះ អាចចាប់ផ្តើមនៅពេលណាក៏បាន តាមការព្រមព្រៀងគ្នារវាងគូភាគី ហើយអាចបញ្ចប់នៅគ្រប់ពេល តាមសំណើរបស់ភាគីណាមួយ។

៣. ប្រសិនបើគូភាគីឯកភាពគ្នា អន្តរការី ការផ្សះផ្សា ឬសន្ទានកម្ម អាចនៅបន្តដំណើរការ ក្នុងខណៈពេលដែលនីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ដូចមានចែងក្នុងជំពូកនេះ កំពុងដំណើរការនីតិវិធីផងដែរ។

៤. នីតិវិធីបណ្តឹងពាក់ព័ន្ធនឹងអន្តរការី ការផ្សះផ្សា ឬសន្ទានកម្ម និងជាពិសេសជំហរប្រកាន់យករបស់គូភាគី ក្នុងអំឡុងពេលនីតិវិធីបណ្តឹងទាំងនេះ ត្រូវរក្សាជាការសម្ងាត់ និងមិនត្រូវប៉ះពាល់ដល់សិទ្ធិនានារបស់ភាគីណាមួយ នៅក្នុងនីតិវិធីបណ្តឹងបន្តបន្ទាប់ឡើយ។

**មាត្រា៨.៧៖ ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម**

១. ភាគីប្តឹងតវ៉ាដែលបានស្នើសុំការពិគ្រោះយោបល់ក្រោមមាត្រា៨.៥ អាចស្នើសុំបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ប្រសិនបើ៖

(ក) ភាគីរងបណ្តឹងមិនចូលរួមពិគ្រោះយោបល់ក្នុងរយៈពេល ៣០ថ្ងៃ ឬ១៥ថ្ងៃ ក្នុងករណីបន្ទាន់រួមបញ្ចូលទាំងករណីពាក់ព័ន្ធនឹងទំនិញងាយខូចគុណភាព គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើសុំការពិគ្រោះយោបល់នោះ ឬ

(ខ) គូភាគីមិនអាចដោះស្រាយវិវាទតាមរយៈការពិគ្រោះយោបល់បាន ក្នុងរយៈពេល ៦០ថ្ងៃ ឬ៣០ថ្ងៃ ក្នុងករណីបន្ទាន់រួមបញ្ចូលទាំងករណីពាក់ព័ន្ធនឹងទំនិញងាយខូចគុណភាព គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើសុំការពិគ្រោះយោបល់នោះ។

២. សំណើសុំបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅភាគីរងបណ្តឹង។ នៅក្នុងសំណើនោះ ភាគីប្តឹងតវ៉ា ត្រូវកំណត់អំពីវិធានការជាក់លាក់ដែលចោទជាបញ្ហា និងមូលដ្ឋានអង្គហេតុ និងមូលដ្ឋានច្បាប់សម្រាប់ពាក្យបណ្តឹង ឱ្យបានគ្រប់គ្រាន់ដើម្បីធ្វើការបង្ហាញអំពីបញ្ហានោះបានច្បាស់លាស់។

**មាត្រា៨.៨៖ លក្ខខណ្ឌយោងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម**

លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះក្នុងអំឡុងពេល ២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើសុំបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម លក្ខខណ្ឌយោងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មត្រូវ៖

"ដោយពិចារណាលើបទប្បញ្ញត្តិពាក់ព័ន្ធនានានៃកិច្ចព្រមព្រៀងនេះ ពិនិត្យលើរឿងក្តីដូចមានក្នុងសំណើសុំបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ដូចមានចែងក្នុងមាត្រា៨.៧ចេញលទ្ធផលរកឃើញ ចេញសេចក្តីសម្រេច និងផ្តល់អនុសាសន៍នានាប្រសិនបើមាន និងធ្វើការបង្ហាញអំពីរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងមាត្រា៨.១២ និងមាត្រា៨.១៣។"

**មាត្រា៨.៩៖ សមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម**

១. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មត្រូវមានសមាសភាពមជ្ឈត្តករចំនួន ៣រូប។

២. ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើសុំបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ភាគីប្តឹងតវ៉ា និងភាគីរងបណ្តឹង ត្រូវតែងតាំងមជ្ឈត្តករម្នាក់ៗចំនួន ១រូប ដែលអាចជាជនជាតិរបស់ខ្លួន និងត្រូវស្នើឡើងនូវបេក្ខជនចំនួន ៣រូប សម្រាប់ការតែងតាំងជាមជ្ឈត្តករទីបី ដែលត្រូវដើរតួនាទីជាប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម។ បេក្ខជនសម្រាប់តួនាទី

ជាមជ្ឈត្តករទីបីទាំងនេះ មិនត្រូវជាជនជាតិនៃភាគីណាមួយ មានទីកន្លែងនៃនិវេសនដ្ឋានក្នុងភាគីណាមួយ ត្រូវបានជួលដោយភាគីណាមួយ និងធ្លាប់បានចូលរួមដោះស្រាយ វិវាទនេះឡើយ ទោះក្នុងតួនាទីជាអ្វីក៏ដោយ។

៣. គូភាគី ត្រូវខិតខំប្រឹងប្រែងឯកភាពគ្នា និងតែងតាំងមជ្ឈត្តករទីបី ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីការតែងតាំងមជ្ឈត្តករទី២ ដូចមានចែងក្នុងកថាខណ្ឌ២ ដោយពិចារណាលើបេក្ខជនដែលបានស្នើឡើង។ ប្រសិនបើគូភាគី មិនអាចឯកភាពគ្នា និងតែងតាំងមជ្ឈត្តករទីបី ក្នុងរយៈពេលខាងលើបានទេនោះ គូភាគីត្រូវប្រជុំគ្នាក្នុងរយៈពេល ៧ថ្ងៃបន្ទាប់ ហើយជ្រើសរើសប្រធានដោយការចាប់ឆ្នោតពីបញ្ជីបេក្ខជន ដែលបានស្នើឡើងដោយភាគីទាំងពីរ។

៤. កាលបរិច្ឆេទនៃការបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវជាកាលបរិច្ឆេទដែល មជ្ឈត្តករទីបី ត្រូវបានតែងតាំង។

៥. មជ្ឈត្តករទាំងអស់ ត្រូវមានជំនាញឬបទពិសោធន៍ផ្នែកច្បាប់ ពាណិជ្ជកម្មអន្តរជាតិ ឬផ្នែកផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ ឬក្នុងការដោះស្រាយវិវាទដែលកើតចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ។ មជ្ឈត្តករនីមួយៗត្រូវតែមានឯករាជ្យភាព បំពេញភារកិច្ចក្នុងតួនាទីរបស់ខ្លួន និងមិនជាប់ពាក់ព័ន្ធជាមួយ ឬទទួលសេចក្ដីបង្គាប់ពីភាគីណាមួយ ឬស្ថាប័នពាក់ព័ន្ធក្នុងវិវាទ និងត្រូវអនុលោមតាមឧបសម្ព័ន្ធ៨-ខ។

៦. នៅពេលភាគីណាមួយពិចារណាថា មជ្ឈត្តករណាមួយមិនអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងឧបសម្ព័ន្ធ៨-ខ គូភាគីត្រូវធ្វើការពិគ្រោះយោបល់ និងធ្វើការជំនួសមជ្ឈត្តកររូបនោះ ដោយអនុលោមតាមកថាខណ្ឌ៧ ប្រសិនបើមានការឯកភាពគ្នាបែបនោះ។

៧. ប្រសិនបើមជ្ឈត្តករដែលត្រូវបានតែងតាំងក្រោមមាត្រានេះ លាលែង ឬក្លាយជាអសមត្ថភាពក្នុងការចូលរួមក្នុងនីតិវិធីបណ្ដឹង ឬត្រូវបានជំនួស ដូចមានចែងក្នុងកថាខណ្ឌ៦ បុគ្គលស្នងតំណែងបន្តត្រូវជ្រើសតាំងក្នុងរយៈពេល ១៥ថ្ងៃ ដោយអនុលោមតាមវិធីសាស្ត្រតែងតាំងដូចមានចែងកថាខណ្ឌ ២ និង ៣ *ត្រូវយកមកអនុវត្តដូចគ្នា*។ បុគ្គលស្នងតំណែងបន្ត ត្រូវមានសិទ្ធិអំណាច និងភារកិច្ចទាំងអស់ដូចមជ្ឈត្តករដើមផងដែរ។ កិច្ចការរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មត្រូវពន្យារក្នុងរយៈពេលមួយដែលចាប់ផ្ដើមពីកាលបរិច្ឆេទដែលមជ្ឈត្តករបានលាលែង ឬក្លាយជាអសមត្ថភាពក្នុងការចូលរួមក្នុងនីតិវិធីបណ្ដឹង ឬត្រូវបានជំនួសដូចមានចែងក្នុងកថាខណ្ឌ៦។ កិច្ចការរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មនេះ ត្រូវដំណើរការជាធម្មតាវិញនៅកាលបរិច្ឆេទដែលបុគ្គលស្នងតំណែងបន្តត្រូវបានតែងតាំង។

## មាត្រា៨.១០៖ នីតិវិធីបណ្ដឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម

១. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវជួបប្រជុំគ្នាក្នុងកិច្ចប្រជុំសម្ងាត់។ គូភាគីត្រូវមានវត្តមាននៅក្នុងកិច្ចប្រជុំ នៅពេលត្រូវបានអញ្ជើញដោយក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មឱ្យមកបង្ហាញខ្លួនចំពោះក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មតែប៉ុណ្ណោះ។

២. គូភាគីត្រូវទទួលបានឱកាសដាក់សារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនយ៉ាងហោចណាស់ចំនួន ១ដង និងចូលរួមក្នុងបទបង្ហាញ សេចក្ដីថ្លែងការណ៍ ឬសេចក្ដីសន្និដ្ឋានតបនានាក្នុងនីតិវិធីបណ្ដឹង។ រាល់ព័ត៌មានដែលបានផ្ដល់ឱ្យ ឬសារណាជាលាយលក្ខណ៍អក្សរដែលដាក់ដោយភាគីណាមួយ ជូនក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម រួមបញ្ចូលទាំងមតិយោបល់នានាលើ

របាយការណ៍បណ្ដោះអាសន្ន និងការឆ្លើយតបទៅសំណួរនានាសួរដោយក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវផ្សព្វផ្សាយដើម្បីឱ្យភាគីម្ខាងទៀតទទួលបាន។

៣. ភាគីម្ខាងដែលបានអះអាងថាវិធានការរបស់ភាគីម្ខាងទៀតមានអសង្គតិភាពជាមួយកិច្ចព្រមព្រៀងនេះ ត្រូវទទួលខុសត្រូវចង្អុលបង្ហាញឱ្យឃើញអំពីអសង្គតិភាពនោះ។ ភាគីម្ខាងដែលបានអះអាងថាវិធានការណាមួយជាកម្មវត្ថុនៃការលើកលែងក្រោមកិច្ចព្រមព្រៀងនេះត្រូវទទួលខុសត្រូវចង្អុលបង្ហាញថាការលើកលែងនោះត្រូវអនុវត្តចំពោះវិធានការនោះ។

៤. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មត្រូវពិគ្រោះយោបល់ជាមួយគូភាគី តាមការសមស្រប និងផ្ដល់ឱ្យនូវឱកាសគ្រប់គ្រាន់សម្រាប់បង្កើតនូវដំណោះស្រាយដែលមានការពេញចិត្តទាំងសងខាង។

៥. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវបកស្រាយកិច្ចព្រមព្រៀងនេះដោយអនុលោមតាមវិធានទំនៀមទំលាប់នៃការបកស្រាយនៃច្បាប់អន្តរជាតិសាធារណៈ រួមបញ្ចូលទាំង *អនុសញ្ញាទីក្រុងវីយែន ស្ដីពីច្បាប់សន្ធិសញ្ញា*។

៦. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវធ្វើការសម្រេចចិត្តនានា រួមបញ្ចូលទាំងរបាយការណ៍របស់ខ្លួន ដោយមតិកុងសង់ស៊ីស ហើយក្នុងករណីដែលក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មមិនអាចឈានដល់មតិកុងសង់ស៊ីសទេ ការសម្រេចចិត្តនោះអាចធ្វើឡើងដោយការបោះឆ្នោតតាមមតិភាគច្រើន។

៧. តបតាមការស្នើសុំរបស់ភាគីម្ខាង ឬដោយគំនិតផ្ដួចផ្ដើមផ្ទាល់ដោយក្រុមប្រឹក្សាក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម អាចស្នើសុំព័ត៌មានពីប្រភពពាក់ព័ន្ធ និងអាចពិគ្រោះយោបល់ជាមួយជំនាញការដើម្បីទទួលបានមតិ ឬការណែនាំបច្ចេកទេស លើទិដ្ឋភាពជាក់លាក់មួយចំនួននៃបញ្ហានោះ។ មុនពេលធ្វើដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវស្នើសុំមតិពីគូភាគីជាមុនសិនដោយមិនប៉ះពាល់ដល់សិទ្ធិក្នុងការស្នើសុំព័ត៌មានរបស់ខ្លួន។ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវផ្ដល់ឱ្យគូភាគីនូវច្បាប់ចម្លងនៃការណែនាំ ឬមតិនានាដែលទទួលបាន ក៏ដូចជាឱកាសក្នុងការផ្ដល់មតិយោបល់ផងដែរ។

៨. កិច្ចពិភាក្សាដេញដោលនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម និងឯកសារដែលផ្ដល់ជូន ត្រូវរក្សាជាការសម្ងាត់។

៩. ទោះបីជាមានការចែងដូចក្នុងកថាខណ្ឌ៨ ក៏ដោយ ភាគីណាមួយអាចផ្សព្វផ្សាយជាសាធារណៈនូវសេចក្ដីថ្លែងការណ៍អំពីមតិរបស់ខ្លួនពាក់ព័ន្ធនឹងវិវាទនោះ ប៉ុន្តែត្រូវរក្សាជាការសម្ងាត់នូវរាល់ព័ត៌មាន និងសារណាជាលាយលក្ខណ៍អក្សរដែលផ្ដល់ឱ្យដោយភាគីម្ខាងទៀតជូនក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ដែលភាគីម្ខាងទៀតនោះបានកំណត់ជាព័ត៌មានសម្ងាត់។ នៅពេលភាគីម្ខាងបានផ្ដល់ព័ត៌មាន ឬសារណាជាលាយលក្ខណ៍អក្សរដែលបានកំណត់ជាព័ត៌មានសម្ងាត់ ភាគីម្ខាងនោះត្រូវផ្ដល់ជូននូវសេចក្ដីសង្ខេបនៃព័ត៌មានមិនមែនជាការសម្ងាត់ ឬសារណាជាលាយលក្ខណ៍អក្សរដែលអាចត្រូវបានលាតត្រដាងជូនសាធារណៈ ក្នុងរយៈពេល ២០ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃសំណើរបស់ភាគីម្ខាងទៀត។

១០. របាយការណ៍នៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវព្រាងឡើងដោយមិនមានវត្តមានរបស់គូភាគី។ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវរៀបចំរបាយការណ៍ដោយផ្អែកជាមូលដ្ឋានលើបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ព្រមទាំងសារណា និងការទាញហេតុផលរបស់គូភាគី

ផងដែរ ហើយអាចពិចារណាលើព័ត៌មានពាក់ព័ន្ធដទៃទៀត ដែលបានផ្តល់ជូនក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម។

១១. របាយការណ៍នៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវមានទាំងផ្នែកពណ៌នាដែលសង្ខេបនូវសារណា ឬការទាញហេតុផលរបស់គូភាគី និងទាំងលទ្ធផលរកឃើញ និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម។ ប្រសិនបើគូភាគីឯកភាពគ្នា ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មអាចផ្តល់អនុសាសន៍សម្រាប់ដំណោះស្រាយវិវាទនៅក្នុងរបាយការណ៍របស់ខ្លួន។ លទ្ធផលរកឃើញ និងសេចក្តីសម្រេច ព្រមទាំងអនុសាសន៍នានានៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ប្រសិនបើមាន មិនអាចបន្ថែម ឬបន្ថយនូវសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះឡើយ។

១២. ទីកន្លែងដំណើរការនីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវសម្រេចដោយការព្រមព្រៀងគ្នាទៅវិញទៅមករវាងគូភាគី។ ប្រសិនបើគ្មានការព្រមព្រៀងគ្នានោះទេ ទីកន្លែងដំណើរការនីតិវិធីបណ្តឹងត្រូវឆ្លាស់គ្នារវាងរាជធានីនៃគូភាគី ដោយកិច្ចប្រជុំនីតិវិធីបណ្តឹងលើកទី១ នៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវធ្វើឡើងក្នុងរាជធានីនៃភាគីរងបណ្តឹង។

## មាត្រា៨.១១៖ ការព្យួរ ឬការបញ្ចប់នៃនីតិវិធីបណ្តឹង

១. នៅពេលគូភាគីឯកភាពគ្នា ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មអាចព្យួរការងាររបស់ខ្លួននៅពេលណាក៏បានសម្រាប់រយៈពេលមិនលើសពី ១២ខែ គិតចាប់ពីកាលបរិច្ឆេទនៃការព្រមព្រៀងគ្នានោះ។ តបតាមការស្នើសុំរបស់ភាគីម្ខាង នីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មត្រូវដំណើរការជាធម្មតាវិញបន្ទាប់ពីការព្យួរការងារនេះ។ ក្នុងករណីការព្យួរការងារនេះ រយៈពេលកំណត់ពាក់ព័ន្ធនឹងការងាររបស់ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវបន្ថែមដោយចំនួននៃរយៈពេលដែលការងារត្រូវបានព្យួរ។ ប្រសិនបើការងារនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មនោះត្រូវបានបន្តព្យួរលើសពី ១២ខែ សិទ្ធិអំណាចនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវផុតរលត់ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ។

២. គូភាគីអាចព្រមព្រៀងគ្នាបញ្ចប់នីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មបាន ដោយរួមគ្នាធ្វើសេចក្តីផ្តល់ព័ត៌មានទៅកាន់ប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម នៅពេលណាក៏ដោយមុនពេលការចេញរបាយការណ៍ស្ថាពរទៅកាន់គូភាគី។

៣. មុនពេលដែលក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មអនុម័តសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងដំណាក់កាលនីតិវិធីបណ្តឹងណាក៏ដោយ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម អាចស្នើទៅកាន់គូភាគីឱ្យដោះស្រាយវិវាទដោយមិត្តភាព។

## មាត្រា៨.១២៖ របាយការណ៍បណ្តោះអាសន្ន

១. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ក្នុងរយៈពេល ៩០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវចេញរបាយការណ៍បណ្តោះអាសន្នជូនគូភាគី ដោយមានផ្នែកពណ៌នា លទ្ធផលរកឃើញ និងសេចក្តីសម្រេចព្រមទាំងអនុសាសន៍នានាផងដែរ ប្រសិនបើមាន ដោយបញ្ជាក់អំពី៖

(ក) ថាតើវិធានការដែលចោទជាបញ្ហានោះ មិនមានសង្គតិភាពជាមួយកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ឬទេ ឬ
(ខ) ថាតើភាគីណាមួយបានខកខានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ឬទេ

ក៏ដូចជាភាពដែលអាចអនុវត្តបាននៃបទប្បញ្ញត្តិពាក់ព័ន្ធនានា និងសំអាងហេតុជាមូលដ្ឋានសម្រាប់រាល់លទ្ធផលរកឃើញ។

២. នៅពេលក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មពិចារណាថា កាលបរិច្ឆេទកំណត់សម្រាប់របាយការណ៍បណ្ដោះអាសន្នបានផុតកំណត់ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មអាចបន្តរយៈពេលនេះបាន ដោយមានការយល់ព្រមពីគូភាគីតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីហេតុផលសម្រាប់ការពន្យារពេល និងកាលបរិច្ឆេទក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មគ្រោងចេញរបាយការណ៍បណ្ដោះអាសន្នរបស់ខ្លួន។ មិនមានកាលៈទេសៈណាមួយ ត្រូវចេញរបាយការណ៍បណ្ដោះអាសន្នមិនលើសពីរយៈពេល ១២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មនោះទេ។

៣. ភាគីណាមួយក៏បាន អាចដាក់មតិយោបល់ជាលាយលក្ខណ៍អក្សរលើរបាយការណ៍បណ្ដោះអាសន្នជូនក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មបានក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីការចេញរបាយការណ៍នោះ។ បន្ទាប់ពីបានពិចារណាលើមតិយោបល់ជាលាយលក្ខណ៍អក្សរដែលគូភាគីបានលើកឡើងលើរបាយការណ៍បណ្ដោះអាសន្ននោះរួច ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម អាចធ្វើការកែសម្រួលរបាយការណ៍នោះបាន ហើយធ្វើការពិនិត្យបន្ថែមលើចំណុចដែលខ្លួនពិចារណាថាសមស្រប។

**មាត្រា៨.១៣៖ របាយការណ៍ស្ថាពរ**

១. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវចេញរបាយការណ៍ស្ថាពររបស់ខ្លួនជូនគូភាគី ក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍បណ្ដោះអាសន្ន។

២. នៅពេលក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មពិចារណាថា កាលបរិច្ឆេទកំណត់សម្រាប់របាយការណ៍ស្ថាពរបានផុតកំណត់ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មអាចបន្តរយៈពេលនេះបាន ដោយមានការយល់ព្រមពីគូភាគីតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីហេតុផលសម្រាប់ការពន្យារពេល និងកាលបរិច្ឆេទដែលក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មគ្រោងចេញរបាយការណ៍ស្ថាពររបស់ខ្លួន។ មិនមានកាលៈទេសៈណាមួយ ត្រូវចេញរបាយការណ៍ស្ថាពរមិនលើសពីរយៈពេល ១៥០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មនេះនោះទេ។

៣. ក្នុងករណីបន្ទាន់ រួមបញ្ចូលទាំងករណីពាក់ព័ន្ធនឹងទំនិញងាយខូចគុណភាព ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវព្យាយាមចេញរបាយការណ៍បណ្ដោះអាសន្ន និងរបាយការណ៍ស្ថាពររបស់ខ្លួនក្នុងរយៈពេលពាក់កណ្ដាល នៃរយៈពេលកំណត់នីមួយៗ ដូចមានចែងក្រោមមាត្រា៨.១២.១ និងមាត្រា៨.១៣.១។

## មាត្រា៨.១៤៖ ការអនុវត្តរបាយការណ៍ស្ថាពរ

១. សេចក្តីសម្រេចនៃរបាយការណ៍ស្ថាពររបស់ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវបានចូលជាស្ថាពរ និងចងកាតព្វកិច្ចចំពោះគូភាគី។

២. ក្នុងរបាយការណ៍ស្ថាពរ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មសម្រេចថាភាគីរងបណ្តឹងមិនបានអនុលោមតាមកាតព្វកិច្ចរបស់ខ្លួនក្រោមបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនេះ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ភាគីរងបណ្តឹងត្រូវលុបនូវការមិនមានអនុលោមភាពភ្លាមៗ ឬប្រសិនបើមិនអាចអនុវត្តបាន ក្នុងរយៈពេលសមស្របណាមួយ។

៣. រយៈពេលសមស្របដូចមានចែងក្នុងកថាខណ្ឌ២ខាងលើ ត្រូវឯកភាពគ្នាទៅវិញទៅមកដោយគូភាគី។ នៅពេលគូភាគី មិនអាចព្រមព្រៀងគ្នាលើរយៈពេលសមស្របនេះក្នុង រយៈពេល៤៥ថ្ងៃគិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍ស្ថាពរនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ភាគីណាមួយអាចបង្វែរបញ្ហានេះទៅក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មដើម ដែលជាអ្នកត្រូវសម្រេចអំពីរយៈពេលសមស្របនោះ។

៤. ភាគីរងបណ្តឹងត្រូវផ្តល់ព័ត៌មានទៅកាន់ភាគីប្តឹងតវ៉ាអំពីវិធានការដែលខ្លួនបានអនុវត្ត ដើម្បីឱ្យអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម មុនពេលផុតកំណត់រយៈពេលសមស្របដែលឯកភាពគ្នាដោយគូភាគី ឬកំណត់ដោយក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មដើម ដូចមានចែងក្នុងកថាខណ្ឌ៣ ខាងលើ។ នៅពេលមិនមានការព្រមព្រៀងគ្នារវាងគូភាគី អំពីថាតើភាគីរងបណ្តឹងបានលុបការមិនមានអនុលោមភាព ដូចបានកំណត់ក្នុងរបាយការណ៍ស្ថាពរនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ក្នុងរយៈពេលសមស្របដូចបានកំណត់ក្នុងកថាខណ្ឌ៣ខាងលើ ភាគីណាមួយអាចបង្វែរបញ្ហានេះទៅក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មដើម។

## មាត្រា៨.១៥៖ ការមិនអនុវត្ត សំណង និងការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងៗ

១. ប្រសិនបើភាគីរងបណ្តឹង មិនអាចផ្តល់ព័ត៌មានអំពីការអនុវត្តវិធានការសម្រាប់ការអនុវត្តនៅមុនពេលផុតកំណត់រយៈពេលសមស្រប ឬផ្តល់ព័ត៌មានជូនភាគីប្តឹងតវ៉ា ថាការអនុវត្តនេះមិនអាចធ្វើទៅបាន ឬប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មដែលបញ្ហាត្រូវបានបង្វែរមក ដូចមានចែងក្នុងមាត្រា៨.១៤.៤ សម្រេចថាភាគីរងបណ្តឹងបានខកខាន ក្នុងការលុបការមិនមានអនុលោមភាពក្នុងរយៈពេលសមស្រប ភាគីរងបណ្តឹងត្រូវចូលរួមការចរចាជាមួយភាគីប្តឹងតវ៉ា ក្នុងគោលបំណងសម្រេចបានសំណងដែលមានការពេញចិត្តទាំងសងខាង ប្រសិនបើត្រូវបានស្នើសុំឱ្យអនុវត្តដូច្នេះ។

២. ប្រសិនបើមិនមានការព្រមព្រៀងគ្នាអំពីសំណង ដែលមានការពេញចិត្តទាំងសងខាង ក្នុងអំឡុងពេល ២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើដូចបានលើកឡើងក្នុងកថាខណ្ឌ១ នៅពេលណាក៏ដោយបន្ទាប់ពីនេះ ភាគីប្តឹងតវ៉ាអាចធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ភាគីរងបណ្តឹង ថាខ្លួនមានបំណងព្យួរការអនុវត្តនូវសម្បទាន ឬកាតព្វកិច្ចផ្សេងៗក្រោមកិច្ចព្រមព្រៀងនេះ ចំពោះភាគីរងបណ្តឹងបាន។ ភាគីប្តឹងតវ៉ាត្រូវមានសិទ្ធិចាប់ផ្តើមការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងៗ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានធ្វើការជូនដំណឹងអំពីការព្យួរនេះ។ សេចក្តីជូនដំណឹងនេះ ត្រូវចង្អុលបង្ហាញអំពីកម្រិត និងវិសាលភាពនៃការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងៗនោះ។

៣. ទោះបីជាមានការចែងដូចក្នុងកថាខណ្ឌ២ ខាងលើក៏ដោយ ភាគីប្ដឹងតវ៉ាមិនត្រូវអនុវត្តសិទ្ធិក្នុងការចាប់ផ្ដើមព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងៗក្រោមមាត្រា២ នៅពេលៈ

(ក) ការត្រួតពិនិត្យកំពុងត្រូវបានធ្វើឡើងដូចមានចែងក្នុងកថាខណ្ឌ៦ ខាងក្រោម ឬ

(ខ) សម្រេចបាននូវដំណោះស្រាយដែលឯកភាពគ្នាទាំងសងខាង។

ដើម្បីឱ្យកាន់តែច្បាស់ថែមទៀត ភាគីតវ៉ាមិនអាចព្យួរការអនុវត្តសម្បទាន ឬកាតព្វកិច្ចផ្សេងនៅមុនពេលការចេញសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ដូចមានចែងក្នុងមាត្រានេះឡើយ។

៤. សំណងដែលមានចែងក្នុងកថាខណ្ឌ១ និងការព្យួរដែលមានចែងក្នុងកថាខណ្ឌ២ខាងលើ ត្រូវជាវិធានការបណ្ដោះអាសន្ន។ ទាំងសំណង ទាំងការព្យួរ មិនមែនជាជម្រើសដែលចង់បានជាជាងការលុបបំបាត់ទាំងស្រុងនូវការមិនមានអនុលោមភាព ដូចបានកំណត់ក្នុងរបាយការណ៍នៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មនោះទេ។ ការព្យួរនេះត្រូវយកមកអនុវត្តរហូតដល់ពេលវេលាដែលការមិនមានអនុលោមភាពត្រូវបានលុបបំបាត់ទាំងស្រុង ឬដំណោះស្រាយមួយដែលអាចទទួលយកបានដោយពេញចិត្តទាំងសងខាង។

៥. ក្នុងការពិចារណាថាតើសម្បទាន ឬកាតព្វកិច្ចផ្សេងៗណាដែលត្រូវព្យួរ ស្របតាមកថាខណ្ឌ២ខាងលើៈ

(ក) ភាគីប្ដឹងតវ៉ាគួរតែស្នើសុំព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងៗក្នុងវិស័យដូចគ្នា មួយ ឬច្រើនជាមុនសិន ដែលក្នុងនោះរបាយការណ៍នៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ដូចមានចែងក្នុងមាត្រា៨.១៣ បានរកឃើញថាខកខានពុំបានបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ

(ខ) ប្រសិនបើភាគីតវ៉ាពិចារណាថាមិនអាចអនុវត្តបាន ឬមិនមានស័ក្តិសិទ្ធិភាពក្នុងការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងៗក្នុងវិស័យដូចគ្នា មួយ ឬច្រើនទេនោះ ភាគីប្ដឹងតវ៉ានោះអាចព្យួរសម្បទាន ឬកាតព្វកិច្ចក្នុងវិស័យផ្សេងទៀតបាន។ សេចក្ដីជូនដំណឹង អំពីការព្យួរដូចមានចែងក្នុងកថាខណ្ឌ២ ខាងលើ ត្រូវចង្អុលបង្ហាញអំពីសំអាងហេតុដែលការព្យួរនេះដែលជាមូលដ្ឋាននៃការសម្រេចចិត្ត និង

(គ) កម្រិតនៃការព្យួរដែលសំដៅដល់ក្នុងកថាខណ្ឌ២ ខាងលើ ត្រូវសមមូលទៅនឹងកម្រិតនៃមោឃៈកម្ម ឬការខូចខាត។

៦. ប្រសិនបើភាគីរងបណ្ដឹងពិចារណាថា លក្ខខណ្ឌតម្រូវនានាសម្រាប់ការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងៗដោយភាគីប្ដឹងតវ៉ា ដូចមានចែងក្នុងកថាខណ្ឌ២, ៣ ឬ ៥ ខាងលើមិនត្រូវបានបំពេញ ភាគីរងបណ្ដឹងនេះអាចបង្វែរបញ្ហានេះទៅក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មបាន។

៧. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនៃមាត្រានេះ ឬមាត្រា៨.១៤ តាមដែលអាចធ្វើទៅបាន ត្រូវមានមជ្ឈត្តករនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មដើម ជាមជ្ឈត្តកររបស់ខ្លួន។ ប្រសិនបើមិនអាចធ្វើទៅបានទេ នោះមជ្ឈត្តករនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មដែលត្រូវបានបង្កើតសម្រាប់គោលបំណងនៃមាត្រានេះ ឬមាត្រា៨.១៤ ត្រូវតែងតាំងដូចមានចែងក្នុងមាត្រា៨.៩។ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មដែលត្រូវបានបង្កើត

ឡើងក្រោមមាត្រានេះ ឬមាត្រា៨.១៤ ត្រូវចេញរបាយការណ៍ទៅគូភាគីក្នុងរយៈពេល ២០ថ្ងៃ អំពីរយៈពេលសមស្រប និងក្នុងរយៈពេល ៤៥ថ្ងៃ អំពីបញ្ហាផ្សេងៗ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដែលបញ្ហាទាំងនោះត្រូវបានបង្វែរមកក្រុមប្រឹក្សានោះ។ នៅពេលក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មនេះ ពិចារណាថាមិនអាចចេញរបាយការណ៍ក្នុងរយៈពេលដូចបានលើកឡើងខាងដើមបានទេនោះ រយៈពេលពាក់ព័ន្ធអាចបន្តដោយក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មចំនួន ៣០ថ្ងៃ បន្ថែមជាអតិបរមាបាន ដោយមានការយល់ព្រមពីគូភាគី។ របាយការណ៍នេះ ត្រូវចងកាតព្វកិច្ចចំពោះគូភាគី។

**មាត្រា៨.១៦៖ វិធាននីតិវិធី**

១. នីតិវិធីបណ្តឹងនៃការដោះស្រាយវិវាទក្រោមជំពូកនេះ ត្រូវគ្រប់គ្រងដោយវិធាននីតិវិធីដូចមានចែងក្នុងឧបសម្ព័ន្ធ៨-ក។ ដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម គូភាគីអាចឯកភាពគ្នាក្នុងការអនុម័តវិធាននីតិវិធីបន្ថែម ដែលមិនមានអសង្គតិភាពជាមួយបទប្បញ្ញត្តិនៃឧបសម្ព័ន្ធនេះបាន។

២. រយៈពេល ឬវិធាននីតិវិធីដទៃទៀតសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មដូចមានចែងក្នុងជំពូកនេះ និងក្នុងឧបសម្ព័ន្ធ៨-ក អាចធ្វើការកែសម្រួលបានដោយមានការយល់ព្រមទៅវិញទៅមក ពីគូភាគី។

**មាត្រា៨.១៧៖ ការចំណាយនានា**

១. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ភាគីនីមួយៗ ត្រូវទទួលបន្ទុកថ្លៃចំណាយសម្រាប់មជ្ឈត្តករដែលខ្លួនបានតែងតាំង និងការចំណាយផ្សេងៗរបស់ខ្លួន និងថ្លៃចំណាយផ្លូវច្បាប់ផងដែរ។

២. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ថ្លៃចំណាយសម្រាប់ប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម និងការចំណាយផ្សេងៗភ្ជាប់ជាមួយការដំណើរការនីតិវិធីបណ្តឹង ត្រូវទទួលបន្ទុកដោយគូភាគីក្នុងចំណែកស្មើៗគ្នា។

## ឧបសម្ព័ន្ធ៨-ក
## វិធាននីតិវិធីសម្រាប់មជ្ឈត្តកម្ម

### និយមន័យ

១. សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ៖

**ទីប្រឹក្សា** សំដៅដល់បុគ្គលដែលជួលដោយភាគីម្ខាងដើម្បីផ្តល់យោបល់ ឬជួយដល់ភាគីនោះពាក់ព័ន្ធនឹងនីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម

**ជំនួយការ** សំដៅដល់បុគ្គលដែលធ្វើការស្រាវជ្រាវ ឬផ្តល់ជំនួយដល់មជ្ឈត្តករណាមួយ ក្រោមលក្ខខណ្ឌនៃការតែងតាំងរបស់មជ្ឈត្តករនោះ និង

**អ្នកតំណាងឱ្យភាគីម្ខាង** សំដៅដល់បុគ្គលទាំងឡាយណាដែលត្រូវបានតែងតាំងដោយភាគីម្ខាង ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុករបស់ភាគីម្ខាងនោះ។

*ការចាត់ចែងឡជីស្ទីក*

២. ក្នុងករណីដែលនីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវបានធ្វើឡើងក្នុងទឹកដីនៃភាគីណាមួយ ភាគីនោះត្រូវទទួលបន្ទុកចាត់ចែងឡជីស្ទីកសម្រាប់នីតិវិធីបណ្តឹង មជ្ឈត្តកម្ម ជាពិសេសការរៀបចំសវនាការ លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ។

*ការជូនដំណឹង*

៣. សំណើ សេចក្តីជូនដំណឹង សារណាជាលាយលក្ខណ៍អក្សរ ឬឯកសារផ្សេងៗ ដែលបញ្ជូនឱ្យដោយភាគីម្ខាង ឬក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវបញ្ជូនមកនូវវិក័យបត្រ ប្រៃសណីយ៍ដែលបានចុះបញ្ជី អ្នកបញ្ជូនសំបុត្រ ការបញ្ជូនតាមប្រព័ន្ធហ្វាក់ ឬតាមទម្រង់ណាផ្សេងទៀតនៃប្រព័ន្ធទូរគមនាគមន៍ ដែលមានកំណត់ត្រានៃការផ្ញើចេញ។

៤. ភាគីម្ខាងត្រូវផ្តល់ឱ្យនូវច្បាប់ចម្លងសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅភាគីម្ខាងទៀត និងមជ្ឈត្តករនីមួយៗផងដែរ។ ច្បាប់ចម្លងនៃឯកសារនេះ ត្រូវផ្តល់ឱ្យក្នុងទម្រង់អេឡិចត្រូនិក។

៥. រាល់ការជូនដំណឹង ត្រូវធ្វើឡើង និងបញ្ជូនទៅក្រសួងពាណិជ្ជកម្មកម្ពុជា ឬស្ថាប័នបន្តវេនបន្ទាប់ និងទៅក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និងថាមពលកូរ៉េ ឬស្ថាប័នបន្តវេនបន្ទាប់ រៀងៗខ្លួន។

៦. កំហុសឆ្គងតូចតាចរបស់ការងារស្មៀនលើសំណើរ សេចក្តីជូនដំណឹង សារណាជាលាយលក្ខណ៍អក្សរ ឬឯកសារផ្សេងៗពាក់ព័ន្ធនឹងនីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម អាចធ្វើការកែតម្រូវបាន ដោយការបញ្ជូនឯកសារថ្មីជំនួស ដោយមានការបញ្ជាក់ច្បាស់ពី កំណែប្រែនោះ។

៧. ប្រសិនបើកាលបរិច្ឆេទចុងក្រោយសម្រាប់បញ្ជូន [1] ឯកសារឈានប៉ះចំថ្ងៃឈប់សម្រាកសាធារណៈនៃភាគីណាមួយ ឯកសារនោះអាចបញ្ជូននៅថ្ងៃធ្វើការបន្ទាប់បាន។

---

[1] ដើម្បីឱ្យកាន់តែច្បាស់ថែមទៀតសម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ កាលបរិច្ឆេទបញ្ជូនគឺជាកាលបរិច្ឆេទដែលឯកសារ ដែលបានបានបញ្ជូនមកដល់ទីកន្លែងតាមបំណង។

*សារណាលើកទី១*

៨. ភាគីប្តឹងតវ៉ា ត្រូវបញ្ជូនសារណាជាលាយលក្ខណ៍អក្សរលើកទី១របស់ខ្លួនក្នុងរយៈពេលមិនឱ្យលើសពី ២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មឡើយ។ ភាគីរងបណ្តឹងត្រូវបញ្ជូនសារណាតបជាលាយលក្ខណ៍អក្សររបស់ខ្លួន ក្នុងរយៈពេលមិនឱ្យលើសពី ២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានសារណាជាលាយលក្ខណ៍អក្សរលើកទី១ របស់ភាគីប្តឹងតវ៉ា។

*ប្រតិបត្តិការនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម*

៩. ប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវចូលរួមដឹកនាំគ្រប់កិច្ចប្រជុំទាំងអស់។ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម អាចធ្វើប្រតិភូកម្មជូនប្រធានក្រុមប្រឹក្សានូវសិទ្ធិអំណាចក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងនីតិវិធី និងកិច្ចការរដ្ឋបាលបាន។

១០. លើកលែងតែមានចែងផ្សេងពីនេះក្នុងជំពូកនេះ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មអាចធ្វើសកម្មភាពរបស់ខ្លួន គ្រប់មធ្យោបាយរួមបញ្ចូលទាំងតាមរយៈទូរស័ព្ទ ការបញ្ជូនតាមប្រព័ន្ធហ្វាក់ ឬតំណភ្ជាប់តាមរយៈប្រព័ន្ធកុំព្យូទ័រ។

១១. មានតែមជ្ឈត្តករប៉ុណ្ណោះ អាចចូលរួមក្នុងកិច្ចពិភាក្សាដេញដោលនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ប៉ុន្តែដោយមានការពិគ្រោះយោបល់ជាមួយគូភាគី ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មអាចអនុញ្ញាតឱ្យជំនួយការ អ្នកបកប្រែផ្ទាល់មាត់ ឬអ្នកបកប្រែអត្ថបទ មានវត្តមានក្នុងកិច្ចពិភាក្សាដេញដោលនេះបាន។ រាល់បុគ្គលដែលមានវត្តមានក្នុងកិច្ចពិភាក្សាដេញដោលនេះ ត្រូវរក្សាការសម្ងាត់នៃនីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម លើកលែងតែព័ត៌មាននោះត្រូវបានផ្សាយជាសាធារណៈរួចហើយ។

១២. ការព្រាងសេចក្តីសម្រេច និងការវិនិច្ឆ័យទាំងឡាយ ត្រូវជាកាតព្វកិច្ចផ្តាច់មុខរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម និងមិនអាចធ្វើប្រតិភូកម្មឡើយ។

១៣. នៅពេលមានសំណួរពាក់ព័ន្ធនឹងនីតិវិធីដែលមិនគ្របដណ្តប់ក្នុងជំពូកនេះ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មអាចអនុម័តនីតិវិធីសមស្របដែលមិនមានអសង្គតិភាពទៅនឹងជំពូកនេះបាន លើកលែងតែក្រុមប្រឹក្សានេះពិចារណាថាសំណួរពាក់ព័ន្ធនឹងនីតិវិធីអាចមានផលប៉ះពាល់ដល់ផ្នែកសំខាន់នៃវិធីសាស្ត្រដែលក្រុមប្រឹក្សានេះពិនិត្យមើលបញ្ហានៅចំពោះមុខ ហើយដែលក្នុងករណីនេះផងដែរ ក្រុមប្រឹក្សានេះត្រូវពិគ្រោះយោបល់ជាមួយគូភាគី។

១៤. ដោយមានការពិគ្រោះយោបល់ជាមួយគូភាគី ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មអាចកែសម្រួលរាល់ពេលកំណត់ដែលអនុវត្តបាន នៅក្នុងនីតិវិធីបណ្តឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ហើយធ្វើការកែសម្រួលផ្នែកនីតិវិធី ឬផ្នែករដ្ឋបាល ដូចដែលអាចនឹងត្រូវបានតម្រូវក្នុងនីតិវិធីបណ្តឹង។

១៥. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ការចំណាយនានានៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម រួមបញ្ចូលទាំងប្រាក់ឈ្នួលសម្រាប់មជ្ឈត្តករ ត្រូវទទួលបន្ទុកដោយគូភាគី ក្នុងចំណែកស្មើៗគ្នា។

*សវនាការ*

១៦. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មត្រូវបើកឱ្យមានសវនាការយ៉ាងហោចណាស់ចំនួនមួយដង សម្រាប់ឱ្យគូភាគីបង្ហាញរឿងក្តីរបស់ខ្លួន។ ប្រធានក្រុមប្រឹក្សា ត្រូវកំណត់កាលបរិច្ឆេទ និងពេលវេលានៃសវនាការ ដោយមានការពិគ្រោះយោបល់ជាមួយគូភាគី និងសមាជិកដទៃទៀតនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម។ ប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មត្រូវជូនដំណឹងទៅគូភាគីអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការជាលាយលក្ខណ៍អក្សរ។ ព័ត៌មានទាំងនេះ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈដោយភាគីទទួលបន្ទុកការចាត់ចែងឡជីស្ទីកនៃនីតិវិធីបណ្តឹង នៅពេលគូភាគីឯកភាពគ្នាអនុញ្ញាតឱ្យសវនាការបើកចំហរជាសាធារណៈ ដោយអនុលោមតាមកថាខណ្ឌ២១ នៃឧបសម្ព័ន្ធនេះ។

១៧. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម អាចបើកសវនាការបន្ថែមទៀតបាន ប្រសិនបើគូភាគីមានការឯកភាពគ្នាដូច្នេះ។

១៨. រាល់មជ្ឈត្តករទាំងអស់ត្រូវមានវត្តមានក្នុងអំឡុងពេលទាំងមូលនៃសវនាការណាមួយ។

១៩. អ្នកតំណាងភាគី ទីប្រឹក្សានៃភាគី អ្នកបកប្រែផ្ទាល់មាត់ អ្នកបកប្រែអត្ថបទ បុគ្គលិករដ្ឋបាលពាក់ព័ន្ធ អ្នករៀបចំរបាយការណ៍ជូនអង្គជំនុំជម្រះ និងជំនួយការនៃមជ្ឈត្តករ អាចចូលរួមសវនាការបាន មិនថាសវនការនោះបើកចំហរជាសាធារណៈ ឬជាការសម្ងាត់នោះទេ។ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម មានតែអ្នកតំណាង និងទីប្រឹក្សានៃភាគីម្ខាងតែប៉ុណ្ណោះ អាចថ្លែងទៅក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម។

២០. ក្នុងរយៈពេលមិនលើសពី ៥ថ្ងៃ មុនកាលបរិច្ឆេទនៃសវនាការ ភាគីនីមួយៗ ត្រូវបញ្ជូនទៅកាន់ក្រុមប្រឹក្សាជំនុំជម្រះនូវបញ្ជីឈ្មោះបុគ្គលដែលត្រូវធ្វើការទាញហេតុផលផ្ទាល់មាត់ ឬបទបង្ហាញនៅក្នុងសវនាការក្នុងនាមភាគីនោះ និងបញ្ជីឈ្មោះនៃអ្នកតំណាងទីប្រឹក្សា អ្នកបកប្រែផ្ទាល់មាត់ និងអ្នកបកប្រែអត្ថបទ នៃភាគីនោះដែលនឹងចូលរួមក្នុងសវនាការ។

២១. សវនាការនៃក្រុមប្រឹក្សាជំនុំជម្រះត្រូវធ្វើឡើងជាការសម្ងាត់។ សវនាការអាចបើកចំហរជាសាធារណៈនូវផ្នែកខ្លះ ឬទាំងស្រុងបាន នៅពេលមានការព្រមព្រៀងគ្នាដោយគូភាគី។

២២. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវបើកសវនាការដោយធានាថា ភាគីប្តឹងតវ៉ា និងភាគីរងបណ្តឹង ទទួលបានរយៈពេលស្មើៗគ្នា សម្រាប់៖

*ការទាញហេតុផល*

(ក) ការទាញហេតុផលរបស់ភាគីប្តឹងតវ៉ា និង

(ខ) ការទាញហេតុផលរបស់ភាគីរងបណ្តឹង។

*ការទាញហេតុផលនៃសេចក្តីសន្និដ្ឋានតប*

(ក) ការឆ្លើយតបនៃភាគីប្តឹងតវ៉ា និង

(ខ) ការឆ្លើយតបបកនៃភាគីរងបណ្តឹង។

២៣. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម អាចចោទជាសំណួរទៅកាន់ភាគីណាមួយនៅពេលណាក៏បានក្នុងសវនាការ។

២៤. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឍត្តកម្ម ត្រូវរៀបចំឱ្យមានអត្ថបទចម្លងជាលាយលក្ខណ៍អក្សរនៃសវនាការនីមួយៗ និងត្រូវបញ្ជូនច្បាប់ចម្លងនៃអត្ថបទចម្លងនេះទៅគូភាគី ឱ្យបានឆាប់តាមដែលអាចធ្វើទៅបានក្រោយពីរៀបចំរួច។

២៥. ក្នុងរយៈពេល ២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃសវនាការ ភាគីនីមួយៗ អាចបញ្ជូនសារណាជាលាយលក្ខណ៍អក្សរបំពេញបន្ថែម ដែលឆ្លើយតបទៅនឹងបញ្ហានានាដែលលើកឡើងក្នុងអំឡុងពេលសវនាការបាន។

*សំណួរជាលាយលក្ខណ៍អក្សរ*

២៦. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឍត្តកម្ម អាចចោទសួរជាលាយលក្ខណ៍អក្សរទៅកាន់ភាគីម្ខាង ឬភាគីទាំងពីរបាន នៅពេលណាក៏ដោយក្នុងអំឡុងពេលនៃនីតិវិធីបណ្ដឹង។ ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឍត្តកម្មត្រូវបញ្ជូនសំណួរជាលាយលក្ខណ៍អក្សរទៅកាន់ភាគីម្ខាងដែលត្រូវបានចោទសួរ ហើយត្រូវធ្វើច្បាប់ចម្លងនៃសំណួរនោះទៅកាន់ភាគីម្ខាងទៀត។

២៧. ភាគីម្ខាងដែលត្រូវបានក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឍត្តកម្មចោទសួរ ត្រូវបញ្ជូនច្បាប់ចម្លងនៃការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅកាន់ភាគីម្ខាងទៀត និងក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឍត្តកម្ម។ ភាគីនីមួយៗត្រូវបានផ្តល់ឱ្យនូវឱកាសគ្រប់គ្រាន់ក្នុងការផ្តល់មតិយោបល់ជាលាយលក្ខណ៍អក្សរលើការឆ្លើយតបនោះ ក្នុងរយៈពេល ៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានការឆ្លើយតបនោះ។

*ការសម្ងាត់*

២៨. នៅគ្រប់ពេលវេលា គូភាគី និងទីប្រឹក្សារបស់ខ្លួន ត្រូវរក្សាការសម្ងាត់នៃសវនាការនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឍត្តកម្ម នៅពេលណាដែលសវនាការនោះត្រូវបានធ្វើឡើងជាការសម្ងាត់។ ភាគីនីមួយៗ និងទីប្រឹក្សារបស់ខ្លួន ត្រូវចាត់ទុករាល់ព័ត៌មានផ្តល់ឱ្យដោយភាគីជូនក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឍត្តកម្ម ជាព័ត៌មានសម្ងាត់ នៅពេលដែលភាគីនោះបានកំណត់ជាព័ត៌មានសម្ងាត់។ នៅពេលភាគីម្ខាងដាក់ជូនក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឍត្តកម្មនូវសំណៅជាការសម្ងាត់នៃសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន ដោយតបតាមការស្នើសុំរបស់ភាគីម្ខាងទៀត ភាគីនោះត្រូវផ្តល់ជូននូវសេចក្តីសង្ខេបនៃព័ត៌មានមិនមែនជាការសម្ងាត់ដែលមានក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន ដែលអាចនឹងត្រូវបានលាតត្រដាងជូនសាធារណៈ ក្នុងរយៈពេលមិនឱ្យលើសពី ២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើ ឬនៃការដាក់ជូន រយៈពេលណាមួយដែលយូរជាងគេ។ ពុំមានបទប្បញ្ញត្តិណាមួយក្នុងកថាខណ្ឌនេះ ហាមឃាត់ភាគីម្ខាងពីការលាតត្រដាងសេចក្តីថ្លែងការណ៍នៃជំហររបស់ខ្លួនជាសាធារណៈឡើយ ដើម្បីធ្វើការបញ្ជាក់នៅពេលធ្វើការយោងទៅព័ត៌មានដែលដាក់ជូនដោយភាគីម្ខាងទៀត ភាគីនោះមិនលាតត្រដាងព័ត៌មានណាដែលបានកំណត់ដោយភាគីម្ខាងទៀតនោះថាជាព័ត៌មានសម្ងាត់នោះទេ។

*ការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង*

២៩. ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឍត្តកម្ម មិនត្រូវជួប ឬទំនាក់ទំនងភាគីម្ខាងដោយអវត្តមានភាគីម្ខាងទៀតឡើយ។ ភាគីនីមួយៗមិនត្រូវទំនាក់ទំនងជាមួយមជ្ឍត្តករពាក់ព័ន្ធនឹងវិវាទដោយអវត្តមានភាគីម្ខាងទៀត ឬមជ្ឍត្តករដទៃទៀតឡើយ។

៣០. មជ្ឈត្តករនីមួយៗមិនត្រូវពិភាក្សា អំពីទិដ្ឋភាពណាមួយនៃកម្មវត្ថុនីតិវិធីបណ្ដឹងជាមួយភាគីម្ខាង ឬភាគីទាំងពីរ ដោយអវត្តមានមជ្ឈត្តករដទៃទៀតឡើយ។

*ការបកប្រែផ្ទាល់មាត់ និងការបកប្រែអត្ថបទ*

៣១. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ ភាសាការងាររួមប្រើប្រាស់សម្រាប់នីតិវិធីបណ្ដឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវជាភាសាអង់គ្លេស។ ប្រសិនបើភាគីម្ខាងសម្រេចចិត្តប្រើប្រាស់ការបកប្រែក្នុងនីតិវិធីបណ្ដឹង ការរៀបចំនិងថ្លៃចំណាយ ត្រូវជាបន្ទុករបស់ភាគីនោះ។

៣២. រាល់ឯកសារដែលបានដាក់ជូនសម្រាប់ប្រើប្រាស់ក្នុងនីតិវិធីបណ្ដឹងដូចមានចែងក្នុងជំពូកនេះ ត្រូវធ្វើឡើងជាភាសាអង់គ្លេស។ ប្រសិនបើឯកសារដើមនោះមិនមែនជាភាសាអង់គ្លេសនោះទេ ភាគីដែលដាក់ជូននូវឯកសារនោះសម្រាប់ប្រើប្រាស់ក្នុងនីតិវិធីបណ្ដឹង ត្រូវផ្ដល់ជូនសេចក្ដីបកប្រែជាភាសាអង់គ្លេសនៃឯកសារទាំងនោះ។

*ការគណនាពេលវេលា*

៣៣. រាល់រយៈពេលដូចមានចែងក្នុងជំពូកនេះ ត្រូវរាប់ដោយគិតតាមថ្ងៃប្រតិទិន ដែលថ្ងៃទី១ ជាថ្ងៃចាប់ផ្ដើមបន្ទាប់ពីសកម្មភាព ឬហេតុការណ៍ដែលថ្ងៃនោះសំដៅលើ។

៣៤. ដោយមូលហេតុនៃប្រតិបត្តិការនៃកថាខណ្ឌ៧ នៅពេលភាគីម្ខាងទទួលបានឯកសារ ក្នុងកាលបរិច្ឆេទដែលមិនមែនជាកាលបរិច្ឆេទដែលឯកសារនេះបានទទួលដោយភាគីម្ខាងទៀត រយៈពេលនៃការគណនាផ្អែកលើការទទួលបាននូវឯកសារនោះ ត្រូវគណនាចាប់ពីកាលបរិច្ឆេទចុងក្រោយដែលទទួលបានឯកសារនោះ។

*នីតិវិធីបណ្ដឹងផ្សេងៗ*

៣៥. ដោយអនុលោមតាមមាត្រា៨.១៤.៣, ៨.១៤.៤, ៨.១៥.៦ និង៨.១៥.៧ ភាគីដែលបង្វែររឿងក្ដីត្រូវបញ្ជូនសារណាជាលាយលក្ខណ៍អក្សរលើកទី១ របស់ខ្លួនក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទការបង្វែរត្រូវបានធ្វើឡើង ហើយភាគីរងបណ្ដឹងនោះ ត្រូវបញ្ជូនសារណាតបជាលាយលក្ខណ៍អក្សររបស់ខ្លួនក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសារណាជាលាយលក្ខណ៍អក្សរលើកទី១ នោះផងដែរ។

៣៦. ប្រសិនបើសមស្រប ក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ត្រូវកំណត់រយៈពេលសម្រាប់បញ្ជូនរាល់សារណាជាលាយលក្ខណ៍អក្សរបន្ថែម រួមបញ្ចូលទាំងសារណាសន្និដ្ឋានតបជាលាយលក្ខណ៍អក្សរ ដើម្បីផ្ដល់ឱ្យភាគីនីមួយៗ នូវឱកាសរៀបចំសារណាជាលាយលក្ខណ៍អក្សរក្នុងចំនួនស្មើៗគ្នា ស្របតាមរយៈពេលនៃនីតិវិធីបណ្ដឹងនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ដូចមានចែងក្នុងមាត្រា៨.១៤ ៨.១៥ និងឧបសម្ព័ន្ធនេះ។

៣៧. លើកលែងតែមានចែងផ្សេងពីនេះ ឧបសម្ព័ន្ធនេះក៏ត្រូវយកមកអនុវត្តផងដែរចំពោះនីតិវិធីដែលបានបង្កើតឡើងក្នុងមាត្រា៨.១៤ និង៨.១៥។

៣៨. រយៈពេលសមស្របដូចបានបង្កើតឡើងក្នុងមាត្រា៨.១៤ និង៨.១៥ ជាធម្មតាមិនត្រូវលើសពីរយៈពេល ១៥ខែ គិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍ស្ថាពរនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្មឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ រយៈពេលសមស្របនេះ អាចមានរយៈពេលខ្លីជាង ឬវែងជាងនេះ អាស្រ័យលើកាលៈទេសៈជាក់ស្ដែង។

## ឧបសម្ព័ន្ធ៨-ខ
## ក្រមប្រតិបត្តិសម្រាប់មជ្ឈត្តករ

*និយមន័យ*

១. សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ៖

**ជំនួយការ** សំដៅដល់បុគ្គលដែលធ្វើការស្រាវជ្រាវ ឬផ្តល់ជំនួយដល់មជ្ឈត្តករណាមួយ ក្រោមលក្ខខណ្ឌនៃការតែងតាំងរបស់មជ្ឈត្តករនោះ និង

**បុគ្គលិក** ពាក់ព័ន្ធនឹងមជ្ឈត្តករ សំដៅដល់បុគ្គលក្រោមការចង្អុលបង្ហាញ និងការគ្រប់គ្រងរបស់មជ្ឈត្តករនោះ ក្រៅពីជំនួយការ។

*ទំនួលខុសត្រូវក្នុងដំណើរការ*

២. រាល់បេក្ខជន និងមជ្ឈត្តករ ត្រូវជៀសវាងការប្រព្រឹត្តមិនត្រឹមត្រូវ និងការស្តែងឡើងនូវការប្រព្រឹត្តមិនត្រឹមត្រូវ ត្រូវមានឯករាជ្យភាព និងមិនលម្អៀង ត្រូវជៀសវាងទំនាស់ផលប្រយោជន៍ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី និងត្រូវគោរពតាមបទដ្ឋានប្រតិបត្តិខ្ពស់ ដើម្បីរក្សាសុចរិតភាព និងភាពមិនលម្អៀងនៃនីតិវិធីដោះស្រាយវិវាទ។ អតីតមជ្ឈត្តករ ត្រូវតែអនុលោមតាមកាតព្វកិច្ច ដូចបានបង្កើតឡើងក្នុងកថាខណ្ឌ១៥ ដល់ ១៨។

*កាតព្វកិច្ចលាតត្រដាង*

៣. មុនពេលនៃការបញ្ជាក់អំពីការតែងតាំងជាមជ្ឈត្តកររបស់ខ្លួន ក្រោមមាត្រា៨.៩ បេក្ខជនត្រូវលាតត្រដាងទៅកាន់គូភាគី នូវព័ត៌មាននានាដែលអាចបណ្តាលឱ្យកើតមាននូវការសង្ស័យដែលមានមូលហេតុត្រឹមត្រូវ រួមបញ្ចូលទាំងផលប្រយោជន៍ ទំនាក់ទំនង ឬបញ្ហាដែលទំនងនឹងប៉ះពាល់ដល់ឯករាជ្យភាព ឬភាពមិនលម្អៀង ឬដែលអាចបង្កើតឱ្យមានការស្តែងឡើងនូវការប្រព្រឹត្តមិនត្រឹមត្រូវ ឬភាពលម្អៀងនៅក្នុងនីតិវិធីបណ្តឹងដោយហេតុផលណាមួយ។ ក្នុងន័យនេះ បេក្ខជនត្រូវព្យាយាមប្រឹងប្រែងតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យបានដឹងអំពីផលប្រយោជន៍ ទំនាក់ទំនង និងបញ្ហានានាដែលអាចកើតឡើងទាំងនេះ។

៤. នៅពេលត្រូវបានតែងតាំង មជ្ឈត្តករ ត្រូវបន្តព្យាយាមប្រឹងប្រែងតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យបានដឹងអំពីផលប្រយោជន៍ ទំនាក់ទំនង ឬបញ្ហានានាដែលអាចកើតឡើង ដូចបានលើកឡើងក្នុងកថាខណ្ឌ៣ ខាងលើ ហើយត្រូវលាតត្រដាងនូវបញ្ហាទាំងនេះផងដែរ។ កាតព្វកិច្ចក្នុងការលាតត្រដាង គឺជាកាតព្វកិច្ចនៅបន្តមានដែលតម្រូវឱ្យមជ្ឈត្តករលាតត្រដាងអំពីផលប្រយោជន៍ ទំនាក់ទំនង និងបញ្ហានានា ដែលអាចកើតមានឡើងនៅគ្រប់ដំណាក់កាលនៃនីតិវិធីបណ្តឹង។ មជ្ឈត្តករនោះ ត្រូវលាតត្រដាងអំពីផលប្រយោជន៍ ទំនាក់ទំនង និងបញ្ហានានា ដោយការបញ្ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការចម្រុះសម្រាប់គូភាគីធ្វើការពិចារណា។

*ភារកិច្ចរបស់មជ្ឈត្តករ*

៥. នៅពេលតែងតាំងរួច មជ្ឈត្តករត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យបានហ្មត់ចត់ និងឆាប់រហ័សក្នុងដំណើរការទាំងមូលនៃនីតិវិធីបណ្តឹង។

៦. មជ្ឈត្តករត្រូវបំពេញភារកិច្ចដោយស្មោះត្រង់ និងប្រកបដោយការយកចិត្តទុកដាក់។

៧. មជ្ឈត្តករត្រូវពិចារណាលើបញ្ហាណាដែលបានលើកឡើងក្នុងនីតិវិធីបណ្តឹង ហើយដែលមានភាពចាំបាច់សម្រាប់ការសម្រេចចិត្តតែប៉ុណ្ណោះ និងមិនត្រូវធ្វើប្រតិភូកម្មភារកិច្ចក្នុងការសម្រេចចិត្តនេះ ទៅបុគ្គលផ្សេងទៀតឡើយ។

៨. មជ្ឈត្តករ ត្រូវចាត់វិធានការសមស្របក្នុងការធានាថា ជំនួយការនិងបុគ្គលិករបស់ខ្លួនបានដឹង និងបានអនុលោមតាមកថាខណ្ឌ២, ៣, ៤, ១៦, ១៧ និង ១៨។

៩. មជ្ឈត្តករ មិនត្រូវចូលរួមក្នុងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង ពាក់ព័ន្ធនឹងនីតិវិធីបណ្តឹង ដូចមានចែងក្នុងកថាខណ្ឌ២៩ និង៣០ នៃឧបសម្ព័ន្ធ៨-ក ឡើយ។

*ឯករាជ្យភាព និងភាពមិនលម្អៀងនៃសមាជិកក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម*

១០. មជ្ឈត្តករ ត្រូវមានឯករាជ្យភាព និងភាពមិនលម្អៀង។ មជ្ឈត្តករត្រូវបំពេញសកម្មភាពដោយយុត្តិធម៌ ត្រូវជៀសវាងការបង្កើតឱ្យមានការស្តែងចេញនូវការប្រព្រឹត្តមិនត្រឹមត្រូវ ឬភាពលម្អៀង និងមិនត្រូវទទួលរងឥទ្ធិពលពីផលប្រយោជន៍ផ្ទាល់ខ្លួន សម្ពាធពីខាងក្រៅ ការពិចារណាផ្នែកនយោបាយ ការទាមទារតវ៉ាជាសាធារណៈ និងភាពស្មោះត្រង់ចំពោះភាគីម្ខាង ឬសេចក្តីភ័យខ្លាចរងការរិះគន់ឡើយ។

១១. ដោយផ្ទាល់ ឬប្រយោលក្តី មជ្ឈត្តករមិនត្រូវទទួលនូវកាតព្វកិច្ច ឬទទួលផលប្រយោជន៍ដែលនឹងជៀតជ្រែក ឬស្តែងឡើងនូវការជៀតជ្រែក ក្នុងការបំពេញភារកិច្ចដោយត្រឹមត្រូវរបស់មជ្ឈត្តករឡើយ ទោះក្នុងមធ្យោបាយណាក៏ដោយ។

១២. មជ្ឈត្តករមិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួនក្នុងនាមជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ដើម្បីបង្កើនផលប្រយោជន៍ឯកជន ឬផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ មជ្ឈត្តករត្រូវជៀសវាងសកម្មភាពណាដែលអាចបង្កើតនូវការយល់ឃើញថាបុគ្គលផ្សេងៗស្ថិតក្នុងស្ថានភាពពិសេសមានឥទ្ធិពលលើមជ្ឈត្តករនោះទេ។

១៣. មជ្ឈត្តករមិនត្រូវអនុញ្ញាតឱ្យទំនាក់ទំនងហិរញ្ញវត្ថុ ធុរកិច្ច ការងារ គ្រួសារ ឬសង្គម ឬទំនួលខុសត្រូវផ្សេងៗក្នុងអតីតកាល ឬកំពុងមានស្រាប់ មានឥទ្ធិពលលើការប្រព្រឹត្ត ឬការវិនិច្ឆ័យរបស់មជ្ឈត្តករឡើយ។

១៤. មជ្ឈត្តករត្រូវជៀសវាងការមានទំនាក់ទំនងណាមួយ ឬទទួលយកនូវផលប្រយោជន៍ហិរញ្ញវត្ថុដែលទំនងនឹងប៉ះពាល់ដល់ភាពមិនលម្អៀងរបស់មជ្ឈត្តករ ឬដែលអាចបង្កើតឱ្យមានការស្តែងឡើងនូវការប្រព្រឹត្តមិនត្រឹមត្រូវ ឬមានភាពលម្អៀង។

*កាតព្វកិច្ចនៃអតីតមជ្ឈត្តករ*

១៥. រាល់អតីតមជ្ឈត្តករទាំងអស់ ត្រូវតែជៀសវាងសកម្មភាពណាដែលអាចបង្កើតឱ្យមានការស្តែងឡើងថាអតីតមជ្ឈត្តករទាំងនោះមានភាពលម្អៀងក្នុងការអនុវត្តភារកិច្ចរបស់ពួកគេ ឬបានទទួលផលប្រយោជន៍ពីសេចក្តីសម្រេច ឬការវិនិច្ឆ័យនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម។

*ការសម្ងាត់*

១៦. នៅពេលណាក៏ដោយ មជ្ឈត្តករ ឬអតីតមជ្ឈត្តករ មិនត្រូវលាតត្រដាង ឬប្រើប្រាស់ព័ត៌មានទាំងឡាយណាដែលមិនមែនជាព័ត៌មានសាធារណៈពាក់ព័ន្ធនឹងនីតិវិធីបណ្តឹង ឬដែលទទួលបានក្នុងអំឡុងពេលនៃនីតិវិធីបណ្តឹងឡើយ លើកលែងតែសម្រាប់គោលបំណងនៃនីតិវិធីបណ្តឹងទាំងនោះ ហើយក្នុងករណីណាក៏ដោយ មិនត្រូវលាតត្រដាង ឬប្រើប្រាស់ព័ត៌មានទាំងនេះ ដើម្បីទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍សម្រាប់បុគ្គលដទៃ ឬដើម្បីប៉ះពាល់យ៉ាងខ្លាំងលើផលប្រយោជន៍របស់បុគ្គលដទៃឡើយ។

១៧. មជ្ឈត្តករ មិនត្រូវលាតត្រដាងការវិនិច្ឆ័យនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ឬផ្នែកណាមួយនៃការវិនិច្ឆ័យនេះ មុនពេលការបោះពុម្ពផ្សាយឡើយ។

១៨. នៅពេលណាក៏ដោយ មជ្ឈត្តករ ឬអតីតមជ្ឈត្តករ មិនត្រូវលាតត្រដាងកិច្ចពិភាក្សាដេញដោលនៃក្រុមប្រឹក្សាជំនុំជម្រះនៃមជ្ឈត្តកម្ម ឬមតិរបស់មជ្ឈត្តករណាមួយឡើយ។

# ជំពូកទី ៩
# ការលើកលែង

## មាត្រា៩.១៖ ការលើកលែងទូទៅ

សម្រាប់គោលបំណងនៃជំពូកទី២ (ពាណិជ្ជកម្មទំនិញ) ជំពូកទី៣ (វិធានដើមកំណើត) ជំពូកទី៤ (នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម) និងជំពូកទី៥ (ឧបាស្រ័យពាណិជ្ជកម្ម) មាត្រា XX នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ និងកំណត់បកស្រាយនានានៃមាត្រានេះ ត្រូវបានដាក់បញ្ចូល និងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះដោយ*ត្រូវយកមកអនុវត្តដូចគ្នា*។[1]

## មាត្រា៩.២៖ ការលើកលែងដោយមូលហេតុសន្តិសុខ

១. មិនមានបញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បី៖

(ក) តម្រូវឱ្យភាគីម្ខាងផ្តល់ព័ត៌មានណាក៏ដោយ ដែលការលាតត្រដាងព័ត៌មាន នោះត្រូវបានភាគីនោះចាត់ទុកថាផ្ទុយនឹងផលប្រយោជន៍សន្តិសុខដ៏ចាំបាច់របស់ខ្លួន។

(ខ) ទប់ស្កាត់ភាគីម្ខាង ពីការចាត់វិធានការណាដែលភាគីនោះ ចាត់ទុកថាចាំបាច់ សម្រាប់ការការពារផលប្រយោជន៍សន្តិសុខចាំបាច់របស់ខ្លួនដែល៖

(i) ពាក់ព័ន្ធនឹងការចរាចរសព្វាវុធ គ្រាប់រំសេវ និងសម្ភារៈធ្វើសង្គ្រាម និងពាក់ព័ន្ធនឹងការចរាចរទំនិញ និងវត្ថុធាតុផ្សេងទៀតដែលបានរៀបចំឡើងដោយផ្ទាល់ ឬដោយប្រយោល សម្រាប់គោលបំណងផ្គត់ផ្គង់ដល់អង្គភាពយោធា។

(ii) ពាក់ព័ន្ធនឹងវត្ថុធាតុដែលអាចបំផ្ទុះបាន និងបញ្ចូលគ្នាបាន ឬវត្ថុធាតុដែលផលិតនូវវត្ថុធាតុទាំងនេះ។

(iii) ពាក់ព័ន្ធនឹងការការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ ពីការប៉ុនប៉ងដោយគ្រោងទុកជាមុន ក្នុងបំណងបញ្ឈប់ដំណើរការ ឬធ្វើឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធទាំងនោះ ឬ

(iv) បានដាក់ចេញនៅពេលប្រទេសជាតិមានភាពអាសន្ន សង្គ្រាម ឬភាពអាសន្នផ្សេងៗក្នុងទំនាក់ទំនងអន្តរជាតិ ឬ

(គ) ដើម្បីទប់ស្កាត់ភាគីម្ខាងពីការធ្វើសកម្មភាពណាមួយ ក្នុងការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុង *ធម្មនុញ្ញអង្គការសហប្រជាជាតិ* សម្រាប់ការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។

២. គណៈកម្មាធិការចម្រុះ ត្រូវទទួលបានការជូនដំណឹងឱ្យបានច្រើនជាអតិបរមាដែលអាចទៅបានអំពីវិធានការដែលបានចាត់ក្រោមវាក្យខណ្ឌ១(ខ) និង(គ) និងការបញ្ចប់នៃវិធានការទាំងនេះផងដែរ។

[1] គូភាគីយល់ថាវិធានការដែលសំដៅដល់ក្នុងមាត្រា XX(ខ) នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ រួមបញ្ចូលវិធានការបរិស្ថានដែលចាំបាច់ក្នុងការការពារជីវិត និងសុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ហើយយល់ឃើញផងដែរថាមាត្រា XX(ឆ) នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ អនុវត្តចំពោះវិធានការដែលពាក់ព័ន្ធនឹងការអភិរក្សធនធានធម្មជាតិដែលអាចបាត់បង់ទាំងស្រុង ទាំងមានជីវិត និងគ្មានជីវិត។

## មាត្រា៩.៣៖ ពន្ធដារ

១. លើកលែងតែមានចែងក្នុងមាត្រានេះ មិនមានបញ្ញត្តិណាមួយក្នុងកិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះវិធានការពន្ធដារឡើយ។

២ មិនមានបញ្ញត្តិណាមួយក្នុងកិច្ចព្រមព្រៀងនេះ ត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងពីរ ក្រោមអនុសញ្ញាពន្ធដារឡើយ។ ក្នុងករណីមានអសង្គតិភាព រវាងកិច្ចព្រមព្រៀងនេះ និងអនុសញ្ញាពន្ធដារទាំងនោះ អនុសញ្ញាពន្ធដារទាំងនោះត្រូវយកជាគោលត្រឹមចំណុចដែលមានអសង្គតិភាពនោះ។ ក្នុងករណីពាក់ព័ន្ធនឹងអនុសញ្ញាពន្ធដារ រវាងគូភាគី អាជ្ញាធរមានសមត្ថកិច្ចក្រោមអនុសញ្ញានោះ ត្រូវមានទំនួលខុសត្រូវទាំងស្រុងក្នុងការកំណត់ថាតើមានអសង្គតិភាពកើតឡើងរវាងកិច្ចព្រមព្រៀងនេះ និងអនុសញ្ញាពន្ធដារនោះ ឬទេ។

៣. កិច្ចព្រមព្រៀងនេះ ត្រូវផ្តល់ឱ្យនូវសិទ្ធិ ឬដាក់កាតព្វកិច្ចពាក់ព័ន្ធនឹងវិធានការពន្ធដារ នៅពេលណាដែលសិទ្ធិនិងកាតព្វកិច្ចនេះ ត្រូវបានផ្តល់ឱ្យ ឬដាក់ក្រោមមាត្រា២.៣ (ប្រព្រឹត្តកម្មជាតិ) ត្រឹមកម្រិតដែលមានចែងក្រោមមាត្រា III នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ តែប៉ុណ្ណោះ។

៤. សម្រាប់គោលបំណង នៃមាត្រានេះ៖

(ក) **អនុសញ្ញា ស្តីពីពន្ធដារ** សំដៅដល់អនុសញ្ញាសម្រាប់ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងផលចំណេញមូលធន និងការទប់ស្កាត់ការគិបកេងបន្លំពន្ធ និងការគេចពន្ធ ឬ កិច្ចព្រមព្រៀងឬកិច្ចរៀបចំ ពន្ធដារអន្តរជាតិដទៃទៀតដែលគូភាគីជាភាគី

(ខ) អាករ និងវិធានការពន្ធដារ មិនរាប់បញ្ចូលពន្ធគយដូចមានកំណត់ក្នុងមាត្រា១.១ (និយមន័យទូទៅ) និងវិធានការដែលមានក្នុងវាក្យខណ្ឌលើកលែង(ខ) (គ) (ឃ) និង(ង) នៃនិយមន័យនោះឡើយ។

(គ) **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់៖

(i) សម្រាប់កម្ពុជា រដ្ឋមន្រ្តីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាងដែលទទួលសិទ្ធិពីរដ្ឋមន្រ្តី និង

(ii) សម្រាប់កូរ៉េ អនុរដ្ឋមន្រ្តីដែលទទួលបន្ទុកពន្ធដារនិងគយ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬបុគ្គលបន្តវេន។

## មាត្រា៩.៤៖ ការលាតត្រដាងព័ត៌មាន

មិនមានបញ្ញត្តិណាមួយក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយថាតម្រូវឱ្យភាគីម្ខាងផ្តល់ឱ្យ ឬអនុញ្ញាតនូវសិទ្ធិទទួលបានព័ត៌មានសម្ងាត់ ដែលការលាតត្រដាងព័ត៌មានសម្ងាត់នេះ នឹងរារាំងការអនុវត្តច្បាប់ ឬផ្ទុយនឹងផលប្រយោជន៍សាធារណៈ ឬនឹងប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មដែលទទួលស្គាល់ដោយច្បាប់របស់សហគ្រាស ទាំងសាធារណៈ ឬឯកជន ឡើយ។

## មាត្រា៩.៥៖ ការសម្ងាត់

លើកលែងតែមានចែងផ្សេងពីនេះក្នុងកិច្ចព្រមព្រៀងនេះ នៅពេលភាគីម្ខាងផ្តល់ព័ត៌មានឱ្យភាគីម្ខាងទៀត ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ហើយកំណត់ព័ត៌មាននោះជាការសម្ងាត់ នោះភាគីដែលទទួលព័ត៌មាននោះ ត្រូវរក្សាការសម្ងាត់នៃព័ត៌មាននោះ។

## ជំពូកទី ១០
## ការរៀបចំស្ថាប័ន និងអវសានបញ្ញត្តិ
## ផ្នែក ក៖ បទបញ្ញត្តិនៃការរៀបចំស្ថាប័ន

**មាត្រា១០.១៖ គណៈកម្មាធិការចម្រុះ**

១. គូភាគីបង្កើតគណៈកម្មាធិការចម្រុះ ដែលមានសមាសភាពចូលចម្រុះដោយមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធពីភាគីនីមួយៗ។ គណៈកម្មាធិការចម្រុះនេះ ត្រូវដឹកនាំរួមដោយរដ្ឋមន្ត្រីពាណិជ្ជកម្មកម្ពុជា និងរដ្ឋមន្ត្រីពាណិជ្ជកម្ម ឧស្សាហកម្ម និងថាមពលកូរ៉េ ឬមន្ត្រីតំណាងរបស់ខ្លួនរៀងខ្លួន។

២. គណៈកម្មាធិការចម្រុះនេះត្រូវ៖

(ក) ត្រួតពិនិត្យឡើងវិញ និងត្រួតពិនិត្យតាមដានលើការអនុវត្ត និងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ

(ខ) ត្រួតពិនិត្យតាមដាន និងសម្របសម្រួលរាល់ការងាររបស់គណៈកម្មាធិការ ក្រុមការងារ និងអង្គភាពផ្សេងៗទៀតដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ

(គ) ពិចារណាលើមធ្យោបាយនានាក្នុងការលើកកម្ពស់ទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគរវាងគូភាគី

(ឃ) ដោយមិនប៉ះពាល់ដល់នីតិវិធីក្រោមជំពូកទី៨ (ការដោះស្រាយវិវាទ) ស្វះស្វែងដោះស្រាយបញ្ហា ឬវិវាទដែលអាចកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ

(ង) តាមដានវឌ្ឍនភាព នៃកម្មវិធីការងារ និងផ្ដល់ការណែនាំ និង

(ច) ពិចារណាលើបញ្ហានានាដទៃទៀតដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ នៃកិច្ចព្រមព្រៀងនេះ ឬវិស័យផ្សេងៗដែលគ្របដណ្ដប់ដោយកិច្ចព្រមព្រៀងនេះ ដូចដែលគូភាគីអាចឯកភាពគ្នា។

៣. គណៈកម្មាធិការចម្រុះនេះអាច៖

(ក) បង្កើតនិងធ្វើប្រតិភូកម្មការទទួលខុសត្រូវទៅគណៈកម្មការចំពោះកិច្ច និងគណៈកម្មការអចិន្ត្រៃយ៍ ក្រុមការងារ ឬអង្គភាពផ្សេង

(ខ) ពិចារណា និងផ្ដល់អនុសាសន៍ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះទៅគូភាគី

(គ) អនុម័តការបកស្រាយបទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ

(ឃ) អនុម័តវិធាននីតិវិធីរបស់ខ្លួន និង

(ង) ផ្ដល់អនុសាសន៍នានាជូនគូភាគី។

៤. នៅពេលភាគីម្ខាងផ្ដល់ព័ត៌មានដែលបានចាត់ទុកថាការសម្ងាត់ក្រោមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ខ្លួនជូនគណៈកម្មាធិការចម្រុះ ក្រុមការងារ ឬអង្គភាពផ្សេងៗដទៃទៀត ភាគីម្ខាងទៀត ត្រូវចាត់ទុកព័ត៌មាននោះជាការសម្ងាត់។

**មាត្រា១០.២៖ នីតិវិធី នៃគណៈកម្មាធិការចម្រុះ**

១. លើកលែងតែគូភាគីឯកភាពគ្នាផ្សេងពីនេះ គណៈកម្មាធិការចម្រុះនេះ ត្រូវបើក ៖

(ក) កិច្ចប្រជុំលើកដំបូងក្នុងរយៈពេល ១២ខែ គិតចាប់ពីការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ

(ខ) បន្ទាប់មក កិច្ចប្រជុំប្រចាំឆ្នាំធម្មតា ដោយកិច្ចប្រជុំនេះត្រូវបាន រៀបចំដោយផ្លាស់វេនគ្នា ក្នុងទឹកដី នៃភាគីនីមួយៗ និង

(គ) កិច្ចប្រជុំវិសាមញ្ញក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីទទួលបានសំណើរបស់ភាគីណាមួយក៏បាន ដោយកិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្នុងទឹកដី នៃភាគីម្ខាងទៀត ឬធ្វើឡើងក្នុងទីតាំងដូចដែលគូភាគីអាចឯកភាពគ្នា។

២. កិច្ចប្រជុំនានារបស់គណៈកម្មាធិការចម្រុះ អាចត្រូវបានធ្វើឡើងដោយជំនួបផ្ទាល់ ឬតាមរយៈមធ្យោបាយបច្ចេកវិទ្យាដែលគូភាគីមាន ប្រសិនបើគូភាគីឯកភាពគ្នា។

៣. រាល់សេចក្តីសម្រេច និងអនុសាសន៍ណែនាំរបស់គណៈកម្មាធិការចម្រុះ ត្រូវធ្វើឡើងដោយការព្រមព្រៀងគ្នាទៅវិញទៅមក។

## មាត្រា១០.៣៖ គណៈកម្មការ និងក្រុមការងារ

១. គណៈកម្មការខាងក្រោមនេះ ត្រូវបានបង្កើតឡើងចំណុះឱ្យគណៈកម្មាធិការចម្រុះ៖

(ក) គណៈកម្មការ ស្តីពីពាណិជ្ជកម្មទំនិញ ដោយអនុលោមតាមមាត្រា២.១៧ (គណៈកម្មការស្តីពីពាណិជ្ជកម្មទំនិញ)

(ខ) គណៈកម្មការ ស្តីពីវិធានដើមកំណើត និងនីតិវិធីគយ ដោយអនុលោមតាមមាត្រា៤.១៨ (គណៈកម្មការ ស្តីពីវិធានដើមកំណើត និងនីតិវិធីគយ)

(គ) គណៈកម្មការ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដោយអនុលោមតាមមាត្រា៦.៤ (គណៈកម្មការ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច)

២. គណៈកម្មាធិការចម្រុះ អាចបង្កើតគណៈកម្មការ ក្រុមការងារ ឬអង្គភាពផ្សេងៗបន្ថែមទៀតបាន រួមទាំងគណៈកម្មការ ស្តីពីតម្លាភាព ដូចមានចែងក្នុងមាត្រា១០.៦(ខ) (កម្មវិធីការងារ) ក្រោមកិច្ចព្រមព្រៀងនេះ។

៣. សមាសភាព ចំនួននៃកិច្ចប្រជុំ និងមុខងាររបស់គណៈកម្មការ ក្រុមការងារ ឬអង្គភាពផ្សេងៗដទៃទៀត ត្រូវអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធក្នុងកិច្ចព្រមព្រៀងនេះ ឬកំណត់ដោយគណៈកម្មាធិការចម្រុះ ដោយមានសង្គតិភាពជាមួយកិច្ចព្រមព្រៀងនេះ។

៤. គណៈកម្មការ ក្រុមការងារ ឬអង្គភាពផ្សេងៗដទៃទៀត ត្រូវជម្រាបជូនគណៈកម្មាធិការចម្រុះ អំពីកាលវិភាគ និងរបៀបវារៈ ក្នុងរយៈពេលគ្រប់គ្រាន់ឱ្យបានមុនកិច្ចប្រជុំនីមួយៗ។ អង្គភាពទាំងនេះត្រូវធ្វើសេចក្តីរាយការណ៍ជូនគណៈកម្មាធិការចម្រុះ អំពីសកម្មភាពក្នុងកិច្ចប្រជុំធម្មតារបស់គណៈកម្មាធិការចម្រុះ។

៥. គណៈកម្មាធិការចម្រុះ អាចធ្វើការសម្រេចផ្លាស់ប្តូរ ឬអនុវត្តការងារដែលបានដាក់ជូនគណៈកម្មការ ក្រុមការងារ ឬអង្គភាពផ្សេងៗដទៃទៀត ឬអាចរំលាយគណៈកម្មការ ក្រុមការងារ ឬអង្គភាពផ្សេងៗដទៃទៀតបាន។

## មាត្រា១០.៤៖ ចំណុចទំនាក់ទំនង

១. ដើម្បីសម្រួលដល់ការប្រាស្រ័យទាក់ទងគ្នារវាងគូភាគី រាល់កិច្ចការពាណិជ្ជកម្មដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ គូភាគី បង្កើតចំណុចទំនាក់ទំនង ដូចខាងក្រោម៖

(ក) សម្រាប់កម្ពុជា ក្រសួងពាណិជ្ជកម្ម និង

(ខ) សម្រាប់កូរ៉េ ក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និងថាមពល ឬស្ថាប័នបន្តវេន រៀងៗខ្លួន។

២. តបតាមការស្នើសុំរបស់ភាគីណាមួយក៏បាន ចំណុចទំនាក់ទំនងនៃភាគីម្ខាងទៀត ត្រូវចង្អុលបង្ហាញនូវស្ថាប័ន ឬមន្ត្រីទទួលខុសត្រូវរាល់បញ្ហាពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ និងត្រូវផ្តល់ឱ្យនូវការគាំទ្រដែលតម្រូវក្នុងការសម្រួលការប្រាស្រ័យទាក់ទងគ្នាជាមួយភាគីស្នើសុំ។ ភាគីនីមួយៗ ត្រូវផ្តល់ព័ត៌មានទៅភាគីម្ខាងទៀតអំពីរាល់ការផ្លាស់ប្តូរនៃចំណុចទំនាក់ទំនងរបស់ខ្លួនក្នុងរយៈពេលសមស្រប។

## ផ្នែក ខ៖ អវសានប្បញ្ញត្តិ

### មាត្រា១០.៥៖ ឧបសម្ព័ន្ធ សេចក្តីបន្ថែម និងលេខយោង

ឧបសម្ព័ន្ធ សេចក្តីបន្ថែម និងលេខយោង នៃកិច្ចព្រមព្រៀងនេះ ត្រូវក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ។

### មាត្រា១០.៦៖ កម្មវិធីការងារ

គូភាគីត្រូវ៖

(ក) ពិគ្រោះយោបល់ និងផ្តួចផ្តើមការចរចាពាណិជ្ជកម្មសេវា និងការវិនិយោគក្នុងរយៈពេល ១ឆ្នាំ បន្ទាប់ពីការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ និង

(ខ) បង្កើតគណៈកម្មការ ស្តីពីតម្លាភាព ក្នុងរយៈពេលសមស្របណាមួយតាមការឯកភាពគ្នាដោយគូភាគី ក្នុងគោលបំណងនៃការអនុវត្ត និងការប្រតិបត្តិជំពូកទី៧ (តម្លាភាព) ប្រកបដោយស័ក្តិសិទ្ធិភាព។

### មាត្រា១០.៧៖ ការត្រួតពិនិត្យឡើងវិញ នៃកិច្ចព្រមព្រៀងនេះ

បន្ទាប់ពីរយៈពេល ៤ឆ្នាំ ក្រោយពីការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ ឬនៅពេលណាមួយបន្ទាប់ពីនេះ តបតាមការស្នើសុំរបស់ភាគីម្ខាង គូភាគីអាចធ្វើការត្រួតពិនិត្យឡើងវិញនៃកិច្ចព្រមព្រៀងនេះ ដើម្បីជំរុញបន្ថែមនូវគោលបំណងនៃកិច្ចព្រមព្រៀងនេះ។ ការត្រួតពិនិត្យឡើងវិញនេះ អាចរួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹមតែការធ្វើឱ្យប្រសើរឡើងនូវការបើកទីផ្សាររបស់គូភាគី សំដៅជំរុញពាណិជ្ជកម្មរវាងគូភាគីនោះឡើយ។

### មាត្រា១០.៨៖ វិសោធនកម្ម

គូភាគីអាចឯកភាពគ្នាជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ។ រាល់វិសោធនកម្មត្រូវចូលជាធរមាន បន្ទាប់ពីគូភាគីផ្លាស់ប្តូរគ្នានូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈផ្លូវការទូតដោយបញ្ជាក់ថាបានបញ្ចប់រាល់លក្ខខណ្ឌ និងនីតិវិធីផ្ទៃក្នុងតម្រូវតាមផ្លូវច្បាប់ចាំបាច់នានា នៅកាលបរិច្ឆេទណាមួយដែលគូភាគីឯកភាពគ្នា។ វិសោធនកម្មនោះ ត្រូវក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ។

**មាត្រា១០.៩៖ វិសោធនកម្មលើកិច្ចព្រមព្រៀងអង្គការ WTO**

ប្រសិនបើមានបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអង្គការ WTO ដែលគូភាគីបានដាក់បញ្ចូលក្នុងកិច្ចព្រមព្រៀងនេះត្រូវបានធ្វើវិសោធនកម្ម គូភាគីត្រូវធ្វើការពិគ្រោះយោបល់ ដើម្បីពិចារណាធ្វើវិសោធនកម្មបទប្បញ្ញត្តិពាក់ព័ន្ធក្នុងកិច្ចព្រមព្រៀងនេះ តាមការសមស្រប ដោយអនុលោមតាមមាត្រា១០.៨ ខាងលើ។

**មាត្រា១០.១០៖ ការចូលជាធរមាន**

កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលគូភាគីបានផ្លាស់ប្តូរគ្នានូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ តាមរយៈផ្លូវការទូត ដោយបញ្ជាក់ថាបានបញ្ចប់រាល់លក្ខខណ្ឌ និងនីតិវិធីផ្ទៃក្នុងតម្រូវតាមផ្លូវច្បាប់ចាំបាច់នានា ឬនៅកាលបរិច្ឆេទផ្សេងទៀតដែលគូភាគីឯកភាពគ្នាជាលាយលក្ខណ៍អក្សរ។

**មាត្រា១០.១១៖ ការបញ្ចប់នៃកិច្ចព្រមព្រៀង**

ភាគីណាមួយក៏បាន អាចបញ្ចប់កិច្ចព្រមព្រៀងនេះដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈផ្លូវការទូតទៅភាគីម្ខាងទៀត ហើយការបញ្ចប់នេះ ត្រូវចូលជាធរមានក្នុងរយៈពេល ៦ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង។

**មាត្រា១០.១២៖ អត្ថបទយថាភូត**

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងជាពីរច្បាប់ ជាភាសាខ្មែរ ភាសាកូរ៉េ និងភាសាអង់គ្លេស ដោយអត្ថបទនីមួយៗមានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទភាសាអង់គ្លេស ត្រូវយកជាអត្ថបទគោល។

**ដើម្បីជាសក្ខីភាព** ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធិត្រឹមត្រូវពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

**ត្រូវបានធ្វើឡើង** ជាពីរច្បាប់នៅភ្នំពេញ និងសេអ៊ូល ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ ជាភាសាខ្មែរ ភាសាកូរ៉េ និងភាសាអង់គ្លេស។

| | |
|---|---|
| **សម្រាប់រាជរដ្ឋាភិបាល** | **សម្រាប់រដ្ឋាភិបាល** |
| **នៃព្រះរាជាណាចក្រកម្ពុជា** | **នៃសាធារណរដ្ឋកូរ៉េ** |